ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ការស៊ើបអង្កេតលើការិយាល័យសហចៅក្រមស៊ើបអង្កេតទាំងមូលគឺជាដំណោះស្រាយ

◆ អ៊ិត សារ៉េត សម្លាញ់ខ្ញុំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤២ ខែតុលា ឆ្នាំ២០១១

ស្វែងរកការពិត

លេខ១៤២ ខែតុលា ឆ្នាំ២០១១

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ការស៊ើបអង្កេតលើការិយាល័យសហចៅក្រមស៊ើបអង្កេត......................១

**ផ្នែកឯកសារ**

◆វីរភាព និងអនាគតភ្លឺស្វាងរបស់កុមារកម្ពុជា.......................................២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ពិធីសម្ពោធពាក្យស្លោកនៅក្រុងសៀមរាប..........................................៦

◆ស្ដាប់អតីតកុមារមូលដ្ឋានរៀបរាប់ ....................................................៨

◆“ខ្មែរក្រហមបោកប្រាស់ខ្ញុំ និងបងប្រុសខ្ញុំ”....................................១២

◆បង្រៀនសិស្សពីប្រវត្តិរបស់ខ្លួន..................................................១៤

◆រូបថតធ្វើឲ្យនឹកឃើញដល់អតីតកាល ..........................................១៨

**ផ្នែកច្បាប់**

◆អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញ........................២២

**វេទិកាពិភាក្សាសាធារណៈ**

◆ក្របខ័ណ្ឌស្ដីពីសិទ្ធិបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ...............៣៣

◆ខ្មែរក្រហមនៅក្នុងបរិបទសង្គ្រាមត្រជាក់......................................៤១

◆បញ្ហាសុខភាពអាចជាឧបសគ្គដល់ដំណើរការស្វែងរកការពិត.............៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆រឿងរ៉ាវពិតរបស់ខ្ញុំ.............................................................៥៧

◆អ៊ិត សារ៉េត សម្លាញ់ខ្ញុំ .......................................................៦០

◆ស្វែងរកឪពុកម្ដាយនិងបងប្អូន................................................៦១



សិស្សានុសិស្សចូលរួមពិធីសម្ពោធពាក្យស្លោក

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** ម៉ម សុវណ្ណ, រ៉េនដល ឌីហ្វាល់កូ, អេង គីមបឺលី, ដេវីដ ឆេនដល័រ, ឆាយ ឈុនលី, ឡៃ ហួត **អ្នកនិពន្ធនិងស្រាវជ្រាវ :** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ :** ទែន សុខស្រីនិត **និពន្ធនាយកទូទៅ :** ឆាំង យុ **ជំនួយការនិពន្ធនាយក :** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ :** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ :** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

# ការស៊ើបអង្កេតលើការិយាល័យសហចៅក្រមស៊ើបអង្កេតទាំងមូល គឺជាដំណោះស្រាយ

ក្នុងនាមជាស្ថាប័នមួយកំពុងធ្វើការដើម្បីការបង់ចាំ និងយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាមានតួនាទីដ៏សំខាន់មួយក្នុងការជួយធានាឲ្យបាននូវភាពស្របច្បាប់ និងជោគជ័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្តីខ្មែរក្រហម) ។ ដោយមិនមានជាប់ពាក់ព័ន្ធជាផ្លូវការណាមួយជាមួយនឹងសាលាក្តីខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាបានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើតឲ្យមានតុលាការនេះឡើង ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានផ្តល់ជូនឯកសារជាងប្រាំសែនទំព័ររួមទាំងខ្សែភាពយន្តឯកសារផែនទី រូបថត និងបទសម្ភាសន៍ជាច្រើនដល់តុលាការ ហើយតុលាការនេះក៏បានទទួលស្គាល់ដែរថា មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអ្នកផ្តល់ជំនួយ "ជាសម្ភារៈវត្ថុ" ដ៏ធំមួយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានបន្តជួយឧបត្ថម្ភដល់សាលាក្តីខ្មែរក្រហមតាមរយៈការផ្តល់ជូននូវការស្រាវជ្រាវ និងជំនាញឯកទេសរបស់ខ្លួនរហូតមកដល់ថ្ងៃនេះ ។

អស់រយៈពេលជាយូរមកហើយដែលអ្នកវិភាគគ្រប់ជាន់ថ្នាក់ និងស្ថាប័នសង្គមស៊ីវិលជាច្រើនបានចោទប្រកាន់ថាមានភាពមិនប្រក្រតីនិងការជ្រៀតជ្រែកផ្នែកនយោបាយនៅសាលាក្តីខ្មែរក្រហម ។ ការចោទប្រកាន់ទាំងអស់នេះគឺសំដៅទៅលើការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ថ្មីៗនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិគឺលោក ស៊ីគហ្វ្រីដ ប៊្លុង បានលាឈប់ពីតំណែងដែលបណ្តាលឲ្យមានការសង្ស័យថា កត្តាដែលជំរុញឲ្យលោកលាលែងពីតំណែងនោះគឺដោយសារមានការជ្រៀតជ្រែកផ្នែកនយោបាយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ។

ជាក់ស្តែង ការលាឈប់របស់លោក ស៊ីគហ្វ្រីដ ប៊្លុង រឹតតែជំរុញឲ្យមានភាពមន្ទិលសង្ស័យកាន់តែខ្លាំងឡើង និងការសន្និដ្ឋានមិនច្បាស់លាស់ទៅវិញទៅមកទាក់ទងទៅនឹងភាពមិនប្រក្រតីនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ ។ យ៉ាងណាមិញពេលវេលាសម្រាប់ការសន្និដ្ឋានប្រកបដោយភាពស្រពេចស្រពិល និងការជជែកដេញដោលបានកន្លងផុតទៅហើយនាពេលនេះ ។ ដូច្នេះអ្វីដែលចាំបាច់បំផុតនោះគឺថា អង្គការសហប្រជាជាតិត្រូវតែចាត់វិធានការឲ្យបានច្បាស់លាស់ដោយឥតរួញរាចំពោះបញ្ហានេះ ។

ភាពស្របច្បាប់របស់សាលាក្តីខ្មែរត្រូវបានរងផលប៉ះពាល់ដោយសារភាពជឿជាក់នៅក្នុងចំណោមសាធារណជនថាមានការជ្រៀតជ្រែកនយោបាយកើតមានឡើងនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ការដែលដាក់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីមកជំនួសលោក ស៊ីគហ្វ្រីដ ប៊្លុង នឹងមិនអាចជួយស្តារភាពជឿទុកចិត្តក្នុងចំណោមសាធារណជនមកលើសាលាក្តីខ្មែរក្រហមវិញបានទេ ។ មធ្យោបាយតែមួយគត់ដើម្បីស្តារកេរ្តិ៍ឈ្មោះរបស់សាលាក្តីខ្មែរក្រហមបាន និងដើម្បីឆ្លុះបញ្ចាំងឲ្យឃើញថា សហគមន៍អន្តរជាតិពិតជាយកចិត្តទុកដាក់លើការប្រឆាំងនឹងអំពើពុករលួយ និទ្ទណ្ឌភាព និងភាពអយុត្តិធម៌ គឺត្រូវតែមានការស៊ើបអង្កេតទៅលើកិច្ចការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទាំងមូលឲ្យបានហ្មត់ចត់ភ្លាមៗ មិនលម្អៀង និងប្រកបដោយតម្លាភាពនិងចាត់ឲ្យមានវិធានការដំណោះស្រាយសមហេតុផលបំផុត ។

ប្រសិនបើគ្មានការស៊ើបអង្កេតទេនោះ ស្ថាប័នដែលជាប់ពាក់ព័ន្ធនឹងសាលាក្តីខ្មែរក្រហមទាំងអស់ ដែលក្នុងនោះរួមមានអង្គការសហប្រជាជាតិផងច្បាស់ជាត្រូវបានចោទប្រកាន់ថាបានរួមដៃដើរជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឲ្យប៉ះពាល់ដល់ឱកាសចុងក្រោយដើម្បីស្វែងរកយុត្តិធម៌មួយសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម ដែលភាពឈឺចាប់របស់ជនរងគ្រោះទាំងអស់នេះមិនត្រូវបានអើពើ ហើយរងការគាបសង្កត់ពីផ្នែកនយោបាយអស់រយៈពេលជាងសាមសិបឆ្នាំកន្លងមកហើយ ។

**ឆាំង យុ**

# ជីវភាព និងអនាគតភ្លឺស្វាងរបស់កុមារកម្ពុជា

## ដកស្រង់ចេញពីឯកសារខ្មែរក្រហម D២១៣៨២

ក្នុងចលនាតស៊ូបដិវត្តន៍គ្រប់ជំនាន់ កុមារកម្ពុជាក្រោមការឃោសនាអប់រំ និងដឹកនាំរបស់អង្គការបដិវត្តន៍ បានរួមវិភាគទានយ៉ាងសកម្ម និងសមរម្យថ្លៃថ្លាបំផុតក្នុងការវាយកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទ ដើម្បីបុព្វហេតុរំដោះប្រទេសជាតិ និងរំដោះប្រជាជន ។

កាលពីក្នុងសម័យតស៊ូនយោបាយសម្ងាត់ កុមារយើងពិសេសកុមារដែលជាកូនកម្មករ-ពលករនៅទីក្រុង និងជាកូនកសិករក្រីក្រនៅជនបទបានរួមប្រាស័យធ្វើសកម្មភាពបដិវត្តន៍តាំងពីតូចៗម្ល៉េះ ។ កុមារខ្លះធ្វើនិរសាររត់សំបុត្រពីកន្លែងមួយទៅកន្លែងមួយ នាំឯកសារពីតំបន់មួយទៅតំបន់មួយ ឬរហូតដល់ឆ្លងខេត្តខណ្ឌជាច្រើនទៀត នៅក្រោមការត្រួតពិនិត្យ ឆែកឆេរ តាមដានឃ្លាំមើលយ៉ាងតឹងរ៉ឹងបំផុតរបស់ខ្មាំងទាំងយប់ទាំងថ្ងៃ ។ តែទោះជាសភាពការណ៍តឹងតែងយ៉ាងនេះក្តី ទោះជាខ្មាំងសម្លុត គំរាមកំហែង ឃោរឃៅ ហ្វាស៊ីសយ៉ាងណាក្តី ក៏កុមារយើងចេះប្រើប្រាជ្ញាឈ្លាសវៃ ប៉ិនប្រសប់ គេចចុះគេចឡើង បង្វិលតែជុំវិញខ្មាំង សម្រេចភារកិច្ចនិរសារនេះប្រកបដោយជោគជ័យជានិច្ច ។

កុមារខ្លះមានភារៈនាំផ្លូវកម្មាភិបាលដើរចុះឡើងធ្វើការនៅតាមមូលដ្ឋាន ឬជួយពង្រត់កម្មាភិបាលយកទៅលាក់បំពួនការពារសន្តិសុខ ពេលខ្មាំងរាតត្បាតមូលដ្ឋានម្តងៗ ។ កុមារខ្លះទៀតទទួលភារៈជាអ្នកស៊ើបការណ៍អំពីខ្មាំង ហើយផ្តល់ព័ត៌មានខ្មាំងជូនអង្គការបដិវត្តន៍យើង ។ កុមារខ្លះទៀតមានភារៈចាំយាមផ្លូវ ឬយាមផ្ទះ ដើម្បីឲ្យសញ្ញាដល់ពូៗកម្មាភិបាលដែលកំពុងធ្វើការ ឬប្រជុំសម្ងាត់នៅក្នុងបន្ទប់នៅពេលណាដែលមានខ្មាំងមកដល់ជិតៗទីនោះ ។ កុមារខ្លះទៀតមានភារៈដើររកម្ហូបចំណី បន្លែបង្ការ ត្រីសាច់ ផ្គត់ផ្គង់ កម្មាភិបាលដែលរស់នៅក្នុងសម្ងាត់ ពុំអាចចេញដើរហើររកស៊ីបានដូចគេឯង ។ កុមារយើងទទួលបំពេញភារកិច្ចនេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងដោយមនោសញ្ចេតនាបដិវត្តន៍ដ៏ជ្រាលជ្រៅបំផុតចំពោះពូៗ-មីងៗកម្មាភិបាលបដិវត្តន៍ ។ ក្នុងមួយថ្ងៃៗ កុមារយើងគ្មានឈប់ទំនេរដៃទេ កុមារដើររកជញ្ជាត់ត្រី ជញ្ជាត់កំពឹស ដឹកក្តាម ចាប់កង្កែប ឬធ្វើអន្ទាក់ ធ្វើដងដាក់សត្វ ដើម្បីបានត្រីសាច់ខ្លះយកមកផ្សែផ្សំធ្វើម្ហូប ផ្គត់ផ្គង់ពូ-មីងកម្មាភិបាល ។ ព្រមជាមួយនេះ កុមារដើរបេះបន្លែបង្ការតាមស្រែ តាមត្រពាំង ឬបេះស្លឹកឈើស្លឹកព្រៃណាដែលអាចហូបបានយក មកទុកធ្វើសម្លជូនពូ-មីងកម្មាភិបាលហូប ដើម្បីមានកម្លាំងបម្រើការងារបដិវត្តន៍ឲ្យបានច្រើន ។ ពេលទំនេរថ្ងៃត្រង់ កុមារក៏មិនដែលសម្រាកដែរ កុមារតែងឆ្លៀតទៅរកដឹកដំឡូងព្រៃ ដំឡូងទឹកទៀត ។ ពេលបានដំឡូងមក កុមារមិនហ៊ានហូបខ្លួនឯងទេ ឬហូបតែបន្តិចបន្តួច ហើយសល់ប៉ុន្មានទុកយកទៅស្ងោរជូនពូ-មីង កម្មាភិបាលបដិវត្តន៍ដែលកំពុងធ្វើការនៅតែក្នុងបន្ទប់ ។ល ។


កងកុមារត្រឡប់មកពីធ្វើការ

ក្នុងសម័យតស៊ូអាវុធ រួមផ្សំនយោបាយ ដើម្បីទប់ទល់ និងវាយកម្ចាត់សង្គ្រាមផ្ទៃក្នុងដែលចក្រពត្តិអាមេរិក និងបរិវារ បង្កឡើង កុមារកម្ពុជាយើងក៏បានរួមចំណែកយ៉ាងសកម្ម និងស័ក្តិសិទ្ធ បំផុតជាមួយនឹងពុកម៉ែ ប្រជាជនកម្ពុជាទាំងមូល ព្រមទាំងពូៗ កងទ័ពបដិវត្តន៍យើងផង ។ កុមារបានធ្វើជានិរសាររត់សំបុត្រកាត់ តំបន់ខ្មាំង ឬពីស្រុកភូមិដែលខ្មាំងកាន់កាប់ទៅមូលដ្ឋានព្រៃភ្នំ និងមូលដ្ឋានព្រៃភ្នំមកតំបន់ខ្មាំងវិញយ៉ាងអង់អាចក្លៀវក្លា និង ឈ្លាសវៃប៉ិនប្រសប់បំផុត ។ កុមារខ្លះចូលក្នុងក្រុមផលិត រួម ប្រយុទ្ធបង្កបង្កើនផលជាមួយពុកម៉ែ បងប្អូន មីងមាផ្សេងទៀត ដើម្បីប្រមូលស្បៀង ឧបត្ថម្ភពូៗ កងទ័ពនៅក្នុងព្រៃ និងឧបត្ថម្ភ បដិវត្តន៍ ។ កុមារខ្លះទៀតប្រើកលល្បិចយ៉ាងប៉ិនប្រសប់ បោក បញ្ឆោត បង្វែរពង្វាងខ្មាំង ជួយដឹកជញ្ជូនស្បៀងអាហារ ថ្នាំពេទ្យ និងសម្ភារៈផ្សេងៗយកទៅផ្តល់ជូនពូៗកងទ័ពនៅក្នុងព្រៃ ។ កុមារ ខ្លះទៀតដូចនៅខាងរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង បានចូលធ្វើ កងឈ្លប ជួយយាមកាមការពារភូមិឃុំ និងជួយពិនិត្យតាមដាន ចលនា និងសកម្មភាពខ្មាំង ។ នៅរដូវប្រាំងម្តងៗ ដែលខ្មាំងតែង ចុះវាតត្បាតតាមមូលដ្ឋានបង្អែកបដិវត្តន៍នានា កុមារយើងបាន រួមជាមួយពុកម៉ែ ពូមីង យាយតា ជួយធ្វើចម្រូងធ្នូ ស្នា ខ្នា យ៉ាងញាប់ដៃញាប់ជើង និងប៉ិនប្រសប់ទាំងយប់ទាំងថ្ងៃ ដើម្បី ប្រដាប់អាវុធឲ្យភូមិឃុំខ្លួនអាចប្រឈមមុខទប់ទល់ការវាតត្បាត របស់ខ្មាំង និងដើម្បីរក្សាការពារមូលដ្ឋានបដិវត្តន៍ការពារប្រជាជន និងទ្រព្យសម្បត្តិរបស់ប្រជាជនឲ្យបានដាច់ខាត ។ ក្រៅពីសកម្មភាព ខាងលើនេះ កុមារនៅបានរួមចំណែកក្នុងសកម្មភាពវប្បធម៌ សិល្បៈ សង្គមកិច្ច និងសុខាភិបាលនៅតាម មូលដ្ឋានបង្អែកបដិវត្តន៍ នានាទៀតផង ។

សរុបមក ក្នុងសម័យតស៊ូអាវុធ រួមផ្សំនយោបាយកន្លង ទៅនេះ កុមារកម្ពុជា ពិសេសកុមារ ដែលជាកូនចៅកម្មករ-ពលករ និងកសិករក្រីក្របានបង្ហាញនូវវីរភាពបដិវត្តន៍យ៉ាងខ្ពង់ខ្ពស់បំផុត បញ្ចេញនូវស្មារតីអង់អាចក្លាហាន ស្មារតីឈ្លាសវៃ ប៉ិនប្រសប់ និងស្នាដៃឆ្នៃប្រឌិតគ្រប់បែបយ៉ាង យ៉ាងរស់រវើក ដើម្បីសម្រេច ភារកិច្ចបដិវត្តន៍ដែលអង្គការប្រគល់ឲ្យប្រកបដោយជោគជ័យ ជានិច្ច ។ ក្នុងការសម្រេចភារកិច្ចបដិវត្តន៍ដ៏មានគ្រោះថ្នាក់ខាង លើនេះ កុមារយើងបានពុះពារគ្រប់ឧបសគ្គឆ្លងកាត់ការលំបាក វេទនា អត់ឃ្លានឈឺថ្កាត់គ្មានថ្នាំសង្កូវ ហ៊ានពលីកម្មគ្រប់បែបយ៉ាង បង្ហូរញើសឈាម ជាមួយពុកម៉ែ ប្រជាជនទូទៅ រហូតដល់ហ៊ាន បូជាអាយុជីវិតដ៏ក្មេងខ្ចីរបស់ខ្លួនយ៉ាងអង់អាចក្លាហាន ដើម្បី បុព្វហេតុបដិវត្តន៍ គឺរំដោះប្រទេសជាតិ និងរំដោះប្រជាជនកម្ពុជា ។

កាលពីសម័យសង្គ្រាមផ្ទៃក្នុង កុមារយើងមួយចំនួនត្រូវ បានខ្មាំងចាប់យកទៅឃុំឃាំង ដាក់គុក ច្រវ៉ាក់ ធ្វើទារុណកម្មលើ រូបរាងកាយយ៉ាងឃោរឃៅព្រៃផ្សៃបំផុតរហូតដល់កុមារខ្លះត្រូវ ពលីនៅក្នុងគុក ឬក្នុងកន្លែងឃុំឃាំង ។ កុមារខ្លះត្រូវពិការអស់មួយ ជីវិត កុមារខ្លះទៀតមានសុខភាពខ្សោយរហូតពុំអាចធ្វើការងារ ធ្ងន់បានដូចគេឯងឡើយ ពេលចេញពីគុកមកវិញ ។ កុមារខ្លះទៀត ត្រូវខ្មាំងចាប់វះពោះ កាត់ក្បាល កាត់ដៃកាត់ជើង ខ្វេះគ្រាប់ភ្នែក ចាក់សម្លាប់នឹងចំពុះទុង ដើម្បីធ្វើការគាបសង្កត់លើឪពុកម្តាយ ជរិតសួរចម្លើយយ៉ាងព្រៃផ្សៃហ្វាស៊ីសបំផុត ។ នៅចំពោះមុខអំពើ ឃោរឃៅ ហ្វាស៊ីសទាំងនេះរបស់ខ្មាំង កុមារកម្ពុជាមិនត្រឹមតែ មិនបាក់បបខ្លបខ្លាច ចុះញ៉មសារភាពខ្មាំងប៉ុណ្ណោះទេ តែផ្ទុយទៅ វិញ កុមារយើងកាន់តែមានកំហឹងឆាបឆេះសន្ធោសន្ធៅចំពោះខ្មាំង ហើយចងគំនុំជាមួយខ្មាំងជារៀងរហូតអស់មួយជីវិត ។ ដូច្នេះ កុមារកម្ពុជាបានរួមសកម្មភាពយ៉ាងជិតស្និទ្ធជាមួយពុកម៉ែ មាមីង បងប្អូន ប្រជាជនទូទៅ លើកជ្រោងគ្រវីទង់ប្រយុទ្ធ វាយកម្ទេចខ្មាំង យ៉ាងអង់អាចក្លាហានបំផុតជាប់រៀងរហូតមក ។

ក្នុងសម័យសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និង បរិវារជាង៥ឆ្នាំកន្លងទៅនេះ កុមារកម្ពុជាដែលមានប្រពៃណីបដិវត្តន៍ អង់អាចក្លាហាន និងឈ្លាសវៃក្នុងការសម្រេចភារកិច្ចបដិវត្តន៍ ក៏បានរួមវិភាគទានក្នុងការប្រយុទ្ធកម្ទេចខ្មាំងកាន់តែសកម្ម កាន់តែ សស្រាក់សស្រាំថែមទៀត ទាំងនៅសមរភូមិមុខ ទាំងនៅសមរភូមិ ក្រោយ ។

នៅសមរភូមិក្រោយ កុមារយើងបានចូលក្នុងក្រុមកុមារ ស្នេហាជាតិ ប្រយុទ្ធបង្កបង្កើនផលជាសមូហភាព ដើម្បីប្រមូល ស្បៀងឧបត្ថម្ភទៅពូៗកងទ័ពនៅសមរភូមិមុខផង ខំហាត់ហ្វឹកហ្វឺន វិជ្ជាយោធា វាយខ្មាំងផង ត្រៀមបម្រុងខ្លួនជាស្រេច ចូលបម្រើ កងទ័ពបដិវត្តន៍នៅពេលណាដែលអង្គការត្រូវការភ្លាម ។ ព្រម

ជាមួយនេះ កុមារយើងនៅបានឆ្លៀតពេលទំនេរ ខិតខំរៀនសូត្រអក្សរ និងលេខដើម្បីកសាង និងបង្កើនសមត្ថភាពខ្លួន ។

កុមារក្នុងក្រុមសហករណ៍ក៏បានរៀនវប្បធម៌ផង ធ្វើពលកម្មបង្កបង្កើនផលផង ។ កុមារបានចុះប្រឡូកធ្វើស្រែចម្ការជាមួយសមាជិកសហករណ៍ផ្សេងទៀត ជួយឃ្វាលគោក្របី ថែទាំឲ្យទឹកឲ្យស្មៅ គោក្របីសហករណ៍ ដោយយកចិត្តទុកដាក់ទទួលខុសត្រូវ និងស្រឡាញ់ថ្នាក់ថ្នមបីដូចជាគោក្របីរបស់ឪពុកម្តាយខ្លួនដែរ ។ កុមារជួយចិញ្ចឹមថែទាំឲ្យបាយទឹក ចំណីដល់ជ្រូក មាន់ ទា ក្នុងក្រុមសហករណ៍ ដោយអស់ពីចិត្តពីថ្លើម ។ ក្រៅពីនេះ កុមារនៅបានចូលរួមប្រាស្រ័យកាប់ដី លើកដី ជញ្ជូនដី ធ្វើទំនប់ ជីកប្រឡាយ ជីកស្រះ ធ្វើអាងទឹក ដោះស្រាយរកទឹកបង្កបង្កើនផលយ៉ាងសស្រាក់សស្រាំ ទាំងយប់ ទាំងថ្ងៃ ដូចតែមនុស្សចាស់ដែរ ។ សកម្មភាពទាំងនេះរបស់កុមារក្នុងក្រុមសហករណ៍សុទ្ធតែជាវិភាគទានយ៉ាងសំខាន់មួយ ដែលបម្រើ និងជំរុញចលនាបង្កបង្កើនផល ឧបត្ថម្ភសង្គ្រាមបដិវត្តន៍ឲ្យផុលផុសខ្លាំងក្លាជានិច្ច ។

កុមារខ្លះទៀតបានធ្វើជានិរសាររត់សំបុត្រចុះឡើង ឬជានិរសារនាំផ្លូវកម្មាភិបាលដែលចេញដើរធ្វើការងារពីកន្លែងមួយទៅកន្លែងមួយ ពីមន្ទីរមួយទៅមន្ទីរមួយ ពីមូលដ្ឋានមួយទៅមូលដ្ឋានមួយទៀត ។ កុមារខ្លះទៀតបានធ្វើជាកងឈ្លបជួយយាមកាមតាមផ្លូវ ការពារសន្តិសុខភូមិឃុំ ដោយស្មារតីប្រុង ប្រយ័ត្នបដិវត្តន៍ខ្ពស់បំផុត ។ ហេតុនេះហើយបានជាកុមារឈ្លបយើងតែងចាប់បានគិញ ភ្នាក់ងារចារកម្ម ឬសន្តិសម្ព័ន្ធរបស់ខ្មាំងដែលបន្លំខ្លួនចូលមកក្នុងភូមិឃុំ បង្កប់ខ្លួននៅតាមព្រៃដើម្បីធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍ និងប្រជាជនយើងជាញឹកញាប់ ។

នៅសមរភូមិមុខ កុមារយើងបានចូលក្នុងជួរកងទ័ព រួមប្រយុទ្ធវាយកម្ទេចខ្មាំងជាមួយពូៗ បងៗឯទៀតយ៉ាងអង់អាចក្លាហានបំផុត ពុះពារឧបសគ្គ ឆ្លងកាត់គ្រោះថ្នាក់ និងការលំបាកវេទនា អត់ឃ្លាន ឈឺថ្កាត់គ្មានថ្នាំសង្កូវ ខ្វះសព្វខ្វះគ្រប់ បានដោយជោគជ័យដូចតែពូៗ បងៗកងទ័ពឯទៀតដែរ ។ កុមារនិរសារបានរត់សំបុត្រនាំបញ្ជាពីក្រោយទៅមុខ ពីបញ្ជាការដ្ឋានទៅខ្សែប្រយុទ្ធជួរមុខបំផុត ដោយរត់ផង លូនផង ក្រាបផង ឆ្លងកាត់សមរភូមិក្រោមគ្រាប់រំសេវ និងគ្រោះថ្នាក់ច្រើនឥតគណនា ។ កុមារដឹកជញ្ជូនដែលពុំទាន់មានកម្លាំងកាយគ្រប់គ្រាន់ ដើម្បីដឹកជញ្ជូនសម្ភារៈធ្ងន់ៗក៏បានបរទេះគោ រទេះក្របី ធាក់កង់ អូសរ៉ឺម៉ក បើកឡាន បើកកាណូត ចែវទូក ក្រោមគ្រាប់រំសេវប្រសាចបីដូចគ្រាប់ភ្លៀងឆ្លងកាត់គ្រោះថ្នាក់ច្រើនរាប់មិនអស់ ដើម្បីដឹកជញ្ជូនស្បៀងអាហារ បាយទឹក គ្រាប់រំសេវ និងសម្ភារៈជាចាំបាច់ផ្សេងៗទៅផ្តល់ជូនកងទ័ពនៅសមរភូមិមុខបានយ៉ាងទៀតទាត់ ពុំដែលអាក់ខានឡើយ ទោះបីខ្មាំងបាញ់រះទម្លាក់គ្រាប់បែក ឬបាញ់ផ្លោង បាញ់ផ្តក់កាត់ផ្លូវគោក ផ្លូវទឹកទាំងយប់ ទាំងថ្ងៃយ៉ាងណាក្តី ។ល ។

ទាំងអស់នេះសុទ្ធសឹងជាសកម្មភាពប្រកបដោយវីរភាពបដិវត្តន៍ខ្ពង់ខ្ពស់បំផុតរបស់កុមារកម្ពុជាយើងក្នុងសម័យធ្វើសង្គ្រាមបដិវត្តន៍ប្រឆាំង និងវាយកម្ទេចនូវសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារ ។

ឥឡូវ មាតុភូមិកម្ពុជាជាទីស្នេហាត្រូវបានរំដោះទាំងស្រុង និងជាស្ថាពរហើយ ។ សន្តិភាពក៏ត្រូវបានកើតមានឡើងវិញនៅលើទឹកដីកម្ពុជាយើង ។ កុមារបដិវត្តន៍យើងដែលទើបចេញផុតពីភ្នក់ភ្លើងសង្គ្រាមក៏បានរួមចំណែកយ៉ាងសកម្ម មមាញឹកជាមួយពុកម៉ែ ប្រជាជនទូទាំងប្រទេស ព្រមទាំងពូៗ កងទ័ពគ្រប់អង្គភាពក្នុងកិច្ចការពារប្រទេស និងកសាងកម្ពុជាថ្មីឲ្យខ្លាំងក្លា សម្បូរសប្បាយថ្កុំថ្កើង រុងរឿង យ៉ាងសស្រាក់សស្រាំទាំងយប់ ទាំងថ្ងៃ និងដោយគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនយ៉ាងរឹងប៉ឹងជាបន្តទៀត ។

នៅតាមគ្រប់មូលដ្ឋាន គ្រប់កសិដ្ឋាន គេឃើញកុមារទាំងក្រុមៗចុះប្រឡូករួមធ្វើគ្រប់កិច្ចការជាមួយនឹងមនុស្សវ័យចាស់យ៉ាងសកម្មប្រយុទ្ធ មមាញឹកជារៀងរាល់ថ្ងៃ ។ នៅជនបទស្រែចម្ការ កុមារជួយកាប់រានដីថ្មី ។ កុមារហាត់រៀនភ្ជួររាស់ ។ កុមារខ្លះជួយដកស្ទូង កុមារខ្លះជួយរែក ឬដឹកសំណាប កុមារខ្លះទៀតឃ្វាលគោក្របី ។ ក្រៅពីនេះទៀត កុមារយើងនៅបានរួមប្រាស្រ័យយ៉ាងសកម្មក្នុងចលនាលើកទំនប់ ជីកប្រឡាយ លើកភ្លឺ ដើម្បីដោះស្រាយបញ្ហាទឹក រក្សាទឹក និងសន្សំទឹកទុក ធ្វើស្រែ ។ កុមារខ្លះកាប់ដី កុមារខ្លះទៀតជួយជញ្ជូនដី កុមារខ្លះទៀតជួយពូនដី បុកបង្ហាប់ដីយ៉ាងស្វាហាប់ ។

នៅតាមកសិដ្ឋាន កុមារជួយថែសួនបន្លែ ដោយរែកទឹកស្រោច ដាក់ជី បោចស្មៅ បេះសត្វល្អិត ឬដង្កូវដែលស៊ីបំផ្លាញផលដំណាំ ។ ក្រៅពីនេះ កុមារចិញ្ចឹមជ្រូកមាន់ទា ថែទាំឲ្យចំណីទឹកយ៉ាង

ទៀតទាត់ ធ្វើទ្រុងមាន់ ទ្រុងទា ទ្រុងជ្រូក ហើយថែទាំបោសសម្អាតយកលាមកសត្វធ្វើជីដាក់បន្លែផង និងរក្សាអនាម័យជានិច្ចកុំឲ្យសត្វឈឺផង ។

នៅតាមការដ្ឋាននានា ដូចជាការដ្ឋានធ្វើផ្លូវ សង់ស្ពាន ធ្វើផ្លូវរទេះភ្លើង និងសំណង់ផ្សេងៗ ក៏គេឃើញមានកុមារចូលរួមធ្វើសកម្មភាពទៅតាមលទ្ធភាព និងកម្លាំងកាយរបស់ខ្លួនដែរ ។

នៅតាមរោងចក្រ និងរោងជាងនានា គេឃើញមានកុមារធ្វើជាកម្មករ បញ្ជាម៉ាស៊ីនតូច-ធំ យ៉ាងស្ទាត់ជំនាញ ឬជួយខ្ចប់ ជួយប្រមូលផលិតផលក្នុងរោងចក្រ ឬមួយទៀតជួយយាមការពារសន្តិសុខរោងចក្រ ដោយស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់បំផុតមិនឲ្យខ្មាំងសត្រូវណាចូលមកយាយី ឬធ្វើវិទ្ធង្សនកម្មបំផ្លិចបំផ្លាញបានឡើយ ។

នៅក្នុងទីក្រុង ក៏គេសង្កេតឃើញកុមារជួយបោសសម្អាតផ្លូវថ្នល់ ជួយរៀបចំផ្ទះសម្បែង ថែទាំសម្អាតទីក្រុង និងជួយយាមកាមការពារសន្តិសុខទីក្រុងដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុតដែរ ។

ទន្ទឹមនឹងសកម្មភាពធ្វើការងារពលកម្មបង្កបង្កើនផលការពារប្រទេស និងកសាងប្រទេសខាងលើនេះ កុមារយើងក៏បានរៀនសូត្រវប្បធម៌ ដើម្បីកសាង និងបង្កើនសមត្ថភាពវប្បធម៌ខ្លួនផងដែរ ។ ការនេះធ្វើទៅបានគឺអាស្រ័យមានការចាត់តាំង ផ្លាស់វេនគ្នាធ្វើការ និងរៀនសូត្រជាបន្តបន្ទាប់ ។ ពេលយប់ទំនេរកុមារនៅបានទទួលការអប់រំ រៀនសូត្រនយោបាយ សតិអារម្មណ៍ចាត់តាំងបដិវត្តន៍ មានប្រជុំជីវភាពត្រួតពិនិត្យ ជួយកសាងគោលជំហរបដិវត្តន៍គ្នា និងដកពិសោធន៍ខុសត្រូវលើការងារដែលបានធ្វើក្នុងមួយថ្ងៃៗកន្លងមក ។

អាស្រ័យហេតុនេះហើយបានជាគេសង្កេតឃើញកុមារក្នុងសម័យកម្ពុជាថ្មីយើងនេះពិតមែនតែនៅតូចទេ តែមានរបៀបរៀបរយ ចេះស្រឡាញ់រាប់អានគ្នា សាមគ្គីគ្នារវាងកុមារ និងកុមារទាំងក្នុងការរស់នៅ ក៏ដូចក្នុងការងារប្រចាំថ្ងៃ ពុំដែលមានទាស់ទែងឈ្លោះប្រកែកគ្នា ជេរប្រទេចគ្នា ឬវាយតប់គ្នាដូចកុមារក្នុងសង្គមចាស់ឡើយ ។ ក្នុងគ្រប់កិច្ចការដែលជាភារកិច្ចរបស់ខ្លួន កុមារតែងយកចិត្តទុកដាក់ខិតខំធ្វើ ខិតខំបំពេញ ដោយស្មារតីទទួលខុសត្រូវខ្ពស់ និងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទុកខ្លួនខ្លួន គ្មានពឹងផ្អែកឬទម្រន់ចាំម៉ែ មីងមា យាយតាណា មកជួយធ្វើឡើយ ។ ព្រមជាមួយនេះ កុមារយើងក៏មានស្មារតីឆ្នៃប្រឌិត កសាងរស់រវើកក្នុងការសម្រេចភារកិច្ចរបស់ខ្លួនទៀតផង ។

បច្ចុប្បន្ននេះ ពិតមែនតែជីវភាពក្មួយទាំងឡាយមិនទាន់បានសម្បូរសប្បាយនៅឡើយទេ តែជីវភាពក្មួយៗមានការធានា ១០០ភាគរយហើយ ព្រោះក្មួយៗរស់នៅក្នុងសង្គមកម្ពុជាថ្មីដែលស្អាតស្អំ យុត្តិធម៌ គ្មានមនុស្សជិះជាន់មនុស្ស គ្មានអំពើពុករលួយពាលាអាវ៉ាសែ និងអំពើអបាយមុខផ្សេងៗទៀតឡើយ ។ ជាសង្គមដែលមនុស្សទាំងអស់ ទាំងនារី ទាំងបុរស ទាំងមនុស្សវ័យចាស់ ទាំងកុមាររស់នៅស្មើភាពគ្នា ហើយទាំងអស់គ្នាចុះប្រឡូកធ្វើពលកម្មបង្កបង្កើនផល កសាងប្រទេស និងការពារប្រទេសក្នុងសេចក្តីថ្លៃថ្នូរ និងកិត្តិយសថ្លៃថ្លារុងរឿងបំផុត ។ អនាគតភ្លឺស្វាងរះចាំងចែងនៅពីមុខក្មួយទាំងឡាយ ។ ក្មួយទាំងឡាយអស់ភ័យភិតឬព្រួយបារម្ភពីរឿងកំព្រាឯកោអានាថា អស់ភ័យភិតពីរឿងធំឡើងអត់ការធ្វើ អស់ភ័យភិតពីរឿងអត់ឃ្លាន ដាច់ពោះស្លាប់ អស់ភ័យភិតពីរឿងមិនចេះអក្សរ ឬធ្លាក់ខ្លួនទៅក្នុងអំពើអបាយមុខទៀតឡើយ ។ ក្នុងសង្គមកម្ពុជាថ្មីនេះ ក្មួយៗកុមារពិតជានឹងបានរស់នៅរីកធំធាត់ ចម្រើនលូតលាស់ក្នុងសុភមង្គលថ្លៃថ្លាបរិសុទ្ធ និងមានកិត្តិនាម កិត្តិសព្ទល្អ ជាអ្នកស្នេហាជាតិ ស្នេហាប្រជាជន ជាអ្នកបម្រើប្រទេសជាតិ បម្រើប្រជាជនយ៉ាងស្មោះសរបំផុត និងជាអ្នកកសាងស្ថាបនាកម្ពុជាថ្មីឲ្យបានកាន់តែខ្លាំងក្លា និងសម្បូរសប្បាយ ថ្កុំថ្កើង រុងរឿង ថែមទៀតជាលំដាប់ ។

ការអប់រំរៀនសូត្រ ដោយជាប់នឹងការងារពលកម្មផលិតយ៉ាងដូច្នេះ ធ្វើឲ្យកុមារយើងមានការរីកចម្រើន ព្រមជាមួយគ្នាទាំងរូបរាងកាយ ទាំងស្មារតី គំនិតបញ្ញា ទាំងគោលជំហរបដិវត្តន៍ គឺគោលជំហរស្នេហាជាតិ ស្នេហាបដិវត្តន៍ ស្នេហាប្រជាជន ស្រឡាញ់ពលកម្ម គោរពអង្គការវិន័យ ស្រឡាញ់ និងគោរពសមូហភាព ។ល។ ទាំងសមត្ថភាពការងារបម្រើប្រទេសជាតិ កសាងប្រទេសជាតិ និងការពារប្រទេសជាតិជាលំដាប់ផង ។ ការអប់រំកសាងកុមារបែបនេះ វាធានាឲ្យកុមារកម្ពុជាយើងរីកចម្រើនលូតលាស់ ហើយធ្វើដំណើរយ៉ាងត្រឹមត្រូវតាមមាគ៌ាបដិវត្តន៍ដ៏ត្រឹមត្រូវ និងភ្លឺស្វាង វាធានាឲ្យកុមារកម្ពុជាយើងបន្តវេនបដិវត្តន៍ ការពារប្រទេស និងកសាងប្រទេសតទៅអនាគតទៀតឲ្យបានគង់វង្ស ឋិតថេរ ខ្លាំងក្លា និងសម្បូរសប្បាយតរៀងទៅ ដោយជោគជ័យទាំងស្រុង ។

# ពិធីសម្ពោធពាក្យស្លោកនៅក្រុងសៀមរាប

កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ កន្លងទៅនេះ ពាក្យស្លោកលើកទី១២ត្រូវបានប្រារព្ធធ្វើឡើងនៅវិទ្យាល័យ១០ មករា ១៩៧៩ ក្រោមអធិបតីភាពពីសំណាក់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងលោក ហុង វិបុលវណ្ណា អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប ។

ពាក្យស្លោកទាំងពីរនេះគឺ «និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱនអធ្យាស្រ័យគ្នា» និង «រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍» ។ គោលបំណងនៃការសម្ពោធពាក្យស្លោកទាំងពីរដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា គឺដើម្បីជំរុញឲ្យមានការអត់ឱន ការអធ្យាស្រ័យ ការអប់រំ និងការផ្សះផ្សា ។ លើសពីនេះទៅទៀត ពាក្យស្លោកនេះមានអត្ថន័យយ៉ាងធំធេងដើម្បីជួយឲ្យក្មេងជំនាន់ចងចាំព្រឹត្តិការណ៍ពីអតីតកាលដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ក៏ដូចជាឧក្រិដ្ឋកម្មផ្សេងទៀតកុំឲ្យកើតមាននៅក្នុងប្រទេសកម្ពុជា និងជុំវិញពិភពលោកជាថ្មីម្តងទៀត ។

យុវសិស្ស សេង ម៉ាឡេត អាយុ១៨ឆ្នាំ ជាសិស្សថ្នាក់ទី១២ មានចិត្តសប្បាយរីករាយជាខ្លាំង ហើយក៏មានមោទកភាពផងដែរ ដែលវិទ្យាល័យនេះមានរៀបចំពិធីសម្ពោធពាក្យស្លោកទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។ ម៉ាឡេត បានរៀបរាប់ឲ្យដឹងថា ពេលដែលឃើញពាក្យស្លោកនេះ គឺធ្វើឲ្យខ្លួននឹកឃើញដល់ជីដូនដែលធ្លាប់និយាយប្រាប់រឿងរ៉ាវខ្មែរក្រហមថា «ការរស់នៅសម័យខ្មែរក្រហមមានការលំបាកយ៉ាងខ្លាំង ព្រោះប្រជាជនមិនមានអាហារហូបគ្រប់គ្រាន់ ធ្វើការងារហួសកម្លាំង និមានការសម្លាប់» ។ ដោយសារការប្រព្រឹត្តរបស់ខ្មែរក្រហម ជីតារបស់ ម៉ាឡេត ម្នាក់ក៏បានស្លាប់នៅក្នុងរបបនោះដែរ ។ ស្រស់ អូ ជាសិស្សថ្នាក់ទី១២ ក៏បានរៀបរាប់ឲ្យដឹងថា ការដាក់សម្ពោធពាក្យស្លោកនៅសាលាថ្ងៃនេះពិតជាមានសារសំខាន់ជាខ្លាំងសម្រាប់ការផ្សះផ្សា ទប់ស្កាត់


សិស្សានុសិស្សចូលរួមពីធីសម្ពោធដាក់តាំងពាក្យស្លោក


សិស្សានុសិស្សសួរសំណួរទាក់ទងនឹងប្រវត្តិសាស្ត្រ

អំពើប្រល័យពូជសាសន៍ និងកសាងសន្តិភាព ហើយថែមទាំងធ្វើឲ្យមនុស្សចេះស្រឡាញ់គ្នាដោយមិនប្រកាន់ពូជសាសន៍ វណ្ណៈ ពណ៌សម្បុរ និងគោរពគ្នាទៅវិញទៅមក ។

ទោះបីជារបបខ្មែរក្រហមបានដួលរលំទៅអស់រយៈពេលជាងសាមសិបហើយក៏ដោយ ក៏ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការសម្ពោធពាក្យស្លោកនេះនៅតែមានអត្ថន័យយ៉ាងធំធេងសម្រាប់ដាស់តឿន និងអប់រំក្មេងជំនាន់ក្រោយៗទៀតបានដឹង និងត្រិះរិះពិចារណា ហើយចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍ ដើម្បីកសាងសន្តិភាពនៅប្រទេសកម្ពុជា ។

**ម៉ម សុខណ្ណ**



លោក ឆាំង យុ (អាវដៃខ្លីពណ៌ស) និងលោកជំទាវ ទន់ សាអុីម ក្នុងឱកាសសម្ពោធពាក្យស្លោក


ម្ពុជាប្រជាធិបតេយ្យ


អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរៀបរាប់ពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅសិស្សានុសិស្ស

# ស្តាប់អតីតកុមារ មូលដ្ឋានរៀបរាប់



តូច ស៊ីវ៉ន ជាកុមារមូលដ្ឋានម្នាក់កាលពីជំនាន់ខ្មែរក្រហម ។ កាលណោះ ស៊ីវ៉ន ត្រូវបានចាត់តាំងឲ្យធ្វើការជាមួយក្មេងៗអាយុស្របាលគ្នាដែលជម្លៀសមកពីទីក្រុង ។ សព្វថ្ងៃ ស៊ីវ៉ន ជាគ្រូបង្រៀននៅវិទ្យាល័យ ហ៊ុន សែន ស្គន់ ខេត្តកំពង់ចាម ។

ស៊ីវ៉ន កើតនៅភូមិសង្កែ ឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាមដែលមានឪពុកម្ដាយជាកសិករ ។ ស៊ីវ៉ន មានបងប្អូនប្រាំពីរនាក់ (ប្រុសបី ស្រីបួននាក់) ហើយគាត់ជាកូនប្រុសពៅ ។ ស៊ីវ៉ន និងបងប្អូនមិនបានចូលរៀនទេ ដោយសារឪពុកម្ដាយមានជីវភាពខ្វះខាត ហើយម្យ៉ាងទៀតផ្ទះនៅឆ្ងាយពីសាលារៀនផង ។

បងប្រុសស្រីរបស់ ស៊ីវ៉ន ប្រាំនាក់បានចេញទៅធ្វើកម្មករសំណង់ និងការងារផ្សេងទៀតនៅទីក្រុងភ្នំពេញដើម្បីរកប្រាក់ឧបត្ថម្ភគ្រួសារ ។ នៅក្នុងភូមិឯស្រុកកំណើតបញ្ហាអសន្តិសុខដោយសារការវាយប្រយុទ្ធរវាងកងទ័ព លន់ នល់ និងយោធាខ្មែរក្រហមកើតមានជាញឹកញាប់ ។

នៅឆ្នាំ១៩៧៣ ភូមិកំណើតរបស់ ស៊ីវ៉ន ត្រូវបានកាន់កាប់ដោយខ្មែរក្រហម ។ ខ្មែរក្រហមបានកៀរគ្រួសារ ស៊ីវ៉ន និងប្រជាជនដែលនៅជាប់នឹងផ្លូវជាតិឲ្យទៅរស់នៅក្នុងព្រៃដែលមានចម្ងាយមួយគីឡូម៉ែត្រពីផ្លូវជាតិ ។ ជារឿយៗ កងទ័ពអាមេរិកបានមកទម្លាក់គ្រាប់បែកលើភូមិ និងផ្ទះសម្បែងប្រជាជនបណ្ដាលឲ្យខូតខាតទ្រព្យសម្បត្តិ ងាប់គោក្របី ព្រមទាំងរបួស និងបាត់បង់

អាយុជីវិតមនុស្សជាច្រើន ។ ព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកនេះ បានធ្វើប្រជាជនមានកំហឹងជាមួយនឹងកងទ័ពអាមេរិកយ៉ាងខ្លាំង ។ ស្របពេលនោះ កងទ័ព លន់ នល់ ក៏ចេញប្រតិបត្តិការដេញខ្មែរក្រហមពីក្នុងភូមិដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិ ។

ខ្មែរក្រហមបានអំពាវនាវឲ្យប្រជាជនដែលមានបងប្អូនកូនចៅរស់នៅ និងធ្វើការនៅភ្នំពេញ ត្រឡប់មកផ្ទះវិញព្រោះប្រទេសជិតចប់សង្គ្រាមហើយ ហើយអង្គការនឹងលើកទោសឲ្យអ្នកទាំងនោះ ។ នៅឆ្នាំ១៩៧៣ ដដែល ឪពុក ស៊ីវ៉ន បានទៅយកកូនប្រុសបីនាក់ដែលធ្វើសំណង់នៅភ្នំពេញមកផ្ទះ ចំណែកកូនស្រីពីរនាក់ទៀតបានត្រឡប់មកផ្ទះក្រោយពេលដែលខ្មែរក្រហមរំដោះឆ្នាំ១៩៧៥ ។

ដំបូងខ្មែរក្រហមបែងចែកប្រជាជនជាក្រុមសាមគ្គី និងបានចែកអង្ករទៅតាមកម្លាំងពលកម្ម និងចំនួនសមាជិកក្នុងគ្រួសារយកមកដាំហូបនៅផ្ទះរៀងៗខ្លួន ។ ក្រោយមក ខ្មែរក្រហមចាប់ផ្តើមធ្វើប្រវត្តិរូបប្រជាជនដោយដាក់គ្រួសារ ស៊ីវ៉ន នៅក្នុងគ្រួសារអនុធន ចំណែកគ្រួសារដែលគ្មានទ្រព្យសម្បត្តិត្រូវបានចាត់តាំងឲ្យធ្វើជាមេកង មេក្រុម និងមេភូមិ ។ អង្គការចាត់តាំងឪពុក ស៊ីវ៉ន ឲ្យធ្វើការនៅក្នុងកងសិប្បកម្មធ្វើរទេះ ហើយម្តាយគាត់ត្បាញកន្ទេលស្លឹកត្នោត និងការ៉ុង ។ ចំណែក បងប្រុសដែលទើបមកដល់ភូមិ អង្គការបានបែងចែកឲ្យនៅកងចល័តស្រុក គឺខែវស្សាត្រូវដើរដកស្ទូងនៅតាមតំបន់ផ្សេងៗ ហើយខែប្រាំងត្រូវលើកទំនប់ និងភ្ជួរស្រែ ។ បងស្រី ស៊ីវ៉ន ម្នាក់ទៀត អង្គការចាត់តាំងឲ្យទៅលើកទំនប់ ១មករា នៅកំពង់ថ្ម ខេត្តកំពង់ធំ ។

ចំណែក ស៊ីវ៉ន អង្គការឲ្យនៅកងឃ្វាលគោ ។ ថ្ងៃមួយ ពេល ស៊ីវ៉ន កៀងគោឲ្យស៊ីស្មៅនៅមុំថ្នល់ជាតិ ស្រាប់តែឃើញប្រជាជនជាច្រើនធ្វើដំណើរមកពីភ្នំពេញ ដោយមានទូល និងយួរបង្វេចខោអាវសំពីងសំពោង ។ ចំណែកសម្ភារៈ និងអីវ៉ាន់ខ្លះទៀតបានដាក់នៅលើកង់ ម៉ូតូ និង ឡាន ដោយមានមនុស្សរុញពីក្រោយ ។ រថយន្តជាច្រើនគ្រឿងត្រូវបានទុកចោល ព្រោះគ្មានផ្លូវបើកទៅមុខទៀតបាន (ដោយសារតែផ្លូវជាច្រើនកន្លែងទទួលរងការខូចខាតនៅក្នុងអំឡុងសង្គ្រាម១៩៧០-១៩៧៥) ។ មានគ្រួសារអ្នកជម្លៀសខ្លះដែលគ្មានមធ្យោបាយដឹកជញ្ជូនបាននាំគ្នាសែងអ្នកជំងឺ និងសាកសពសមាជិកគ្រួសារដែលស្លាប់តាមផ្លូវទៅកន្លែងបញ្ចុះជាមួយនឹងសំឡេងយំខ្សឹកខ្សួល ។

ស៊ីវ៉ន ឃើញក្មេងដែលជម្លៀសមកថ្មីខ្លះបានស្លៀកពាក់ខោអាវស្អាតបាត បានឡើងបេះផ្លែស្វាយទុំនៅលើដើមខ្ពស់ៗ ហើយក្មេងទាំងនោះមិនទាំងស្គាល់អង្រ្គង កន្ត្រែប និងស្រូវផង ។ ពេលឃ្លានខ្លាំង ក្មេងខ្លះបានដើរទៅរើសផ្លែត្នោតដែលជ្រុះមកកកេរហូតម្តាយក្មេងនោះមកអូសដៃដើម្បីបន្តដំណើរទៅមុខទៀត ។ ស៊ីវ៉ន មានការប្លែកក្នុងចិត្តយ៉ាងខ្លាំង ហើយគិតថាក្មេងៗទាំងនោះមិនដឹងអ្វីទាំងអស់ ។ ស៊ីវ៉ន នៅចាំពាក្យអង្គការដែលបានអប់រំគាត់ថា ប្រជាជនថ្មីទាំងនោះសុទ្ធតែពួកចក្រពត្តិ ជិះជាន់ កេងប្រវ័ញ្ច ។

អង្គការបានបញ្ជូនគ្រួសារអ្នកជម្លៀសចំនួន១៥គ្រួសារឲ្យមករស់នៅក្នុងភូមិរបស់ ស៊ីវ៉ន ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិប្រជាជននៅក្នុងភូមិទាំងអស់មកដាក់ក្នុងសហករណ៍ ។ នៅពេលនោះ ទោះបីឪពុកម្តាយ ស៊ីវ៉ន ជាអ្នកមូលដ្ឋានក៏ដោយ ក៏គ្រួសារគាត់ត្រូវមកហូបនៅរោងបាយរួមដែរ ។ ជារឿយៗ របបអាហារដែលអង្គការចែកឲ្យហូបមិនគ្រប់គ្រាន់ទេ ដូច្នេះ ឪពុកម្តាយ ស៊ីវ៉ន បានឆ្លៀតពេលរកមើមក្តួច និងគល់ចេកមកបបរលាយជាមួយអង្ករហូបបន្ថែមទៀត ។

ចំណែក ស៊ីវ៉ន អង្គការបានចាត់តាំងឲ្យទៅកាប់រំពាក់មកធ្វើខ្សែជាមួយក្មេងៗដទៃទៀត ដែលក្នុងចំណោមនោះមានមិត្តភក្តិរបស់គាត់ពីរនាក់គឺឈ្មោះ ពៅ និង ឈ្មោះ គាងម៉ាង ។ ស៊ីវ៉ន តែងតែធ្វើការងាររហើយមុនគេ ព្រោះគាត់ដឹងពីរបៀបហូតរំពាក់ពីចុងមកគល់ ហើយនៅសល់ពេល គាត់បានមកជួយមិត្តភក្តិគាត់ថែមទៀត ។ ក្មេងផ្សេងទៀតមិនដែលធ្លាប់ហូតរំពាក់ធ្វើខ្សែតែងតែយំស្រែកនៅពេលមុតបន្លាម្តងៗ និងមិនដែលធ្វើហើយតាមផែនការដែលប្រធានកងដាក់ឲ្យធ្វើទេ ។ ក្រៅពីម៉ោងធ្វើការ ក្មេងៗដែលជម្លៀសមកថ្មីទាំងនោះតែងតែមកយកចិត្ត និងសួរ ស៊ីវ៉ន ពីផ្លែឈើព្រៃដែលអាចបេះយកមកហូបបាន ។ នៅពេលនោះ ស៊ីវ៉ន បានស្គាល់គ្រួសារអ្នកថ្មីដូចជាគ្រួសារយាយ ផា និង គ្រួសារតាម៉ាប់ ដែលគ្រួសារទាំងពីរបាននៅរស់រហូតដល់របបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ចំណែកប្រជាជនថ្មីដប់បីគ្រួសារទៀតបានស្លាប់ទាំងអស់ ។

មួយរយៈក្រោយមក អង្គការបានចាត់តាំង ស៊ីវន ឲ្យទៅនៅកងកុមារ ដែលមានកុមារសរុបទាំងអស់១៥នាក់ ។ ពេលព្រឹក ប្រធានក្រុមចាត់តាំង ស៊ីវន ឲ្យប្រមូលជីអាចម៍គោឲ្យបាន៣០បង្គី និងពេលរសៀលត្រូវឃ្វាលគោចំនួន២០-៣០ក្បាល ជាមួយកុមារប្អូននាក់ផ្សេងទៀត ។ ថ្ងៃមួយ ស៊ីវន ឃើញមិត្តភក្តិម្នាក់ឈ្មោះ យ៉ុន កំពុងអង្គុយវាយបំបែកដីដំបូកមកលាយជាមួយទន្ទ្រានខែត្រ និងអាចម៍គោដើម្បីធ្វើជី ស្រាប់តែប្រធានកងដើរមកដាល់គាត់ចំកណ្តាលមុខដោយមិនដឹងពីមូលហេតុ ។ នៅពេលឈប់សម្រាកបើករបបថ្ងៃត្រង់ ប្រធានក្រុមបានដួសខ្លាញ់ជ្រូកដាក់ក្នុងចានបបររបស់ លី ដែលជាជនជាតិចាម ។ ឃើញដូច្នេះ លី ឈប់ហូបបបរនោះ រួចរត់មកផ្ទះគាត់វិញ ។ មួយសប្តាហ៍ក្រោយមក លី និងកុមារជនជាតិចាមពីរនាក់ទៀតគឺ កី និង យ៉ា ត្រូវឈ្លបយកទៅសម្លាប់ ។

នៅពេលនោះ បងប្រុស ស៊ីវន ឈ្មោះ ទូច ទៅលើកទំនប់ត្នោតពង ដែលស្ថិតនៅភូមិសង្កែ និងមានចម្ងាយប្រមាណមួយគីឡូម៉ែត្រពីផ្ទះរបស់គាត់ ក៏ត្រូវឈ្លបបានចាប់យកទៅឃុំឃាំងនៅស្តើងជ័យដែរ ដោយសារតែបងគាត់បានដើរសម្តែងតួ ដូចជាតួឯក គង់ សំអឿន នៅក្នុងរឿងល្ខោនជាមួយនឹងនារីម្នាក់ដែលត្រូវជាបងប្អូនជីដូនមួយ ។ នៅយប់នោះ មានក្មេងម្នាក់បានលួចមកខ្សឹបប្រាប់ ទូច ថា "ស្អែកឈ្លបនឹងយកពូទៅសម្លាប់ចោលហើយ" ទើប ទូច រត់គេចខ្លួនទៅភ្នំប្រុស-ភ្នំស្រី ។

ក្រោយមក អង្គការបានចាត់តាំងប្រធានភូមិឲ្យជ្រើសរើសគ្រួសារ ១៧ មេសា ឲ្យទៅរស់នៅ និងធ្វើការនៅភូមិថ្មី ដែលនៅទីនោះទទួលបានរបបអាហារបីពេលក្នុងមួយថ្ងៃ ហើយមួយអាទិត្យមានបង្អែមមួយពេលទៀតផង ។ ប៉ុន្តែអ្នកដែលបានស្ម័គ្រទៅមិនដែលឃើញត្រឡប់មករកបងប្អូន និងមកភូមិវិញទេ រួមទាំងបងប្អូនជីដូនមួយរបស់ ស៊ីវន ដែលជាអ្នកសារព័ត៌មានជំនាន់សង្គមរាស្ត្រនិយមម្នាក់ឈ្មោះ ពៅ គីម ដែរ ។

ក្រោយរដូវច្រូតកាត់ និងបោកបែនចប់រួចរាល់ ប្រធានភូមិចាត់តាំង ស៊ីវន និងកុមារ៤០នាក់ឲ្យទូលស្រូវពីភូមិទៅដាក់ក្នុងជង្រុកសហករណ៍ស្ថិតនៅវត្តស្តើងជ័យដែលមានចម្ងាយប្រមាណបួនគីឡូម៉ែត្រពីភូមិ ។ ប្រធានភូមិកំណត់ឲ្យកុមារទាំងអស់ទូលស្រូវឲ្យបានដប់ល្អីក្នុងមួយព្រឹក ។ ហើយបើនរណាធ្វើឲ្យកំពប់ស្រូវ អង្គការដាក់ពិន័យ ។

នៅឆ្នាំ១៩៧៧ អង្គការឈប់អនុញ្ញាតឲ្យ ស៊ីវន នៅជាមួយឪពុកម្តាយដូចមុនទៀតហើយ គឺគាត់ត្រូវស្នាក់នៅកងកុមារ ។ នៅពេលភ្លៀងម្តងៗ ស៊ីវន តែងតែយំព្រោះនឹកម្តាយ ដោយមិនហ៊ានឲ្យប្រធានកង ឬឈ្លបដឹងឡើយ ព្រោះខ្លាចឈ្លបវាយធ្វើបាប ។ ល្ងាចមួយ ពេល ស៊ីវន កំពុងកៀងគោមកដល់ខ្លោងទ្វារវត្តស្អាង ស្រាប់តែគាត់ឃើញឈ្លបសង្កាត់ស្តើងជ័យម្នាក់ចាប់កងចល័តនារីពីរនាក់យកមកពីស្រុកជើងព្រៃ បានមកដល់ផ្លូវនោះដែរ ។ ភ្លាមនោះ ស៊ីវន បានក្រាបនៅក្រោមដើមសង្កែដោយបណ្តោយឲ្យគោដើរទៅមុខមុន ។ មកដល់ដើមពោធិ៍មួយកន្លែង ឈ្លបបានយកស្នប់សប់ខ្យល់ចូលក្នុងមាត់អ្នកទោស ប៉ុន្តែអ្នកទោសបានរើបម្រះ ។ ឈ្លបទាំងនោះបានវាយធ្វើទារុណកម្មបង្ខំឲ្យអ្នកទោសរហូតលេបខ្យល់ពេញពោះ រួចហើយបានឲ្យអ្នកទោសរត់ពីមុខកង់យកទៅសម្លាប់នៅស្តន់ ។

ថ្ងៃមួយ ពេល ស៊ីវន ដឹកគោឲ្យស៊ីចំបើង គាត់បានឃើញកងចល័តម្នាក់រើសគ្រាប់ស្រូវមកទំពារ ពេលកំពុងបែនស្រូវស្រាប់តែឈ្លបឃើញក៏ស្ទុះមកទះកំភ្លៀងអ្នកនោះរហូតចេញឈាមតាមច្រមុះ ។ ប្រធានឈ្លបបានចាប់ចងដៃបុរសនោះទាំងពីរទៅក្រោយ រួចបណ្តើរយកទៅវាយ និងធ្វើទារុណកម្មនៅរោងបាយរួម និងបានប្រកាសប្រាប់កុំឲ្យអ្នកផ្សេងទៀតយកគំរូតាម ។ ចំណែកបងជីដូនមួយ ស៊ីវន ម្នាក់ឈ្មោះ ឌឹម ដែលលួចយកគួរស្រូវដាក់ ក្នុងហោប៉ៅមកផ្ញើកូនៗ ក៏ត្រូវប្រធានកងរាយការណ៍ឲ្យប្រធានភូមិមកពីខាងភូមិភាគនិរតីឈ្មោះ ភ័ន្ត ដែរ ។ ប្រធានភូមិបានចាប់ ឌឹម យកមករោងបាយរួម បន្ទាប់មកយកដំបងឫស្សីវាយលើគាត់ និងបានយកស្បែកជើងកង់ឡានវាយលើថ្ពាល់ទាំងពីរគាត់ថែមទៀត រួចហើយស្រែកសំឡុតថា "អ៊ែ្ហងលួចស្រូវប៉ុន្មានដងហើយ ហេតុអ្វីបានជាអ៊ែ្ហងក្បត់អង្គការ?" ហេតុការណ៍នោះធ្វើឲ្យប្រជាជនដែលកំពុងធ្វើការនៅក្នុងកងសិប្បកម្ម កងកិនស្រូវ និងត្បាញកន្ទេលក្នុងភូមិភ័យញ័រគ្រប់ៗគ្នា ។ បន្ទាប់ពីធ្វើទារុណកម្មរួច ឈ្លបនោះបានយកបងជីដូនមួយគាត់ចេញទៅបាត់ ។

នៅរដូវរំហើយ ស៊ីវន ឃើញកងចល័តម្នាក់ឈ្មោះ មាស

ជានិស្សិតមកពីភ្នំពេញចាប់ត្រីនៅវាលស្រែបាន រួចហើយបោះចូលក្នុងភ្នក់ភ្លើងដើម្បីហូប ។ ភ្លាមនោះ ឈ្លបបានឃើញហើយក៏យកដំបងឫស្សីពីងពង់មកវាយលើបុរសនោះឲ្យខ្ទាក់សាច់ត្រីឆ្អិនចេញពីមាត់ រួចយកត្រីរស់មកឲ្យបៀមវិញ ។ បន្ទាប់ពីវាយបាក់ដំបងឫស្សីពីងពង់ ឈ្លបបានទៅយកមែកសង្កែវាយគាត់បន្ថែមទៀត រួចហើយដឹកយកទៅសម្លាប់នៅស្តុន់ (បច្ចុប្បន្នប្រជាជនបានសាងសង់ផ្ទះលើរណ្តៅទាំងនោះ) ស្ថិតនៅខាងត្បូងវត្តស្តុន់ក្នុងភូមិបណា ឃុំសន្ទឹប ស្រុកជើងព្រៃ ។

នៅរដូវអត់អាហារខ្លាំង ស៊ីវ៉ន បានចាប់ឈ្លើងដែលទាមក្របីយកទៅដុត រួចយកឈាមនៅក្នុងពោះឈ្លើងមកហូប ។ ថ្ងៃមួយប្រធានភូមិបានបញ្ជា ស៊ីវ៉ន និងកុមារបីនាក់រមៀលដើមត្នោតមួយដើមដើម្បីទប់ទឹកកុំឲ្យហូរ ។ ស៊ីវ៉ន ធ្វើការរហូតដល់ថ្ងៃត្រង់ទើបរួចរាល់ ។ នៅពេល ស៊ីវ៉ន ត្រឡប់មកដល់រោងបាយរួម ប្រធានភូមិបានបញ្ជាឲ្យចុងភៅយកអន្ទាមចែកឲ្យ ស៊ីវ៉ន និងកុមារបីនាក់ទៀតដោយក្នុងម្នាក់ទទួលបានអន្ទាមមួយថ្នក់ក្រមា ។ ស៊ីវ៉ន អរយ៉ាងខ្លាំង រួចយកអន្ទាមឲ្យម្តាយគាត់លីង ហើយបុកដើម្បីសម្រិតយកកន្ទក់ហូប ។

នៅឆ្នាំ១៩៧៨ បងប្រុសរបស់ ស៊ីវ៉ន ដែលអង្គការចាត់តាំងឲ្យចិញ្ចឹមជ្រូក និងមាន់ ទា ដើម្បីផ្គត់ផ្គង់រោងបាយរួម បានទៅស្នើសុំប្រធានភូមិយក ស៊ីវ៉ន មកនៅជាមួយដើម្បីជួយដាំបបរជ្រូក និងដាក់បាយឲ្យជ្រូកស៊ី ។ នៅពេលនោះ ស៊ីវ៉ន បានហូបឆ្អែតដោយសារគាត់យកបាយដែលដាក់ឲ្យជ្រូកមកហូប ។ ស៊ីវ៉ន ធ្វើការនៅរោងចិញ្ចឹមជ្រូក រហូតដល់ឆ្នាំ១៩៧៩ ទើបគាត់ត្រឡប់មករស់នៅផ្ទះ ជួបជុំឪពុកម្តាយ និងបងប្អូនវិញ ។

នៅឆ្នាំ១៩៨០ ស៊ីវ៉ន បានចូលរៀននៅសាលាបឋមសិក្សាស្តើងជ័យ ហើយក្រោយមកគាត់ប្រឡងជាប់គ្រូបង្រៀន ។ នៅឆ្នាំ១៩៨៧ ស៊ីវ៉ន បានចេញបង្រៀននៅអនុវិទ្យាល័យស្តុន់ ក្រោយមកបានដំឡើងទៅជាវិទ្យាល័យ ហ៊ុន សែន ស្តុន់ ។

បច្ចុប្បន្ន ស៊ីវ៉ន ជាគ្រូបង្រៀនប្រវត្តិសាស្ត្រ ។ ស៊ីវ៉ន តែងតែនិយាយរឿងរ៉ាវរបស់គាត់ប្រាប់ទៅសិស្សទាំងអស់នៅក្នុងថ្នាក់ ទោះបីគ្រួសារគាត់ជាអ្នកមូលដ្ឋាននៅក្នុងសម័យនោះក៏ដោយ ។ **សោម ប៊ុនថន**



# "ខ្មែរក្រហមបោកប្រាស់ខ្ញុំ និងបងប្រុសខ្ញុំ"

នៅក្នុងសម័យកាលតស៊ូរបស់ខ្មែរក្រហម យុវជនជាច្រើននាក់ត្រូវបានជ្រើសរើសឲ្យចូលបម្រើបដិវត្តន៍ ។ មេដឹកនាំខ្មែរក្រហមបានប្រើមនោគមន៍វិជ្ជាបំផុសបំផុលឲ្យយុវជនទាំងអស់នេះតស៊ូយ៉ាងស្មោះស្ម័គ្រជាមួយនឹងខ្លួនដើម្បីជ័យជម្នះ ។ ក្រោយពេលដែលខ្មែរក្រហមបានឡើងកាន់កាប់អំណាចពេញលេញ យុវជនទាំងអស់ត្រូវនៅបំពេញការងាររបស់ខ្លួនតាមគោលនយោបាយដែលអង្គការថ្នាក់លើបានចាត់តាំង ។ នេះគឺជាសាច់រឿងពិតដែលបានកើតឡើងចំពោះ នេត ផល្លី ដែលបងប្រុសរបស់គាត់ នេត ប៊ុនធី ជាអ្នកស្ម័គ្របម្រើនឹងអង្គការត្រូវបានសម្លាប់នៅមន្ទីរ ស-២១ ហើយចំណែកឯរូបគាត់វិញត្រូវបានចោទថាជាខ្មាំង និងត្រូវបានអង្គការតាមសម្លាប់ ។ តែភ័ព្វសំណាង ផល្លី បានគេចផុតពីការតាមរាវតាមប្រមាញ់ដល់ជីវិតនេះ ។

នៅឆ្នាំ១៩៧០ ប៊ុនធី បានចូលបម្រើបដិវត្តន៍ ។ គាត់បានបន្តតស៊ូស្មោះស្ម័គ្រនឹងអង្គការ ដោយជួយបំផុសបំផុលប្រជាជននៅស្រុកអូររាំងឪ ខេត្តកំពង់ចាមដែលជាស្រុកកំណើតរបស់គាត់ឲ្យជឿលើចលនាតស៊ូរបស់បដិវត្តន៍ ។ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ប៊ុនធី បានក្លាយជាយោធានៅតំបន់ ២២ ភូមិភាគបូព៌ាដែលមានឈ្មោះ ធា ជាប្រធាន ។ នៅឆ្នាំ១៩៧៦ ផល្លី បានជួបជាមួយបងប្រុសគាត់ម្តងនៅបឹងស្នោរ ខេត្តកំពង់ចាម ហើយបាននិយាយគ្នាបានរយៈពេលប្រហែលមួយម៉ោង ។ ប៉ុន្តែនៅចុងឆ្នាំ១៩៧៨ ផល្លីបានទទួលដំណឹងថា បងប្រុសរបស់គាត់រងរបួសធ្ងន់ធ្ងរ ហើយកំពុងតែព្យាបាលនៅមន្ទីរពេទ្យ១៧មេសា (បច្ចុប្បន្នមន្ទីរពេទ្យរុស្ស៊ី) នៅទីក្រុងភ្នំពេញ ។ គាត់បានទៅសួរសុខទុក្ខបងប្រុសរបស់គាត់ចំនួនពីរលើក ហើយបានប្រាប់បងប្រុសរបស់គាត់ឲ្យស្នើសុំអង្គការចូលក្នុងកងជនពិការវិញ ដើម្បីកុំឲ្យមានឈ្មោះទៅសមរភូមិប្រយុទ្ធជាមួយវៀតណាម ។ ប៉ុន្តែនៅពេល ផល្លី ទៅសួរសុខទុក្ខបងប្រុសជាលើកទីបី បងប្រុសគាត់ក៏បានបាត់ខ្លួនពីមន្ទីរពេទ្យ ហើយមិនមាននរណាម្នាក់ដឹងពីមូលហេតុឡើយ ។ ផល្លី បានស៊ើបស្វែងរកគ្រប់ទីកន្លែងដែរ តែនៅតែរកមិនឃើញ ។

ចំណែក ផល្លី បានចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧៤ ។ គាត់ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកបើករថយន្តឲ្យនាយកដ្ឋានសាធារណការដឹកជញ្ជូននៅទីក្រុងភ្នំពេញ នៅពេលដែលខ្មែរក្រហមកាន់កាប់អំណាចទូទាំងប្រទេស ។ គាត់បានខិតខំតស៊ូបម្រើបដិវត្តន៍ ដោយមិនដែលរអ៊ូរទាំអ្វីឡើយ ។ ប៉ុន្តែ ភាពស្មោះស្ម័គ្រនិងការតស៊ូរបស់គាត់ត្រូវបានរលាយសាបសូន្យដោយសារគាត់ត្រូវបានអង្គការចោទថាខ្មាំងចូលដៃជាមួយវៀតណាម នៅពេលដែលកងយោធាវៀតណាមវាយដណ្តើមបានទីក្រុងភ្នំពេញ ។ គាត់បានព្យាយាមរត់គេចពីការតាមសម្លាប់



របស់ខ្មែរក្រហម ដោយរក្សាជីវិតរបស់គាត់រហូតដល់ស្រុកទេសមានសន្តិភាពវិញ ។

នេត ផល្លី បានដឹងពីដំណឹងថាបងប្រុសរបស់គាត់ស្លាប់នៅមន្ទីរស-២១តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គាត់មានភាពឈឺចាប់យ៉ាងខ្លាំងនៅពេលដែលដឹងថាបងប្រុសរបស់គាត់ដែលជាមនុស្សស្លូតត្រង់ស្មោះស្ម័គ្របម្រើជាតិដែលដឹកនាំដោយមេដឹកនាំខ្មែរក្រហមត្រូវបានចាប់ខ្លួនយកទៅសម្លាប់នៅគុកទួលស្លែងក្នុងរយៈពេលពីរសប្តាហ៍មុនពេលកងយោធាវៀតណាមវាយបានទីក្រុងភ្នំពេញ ។ ភាពស្មោះស្ម័គ្រនឹងអង្គការរបស់បងប្អូនគាត់ពីរនាក់ត្រូវបានខ្មែរក្រហមបោកប្រាស់ ហើយផ្តល់ឲ្យមកវិញនូវភាពឈឺចាប់ដែលមិនអាចបំភ្លេចបាន ។ ភាពឈឺចាប់នេះហើយដែលជំរុញឲ្យ ផល្លី ដាក់ពាក្យបណ្តឹងធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីស្វែងរកនូវយុត្តិធម៌ជូនបងប្រុសរបស់គាត់ ។

នៅក្នុងដំណើរការនីតិវិធីស្តីពីការវិនិច្ឆ័យស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលចាប់ផ្តើមដំណើរការពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ ផល្លី បានចូលរួមអង្គនីតិវិធីនេះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ។ នៅក្នុងអំឡុងពេលអង្គសវនាការនាពេលព្រឹកនេះ ជនជាប់ចោទ នួន ជា បានស្នើសុំចៅក្រមឡើងធ្វើសេចក្តីថ្លែងការណ៍មួយមុននឹងខ្លួនសុំមិនចូលរួមនៅក្នុងអង្គសវនាការនៃអង្គនីតិវិធីសម្រាប់ថ្ងៃនេះ ។ ជនជាប់ចោទ នួន ជា បាននិយាយថា ស្របពេលដែលខ្លួនមានឆន្ទៈនិងការប្តេជ្ញាចិត្តដើម្បីមានវត្តមានគ្រប់ពេលដែលអង្គសវនាការដំណើរការតាមអំណោយផលផ្នែកសុខភាពរបស់ខ្លួន នួន ជា សូមបញ្ជាក់ជូនចៅក្រម និងភាគីពាក់ព័ន្ធទាំងអស់នៅក្នុងអង្គសវនាការនៅក្នុងថ្ងៃនេះពីស្ថានភាពដ៏ចាស់ជរា និងទ្រុឌទ្រោមផ្នែកសុខភាពរបស់ខ្លួន ។ នួន ជា បានបន្តទៀតថា “ខ្ញុំមានបញ្ហាផ្លូវអារម្មណ៍ ។ ខ្ញុំអាចអង្គុយស្តាប់ដំណើរការនីតិវិធីតែរយៈពេលមួយម៉ោងទៅមួយម៉ោងកន្លះប៉ុណ្ណោះ ។ បន្ទាប់ពីនោះ ខ្ញុំចាប់ផ្តើមស្រវាំងភ្នែក ខួរក្បាលគក់ បេះដូងចាប់ផ្តើមលោតញ័រ ធ្វើឲ្យសម្ពាធឈាមឡើងខ្ពស់ ឈឺចង្កេះ ហើយអង្គុយបន្តទៀតលែងបាន” ។ ដូច្នេះ នួន ជា ស្នើសុំឲ្យចៅក្រមចាត់តាំងអ្នកជំនាញម្នាក់ទៀតដើម្បីវាយតម្លៃលើស្ថានភាពរបស់គាត់ឲ្យបានជាក់ច្បាស់ ។ ផល្លី បានបញ្ចេញប្រតិកម្មចំពោះការស្នើសុំនេះថា “បញ្ហាសុខភាពនេះ វាពិបាកនឹងវិនិច្ឆ័យណាស់ ពីព្រោះការពិត និងការភូតកុហកនៃស្ថានភាពជំងឺរបស់គាត់គឺឋិតនៅលើការនិយាយរបស់គាត់ទាំងអស់ ។ ទាំងអ្នកជំនាញនិងទាំងចៅក្រមក៏មិនអាចទៅវះកាត់បេះដូង នួន ជា បានទេ ពីព្រោះបញ្ហាសតិអារម្មណ៍ និងបញ្ហាវិកលចរិតនេះ មនុស្សយើងអាចធ្វើជាបាន ហើយក៏អាចធ្វើឆ្កួតបានដែរ” ។

នៅពេលសួរថា បើចៅក្រមសម្រេចចាត់តាំងអ្នកជំនាញម្នាក់ទៀតដើម្បីវាយតម្លៃលើស្ថានភាពកាយសម្បទារបស់ នួន ជា ក្រោយពីមានការវាយតម្លៃមួយរបស់លោកសាស្ត្រាចារ្យ ចន ខាំប៊ែល អ្នកជំនាញថែទាំមនុស្សចាស់ដែលចៅក្រមបានចាត់តាំងឲ្យវាយតម្លៃលើជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា ដែលរកឃើញថា នួន ជា មានស្ថានភាពធម្មតា ហើយអាចចូលរួមដំណើរការនីតិវិធីរបស់តុលាការបាននោះ ផល្លី បានជំទាស់ថា “នេះគ្រាន់តែជាលេសមួយរបស់ នួន ជា ដើម្បីមិនចូលរួមដំណើរការកាត់ទោសរបស់ខ្លួនតែប៉ុណ្ណោះ ពីព្រោះលោក ខាំប៊ែល បានអះអាងថា នួន ជា មានសុខភាពធម្មតាអាចចូលរួមដំណើរការកាត់ទោសបាន ។ ដូច្នេះ វាហាក់បីដូចជាថា នួន ជា បានកំពុងតែព្យាយាមបោកប្រាស់តុលាការដូចដែលខ្មែរក្រហមបោកប្រាស់បងប្រុសខ្ញុំ និងរូបខ្ញុំដូច្នោះដែរ” ។

ទោះជាយ៉ាងណាក្តី ក៏ ផល្លី បានទទួលស្គាល់ថា បញ្ហាសុខភាពទ្រុឌទ្រោម និងជរារបស់មេដឹកនាំខ្មែរក្រហមទាំងបួននាក់នេះចោទជាឧបសគ្គចម្បងដល់ដំណើរការស្វែងរកការពិតជូនបងប្រុសរបស់គាត់ និងបងប្អូនជនរងគ្រោះដែលត្រូវបានសម្លាប់នៅក្រោមការដឹកនាំរបស់ខ្មែរក្រហមជាច្រើននាក់ផ្សេងទៀត ។ គាត់បាននិយាយថា “តាមទ្រឹស្តីព្រះពុទ្ធ ជីវិតគឺមិនទៀង ។ វាអាចថា នៅថ្ងៃណាមួយមេដឹកនាំណាមួយអាចធ្លាក់ខ្លួនឈឺធ្ងន់ ហើយស្លាប់ក៏ថាបាន ។ បើដូច្នោះមែននោះ យុត្តិធម៌នឹងមិនសម្រេចបានទេ ។ ដូច្នេះ ខ្ញុំសូមសំណូមពរឲ្យចៅក្រមខិតខំប្រឹងប្រែងបន្តទៀតដើម្បីកាត់ទោសជនជាប់ចោទទាំងអស់ឲ្យបានឆាប់ កុំឲ្យជនជាប់ចោទចេះតែរកពុតត្បុត ឬលេសដើម្បីគេចវេះពីការពិត ហើយមិនទទួលស្គាល់ចំពោះទង្វើដែលខ្លួនបានប្រព្រឹត្ត” ។ **ផែន សុខស្រីនិត**

# បង្រៀនសិស្សពីប្រវត្តិរបស់ខ្លួន

ជ្រាន លីគាង កើតនៅភូមិកៀនជ្រៃក្រៅ ឃុំកៀនជ្រៃ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ លីគាង មានផ្ទះមួយខ្នងស្ថិតនៅតាមបណ្តោយទន្លេមេគង្គ និងមានចម្ងាយប្រាំបីគីឡូម៉ែត្រពីទីក្រុងកំពង់ចាម ។ លីគាង មានបងប្អូនប្រាំនាក់ (ស្រីពីរនាក់ និងប្រុសបីនាក់) គាត់ជាកូនទីបួន ។

នៅសម័យ លន់ នល់ ឪពុកម្តាយ លីគាង ប្រកបរបរដាំប៉ិគុ, ដំឡូង, សណ្តែក, ពោត និងថ្នាំជក់ ហើយដោយសារចង់រកប្រាក់ចំណូលមកផ្គត់ផ្គង់ជីវភាពគ្រួសារបន្ថែមទៀត ឪពុកម្តាយគាត់បង្កើតមុខរបរមួយទៀតគឺទិញម៉ាស៊ីនកិនស្រូវ ។ រៀងរាល់ថ្ងៃក្រៅពីថែចម្ការ ឪពុកម្តាយ លីគាង បានមករោងម៉ាស៊ីនកិនស្រូវដើម្បីកិនស្រូវឲ្យអ្នកភូមិ ។

ចាប់តាំងពីឆ្នាំ១៩៧២មក ខ្មែរក្រហមបានចូលមកឃោសនាពីចលនាបដិវត្តន៍ក្នុងភូមិរបស់គាត់ ធ្វើឲ្យម្ចាស់ចម្ការធំៗ និងអ្នកភូមិដែលមានជីវភាពធូធារ និងទ្រព្យសម្បត្តិស្តុកស្តម្ភមួយចំនួនមានការភ័យខ្លាច និងគេចចេញពីភូមិទៅរស់នៅក្រុងកំពង់ចាម ។ ចំណែកឯឪពុកម្តាយរបស់ លីគាង នៅប្រកបរបរកិនស្រូវ និងធ្វើចម្ការនៅក្នុងភូមិដដែល ប៉ុន្តែរាល់ពេលចេញចូលក្នុងភូមិផ្សេងៗ គាត់ត្រូវសុំការអនុញ្ញាតពីខ្មែរក្រហម ។

ក្រោយមក ខ្មែរក្រហមចាប់ផ្តើមធ្វើការជ្រើសតាំងប្រធានក្រុម និងប្រធានភូមិដើម្បីដឹកនាំប្រជាជន ។ ចំណែកការវាយប្រយុទ្ធរវាងកងទ័ព លន់ នល់ និងយោធាខ្មែរក្រហមក៏នៅតែបន្តរៀងរាល់ថ្ងៃ និងមានសភាពកាន់តែខ្លាំងក្លាឡើង ។ ឃើញដូច្នេះ ឪពុកម្តាយ លីគាង បានទិញផ្ទះមួយកន្លែងនៅខាងក្រោយវត្តជីជុះស្ថិតនៅក្នុងឃុំវាលវង់ ក្រុងកំពង់ចាម ហើយគាត់បាននាំកូនទាំងអស់មករស់នៅទីនោះវិញ ។ រៀងរាល់ព្រឹក ឪពុកម្តាយរបស់ លីគាង ត្រូវទៅមើលថែចម្ការ ផ្ទះសម្បែង និងរោងម៉ាស៊ីនកិនស្រូវនៅភូមិកំណើតដដែល ព្រោះនៅពេលនោះខ្មែរក្រហមនៅអនុញ្ញាតឲ្យប្រជាជនចេញចូលបាន ប៉ុន្តែគាត់តែងតែត្រឡប់មកមើលថែកូនៗវិញនៅពេលរសៀល ។

ក្នុងឆ្នាំ១៩៧៣ យោធាខ្មែរក្រហមបានបើកការវាយប្រហារកាន់តែខ្លាំងទៅលើទីប្រជុំជននានា និងបានឡោមព័ទ្ធទីក្រុងកំពង់ចាមទាំងមូល ។ ចំណែកការចេញចូលក្នុងភូមិ និងរាល់ទំនាក់ទំនងរវាងតំបន់រំដោះជាមួយនឹងតំបន់ លន់ នល់ គ្រប់គ្រងត្រូវបានរឹតបន្តឹងនិងហាមឃាត់ ។ ចាប់តាំងពីពេលនោះមក ឪពុកម្តាយ លីគាង លែងហ៊ានត្រឡប់ទៅភូមិកំណើតដូចមុនទៀតហើយ ព្រោះខ្លាចខ្មែរក្រហមចោទថា «ពួកសេរី» ចំណែក ដីចម្ការ ម៉ាស៊ីនកិនស្រូវ និងផ្ទះសម្បែងក៏គាត់បោះបង់ចោលទាំងអស់ដែរ ។ នៅពេលនោះ ការហូបចុកមួយភាគធំត្រូវពឹងផ្អែកទៅលើជំនួយអង្កររបស់អាមេរិក ។

មិនយូរប៉ុន្មាន យោធាខ្មែរក្រហមវាយយកបានទីក្រុង



លីគាង កំពុងបង្រៀនមេរៀនគំរូពីប្រវត្តិសាស្ត្រខ្មែរក្រហម

កំពង់ចាម ។ ក្នុងនោះ ខ្មែរក្រហមជម្លៀសក្រុមគ្រួសាររបស់ លីគាង ទៅចម្ការតាមបណ្តោយមាត់ទន្លេមេគង្គ ។ គ្រួសារ លីគាង បានទៅរស់នៅផ្ទះដែលអង្គការចែកឲ្យស្ថិតនៅឃុំជីហែ ស្រុកកំពង់សៀម ។ នៅទីនោះ ឪពុកម្តាយ លីគាង គ្មានបងប្អូនដែលអាចពឹងពាក់បានទេ ហើយម្យ៉ាងទៀត ដោយសារពេលនោះខ្មែរក្រហមមិនទាន់រឹតបន្តឹងក្នុងការរស់នៅ ទើបគាត់សុំអនុញ្ញាតពីអ្នកគ្រប់គ្រងទៅរស់នៅកោះក្រែងដែលមានទីតាំងនៅត្រើយម្ខាងនៃក្រុងកំពង់ចាម ដើម្បីងាយស្រួលត្រឡប់មកផ្ទះវិញ ព្រោះកងទ័ពរបស់ លន់ នល់ វាយកាន់កាប់ទីក្រុងកំពង់ចាមបានវិញ បន្ទាប់ពីយោធាខ្មែរក្រហមចូលគ្រប់គ្រងបានរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ ។ មកដល់កោះក្រែង ឪពុកម្តាយ លីគាង បានដើររកឈើ និងស្លឹកមកធ្វើខ្ទមស្នាក់នៅដោយខ្លួនឯង ហើយគាត់បានទិញទូកតូចមួយដើម្បីប្រើប្រាស់ក្នុងគ្រួសារ ។

លីគាង នៅចាំថា នៅថ្ងៃមួយវេលាម៉ោងប្រមាណប្រាំបួនយប់ពេលមេឃកំពុងភ្លៀង និងមានរន្ទះខ្លាំងៗ ឪពុកម្តាយរបស់ លីគាង បាននាំកូនៗឡើងជិះទូកដើម្បីគេចចេញពីខ្មែរក្រហម ។ យប់នោះ លីគាង រងាយ៉ាងខ្លាំងព្រោះភ្លៀងនៅតែធ្លាក់បន្តមិនដាច់ ។ លីគាង បានជិះទូករហូតដល់ភ្លឺទើបទៅដល់ក្រុងកំពង់ចាមដែលនៅទីនោះមានមន្ត្រីខាងរដ្ឋាភិបាល លន់ នល់ និងកាកបាទក្រហមមកចាំស្វាគមន៍ និងចែកស្បៀងដល់គ្រួសារគាត់ និងគ្រួសាររាប់ពាន់ទៀតដែលភៀសខ្លួនមកពីតំបន់ខ្មែរក្រហម ។

នៅអំឡុងពេលនោះ ឪពុកម្តាយ លីគាង មិនមានប្រកបមុខរបរអ្វីទេ ដូច្នេះបានទៅជួលដីមួយកន្លែងនៅភូមិកោះប៉ែនដើម្បីដាំបន្លែ និងថ្នាំជក់លក់យកប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារ ។ បន្ទាប់មក គាត់បានចុះឈ្មោះ លីគាង និងបងប្អូន លីគាង ឲ្យចូលរៀននៅសាលាបឋមសិក្សាជីជុះជាមួយកូនរបស់អ្នកភូមិដែលភៀសខ្លួនមកពីតំបន់ខ្មែរក្រហម ។

ជារឿយៗ យោធាខ្មែរក្រហមបានផ្លោងចូលមកក្រុងកំពង់ចាមធ្វើឲ្យប្រជាជនភិតភ័យយ៉ាងខ្លាំង ចំណែក លីគាង ដែលនៅវ័យក្មេងនៅឡើយមិនមានការបារម្ភពីគ្រោះថ្នាក់អ្វីទេ ។ រៀងរាល់ថ្ងៃ លីគាង តែងឈរមើលឧទ្ធម្ភាគចក្ររបស់កងទ័ព លន់ នល់ ហោះល្បាតចុះឡើងនៅលើផ្ទះគាត់យ៉ាងសប្បាយរីករាយ ។

លីគាង នៅចាំថា ថ្ងៃមួយវេលាម៉ោងដប់ព្រឹក ខ្មែរក្រហមបានផ្លោងគ្រាប់ជាច្រើនចូលក្រុងកំពង់ចាម ហើយឪពុកម្តាយគាត់ភិតភ័យយ៉ាងខ្លាំង រួចនាំគាត់និងបងប្អូនទាំងអស់ចូលពួននៅក្នុងលេណដ្ឋាន ។ ចាប់តាំងពីពេលនោះ លីគាង តែងតែរត់ពួនក្នុងលេណដ្ឋានពេលគាត់ឮគ្រាប់កាំភ្លើងម្តងៗ ។

នៅល្ងាចមួយ លីគាង បានឃើញយោធាខ្មែរក្រហមជាច្រើននាក់ដើរចូលក្រុងកំពង់ចាម ។ លីគាង សប្បាយចិត្តយ៉ាងខ្លាំងព្រោះឃើញយោធាខ្មែរក្រហមដែលមានអាយុស្របាលៗគាត់ និងមានប្រជាជនឈរចាំអបអរយ៉ាងច្រើន ។ នៅពេលនោះ លីគាង មិនបានដឹងថាមានរឿងអ្វីកើតឡើង ប៉ុន្តែស្រាប់តែនៅព្រឹកបន្ទាប់យោធាទាំងនោះបានមកដេញគ្រួសារគាត់ឲ្យចេញពីផ្ទះដោយប្រកាសថា «អង្គការរៀបចំទីក្រុងឡើងវិញ» ។ ឪពុកម្តាយ លីគាង បានរៀបចំខោ អាវ ចាន ឆ្នាំង អង្ករ និង ត្រី សាច់យកទៅជាមួយ ប៉ុន្តែយោធាខ្មែរក្រហមបានហាមថា «មិនបាច់យករបស់ទៅច្រើនទេ ព្រោះអង្គការឲ្យចេញតែរយៈពេលបីថ្ងៃប៉ុណ្ណោះ» ។

គ្រួសារ លីគាង ត្រូវយោធាខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅជីហែ ។ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៥ វេលាម៉ោងដប់មួយ ខ្មែរក្រហមយករថយន្តពីរគ្រឿងមកដឹកគ្រួសារ លីគាង និងប្រជាជននៅទីនោះទៅនៅឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ ។ លីគាង ទៅដល់ភូមិត្រាច វេលាម៉ោងប្រាំបួនយប់ ដោយខ្មែរក្រហមឲ្យគ្រួសារគាត់ដេកនៅវាលស្រែខាងមុខផ្ទះអ្នកភូមិ ។ យប់នោះ លីគាង រងាយ៉ាងខ្លាំងព្រោះជារដូវធ្លាក់ខ្យល់ត្រជាក់ពីជើង និងមានវាលស្រែធំល្វឹងល្វើយ ។

ព្រឹកឡើង ប្រធានភូមិបានបែងចែកគ្រួសារ លីគាង ឲ្យទៅរស់នៅផ្ទះឈើមួយខ្នងជាមួយគ្រួសារអ្នកមូលដ្ឋានឈ្មោះ ជា និង យឹម ព្រមជាមួយកូនរបស់គាត់បីនាក់ទៀត ។ ដំបូង គ្រួសារ លីគាង បានដាំបាយហូបជុំគ្នា និងអាចទៅរកត្រីមកហូបបាន ។ ក្រោយពីប្រធានភូមិចុះមកធ្វើប្រវត្តិរូប ឪពុកម្តាយគាត់ដាក់ថាធ្វើស្រែ និងចម្ការ ចំណែកបងប្អូនជីដូនមួយរបស់ លីគាង ឈ្មោះ គូ ឡេង ធ្វើជាគ្រូបង្រៀនបានសរសេរដាក់ប្រវត្តិរូបពិតប្រាកដរបស់គាត់ ។

ប្រធានភូមិបានចុះមកធ្វើប្រវត្តិរូបគ្រួសារ លីគាង និង

ប្រជាជនថ្មីចំនួនបីដងក្នុងរយៈពេលមួយខែ និងបានចុះតាមដានដល់កន្លែងដកស្ទូង និងភ្ជួររាស់ទៀតផង ។ ប្រសិនបើអង្គការរកឃើញថានរណាចុះប្រវត្តិរូបកុហក អ្នកនោះនឹងបាត់ខ្លួនមិនខាន ។

នៅក្នុងភូមិ លីគាង មានការលំបាកទំនាក់ទំនងគ្នាយ៉ាងខ្លាំង ព្រោះពេលនោះគាត់មិនអាចស្តាប់ភាសាអ្នកមូលដ្ឋានបាន ដោយសារគេនិយាយ «រដឹន» ហើយនៅចុងឃ្លាគេបញ្ចប់ដោយពាក្យ «នេះឯង» ។ ចំណែកចាស់ៗនិងក្មេងៗនៅមូលដ្ឋានតែងតែនាំគ្នាសើច និងធ្វើត្រាប់នៅពេលឮ លីគាង និយាយម្តងៗ ។

រដូវវស្សាចូលមកដល់ អង្គការបានបែងចែក លីគាង ដែលពេលនោះគាត់ទើបមានអាយុដប់មួយឆ្នាំឲ្យចូលកងកុមារ ចំណែកបងៗរបស់របស់គាត់នៅក្នុងកងចល័ត ។ បន្ទាប់មក អង្គការបានចាត់តាំង លីគាង ទៅធ្វើស្រែ និងឃ្វាលក្របីនៅវាលស្រែក្រោមដែលមានចម្ងាយប្រមាណម្ភៃគីឡូម៉ែត្រពីផ្ទះរបស់គាត់ ។ នៅទីនោះ លីគាង ទទួលបានបបររាវៗប៉ុណ្ណោះរហូតដល់រដូវច្រូត កាត់ទើបអង្គការចែករបបខាប់ឲ្យ ។ ថ្ងៃខ្លះ ពេល លីគាង ត្រឡប់មកពីធ្វើការវិញ ចុងភៅមិនទាន់ដាំស្លទេព្រោះពុំមានអង្ករ ។ លីគាង ត្រូវចេញទៅធ្វើការវិញទាំងពុំមានអ្វីបរិភោគ ពេលនោះដោយសារឃ្លានខ្លាំងពេកគាត់បានដើររកក្តាម និងខ្យងនៅតាមវាលស្រែមកហូបទាំងឆៅ ។

នៅយប់មួយ ប្រធានកងបានហៅកុមារនៅក្នុងកងទាំងអស់មកប្រជុំស្វ័យទិតៀន ប៉ុន្តែពេលនោះ លីគាង បានដេកលក់ដោយសារគាត់អស់កម្លាំងខ្លាំងពេក ។ ស្រាប់តែពេលនោះ ប្រធានកងបានចោទ លីគាង ថា «នៅសម្ងំចាំលួចបាយក្តាំង ទើបមិនមកចូលរួមប្រជុំ» រួចហើយរាយការណ៍ឲ្យឈ្លបមកចាប់ លីគាង យកទៅចងនៅក្នុងរោងបាយ រួចវាយធ្វើបាបរហូតដិតភ្លឺ ។ ក្រោយមកទើបមានប្រជាជនមូលដ្ឋានបានទៅប្រាប់ឈ្លបពីប្រវត្តិរូបគ្រួសាររូបឪពុកម្តាយ លីគាង ជាអ្នកស្រែ និងធ្វើការងារបានល្អ ទើបឈ្លបនោះដោះលែងវិញ ។

ជារឿយៗ លីគាង បានលួចរត់ចេញពីកងត្រឡប់មកផ្ទះវិញ ប៉ុន្តែគាត់មិនសូវបានជួបឪពុកម្តាយទេ ព្រោះឪពុកម្តាយគាត់ត្រូវអង្គការចាត់តាំងឲ្យចេញទៅដកស្ទូងនៅក្រៅភូមិ ។ ថ្ងៃមួយ ឈ្លបខ្មែរក្រហមបានមកតាមរក លីគាង ដល់ផ្ទះ ប៉ុន្តែពេលនោះគាត់បានរត់ទៅពួននៅវាលស្រែខាងក្រោយភូមិ ។ ឈ្លបបានទៅសួរម្តាយរបស់ លីគាង ប៉ុន្តែម្តាយគាត់បានកុហកថា មិនឃើញមកផ្ទះទើបគាត់បានរួចខ្លួន ។ ពេលនោះ ម្តាយ លីគាង តែងតែយករបបរបស់គាត់មកចែករំលែកឲ្យ លីគាង ហូប ហើយគាត់តែងតែប្រាប់ លីគាង កុំឲ្យលួចមកផ្ទះទៀត ព្រោះខ្លាចឈ្លបខ្មែរក្រហមវាយធ្វើបាប ។

ថ្ងៃមួយ ឈ្លបបានជិះសេះតាមទាន់ លីគាង រួចបណ្តើរគាត់ទៅកងកុមារវិញ ប៉ុន្តែពេលដើរទៅមុនបន្តិច គាត់បានរត់គេចតាមវាលស្រែត្រឡប់មកផ្ទះវិញ ។ នៅផ្ទះបានមួយរយៈ អង្គការបានចាត់តាំងឲ្យឪពុកម្តាយ លីគាង ទៅលើកទំនប់ និងជីកប្រឡាយនៅក្រយាសង្រ្កាមដែលមានចម្ងាយប្រមាណសាបសិបគីឡូពីភូមិរបស់គាត់ ។ ពេលនោះ លីគាង ក៏ទៅជាមួយឪពុកម្តាយគាត់ដែរ ។ លីគាង បានដើរកាត់ព្រៃតាំងពីព្រលឹម រហូតដល់រសៀលទើបដល់ការដ្ឋាន ។ លីគាង នៅធ្វើការលើកទំនប់ និងជីកប្រឡាយជាមួយឪពុកម្តាយរហូតដល់ចប់ទើបត្រឡប់មកភូមិវិញ ។

នៅក្នុងភូមិ លីគាង បានដើររើសអាចម៍គោធ្វើជី និងជញ្ជូនសំណាបទៅឲ្យអ្នកស្ទូង ។ នៅរដូវវស្សា លីគាង ពុំមានអាហារហូបគ្រប់គ្រាន់ទេ ដូច្នេះនៅពេលថ្ងៃគាត់បានដើររើសសម្បកដំឡូងមីមកហូប ហើយនៅពេលយប់គាត់បានដើរចាប់ចាបដែលទុំនៅលើគួរស្រូវ និងរើសត្នោតទុំដែលជ្រុះនៅតាមទួលតូចៗដែលមានសុទ្ធតែផ្នូរខ្មោចជនជាតិចិនមកហូបបន្ថែមទៀត ។ ថ្ងៃមួយ លីគាង បានដើរកាត់ទួលមួយដែលមានចម្ងាយប្រមាណបីគីឡូម៉ែត្រពីផ្ទះ ពេលនោះគាត់ឮសម្រែកអ្នកទោសជាច្រើនដែលឈ្លបខ្មែរក្រហមចាប់យកទៅសម្លាប់ ។

រៀងរាល់យប់ ឪពុកម្តាយ លីគាង ភិតភ័យយ៉ាងខ្លាំង ដោយសារគាត់ឮសំឡេងរទេះសេះ ព្រោះផ្ទះគាត់ស្នាក់នៅជាប់នឹងថ្នល់ជាតិរបស់ឈ្លបខ្មែរក្រហមមកដឹកប្រជាជនថ្មីយកទៅសម្លាប់ជាបន្តបន្ទាប់ ។ ចំណែកម្តាយមីង លីគាង ឈ្មោះ ផាត ដែលដកស្ទូងក្នុងភូមិ និងកូនរបស់គាត់ម្នាក់ឈ្មោះ អាក្តីរាប ព្រោះវាកើតនៅកំពង់ក្តី ឃុំជីហែ មុនពេលខ្មែរក្រហមជម្លៀសទៅនៅស្មោង ដែលទើបតែមានអាយុបីឆ្នាំក៏ត្រូវឈ្លបចាប់យកទៅសម្លាប់នៅពេលយប់ដែរ ។ ព្រឹកឡើង ឈ្លបទាំងនោះតែងតែយកសម្ភារៈនិង

ខោអាវរបស់ម្ដាយមីង លីគាង មកចែកឲ្យអ្នកភូមិប្រើប្រាស់វិញ ។

បន្ទាប់ពីសម្លាប់ម្ដាយមីង លីគាង បានមួយថ្ងៃ ឈ្លបខ្មែរក្រហមបានទៅហៅឪពុកមា លីគាង ឈ្មោះ ឡេង ដែលបានដាក់ក្នុងប្រវត្តិរូបថាជាគ្រូបង្រៀនឲ្យត្រឡប់មកភូមិ ។ ពេលឮដំណឹងនេះភ្លាម ឡេង អរយ៉ាងខ្លាំង ហើយគាត់បានយកអង្ករបីកំប៉ុង និងត្រីប្រឡាក់តូចៗប្រាំក្បាល មកផ្ញើឪពុក និងប្រពន្ធ ។ មកដល់ផ្ទះបន្ទាប់ពី ឡេង ដាក់ដាំបាយរួច ទើបឪពុកគាត់ត្រូវជាជីតា លីគាង ប្រាប់ថា «ឈ្លបចាប់ប្រពន្ធកូនឯងយកទៅបាត់ហើយ» ។ ឡេង មិននិយាយស្ដីអ្វីទាំងអស់ គឺបានត្រឹមតែដេកយំឱបឪពុកដែលដេកឈឺលើកន្ទេលដោយសារជំងឺចាស់ជរា ។ បន្ទាប់ពី ឡេង ដួសបាយជូនឪពុកគាត់ហូបរួច ឈ្លបខ្មែរក្រហមបានមកចាប់ចងដៃគាត់ទាំងពីរទៅក្រោយ នៅចំពោះមុខឪពុក និងបងប្អូនរបស់គាត់ រួចដឹកតាមកង់ចេញទៅបាត់ ។

ក្រោយមក អង្គការចាត់តាំងឲ្យ លីគាង ទៅរកខសជាមួយឪពុករបស់គាត់ ។ រៀងរាល់ព្រឹក លីគាង និងឪពុកត្រូវបរទេះចេញទៅកាប់ខសក្នុងព្រៃរហូតដល់ពេលព្រលប់ទើបត្រឡប់មកភូមិវិញ ។ លីគាង មិនដែលបានជួបបងប្អូនទេ ព្រោះអង្គការបញ្ជូនបងប្អូនគាត់ទៅធ្វើការនៅកន្លែងផ្សេងៗពីគ្នា ។ បងស្រីរបស់ លីគាង ម្នាក់ត្រូវអង្គការបញ្ជូនឲ្យទៅទៅលើកទំនប់នៅភ្នំសន្ទុកដែលមានចម្ងាយប្រមាណចិតសិបគីឡូម៉ែត្រពីផ្ទះ ។ ក្រោយមក បងស្រីរបស់គាត់បានសន្លប់លែងដឹងខ្លួនដោយសារធ្វើការងារធ្ងន់និងអត់អាហារ ។ ខ្មែរក្រហមបានទុកគាត់ចោលនៅក្នុងកងចល័ត ដោយសារគ្មានថ្នាំព្យាបាល ។ ម្ដាយ លីគាង បានយំយ៉ាងខ្លាំងក្រោយពីគាត់ទទួលដំណឹងពីអ្នកភូមិថា បងស្រីគាត់ឈឺធ្ងន់ និងមិនសង្ឃឹមរស់ ។ ប៉ុន្តែ ពេលវៀតណាមវាយចូលមកដល់ទីរួមខេត្តកំពង់ធំឆ្នាំ១៩៧៩ ស្រាប់តែឃើញគាត់ត្រឡប់មករកឪពុកម្ដាយនៅស្ទោងវិញ ។ ក្រុមគ្រួសារ លីគាង បានបរទេះរយៈពេលជិតមួយខែទើបមកភូមិកំណើតវិញ ។

លីគាង ចូលរៀនម្ដងទៀត ហើយនៅឆ្នាំ១៩៨៨ បានប្រឡងជាប់គ្រូប្រវត្តិវិទ្យានៅភ្នំពេញ ។ នៅឆ្នាំ១៩៩២ លីគាង បានចេញបង្រៀននៅវិទ្យាល័យព្រះសីហនុរហូតដល់សព្វថ្ងៃនេះ ។

**សោម ប៊ុនថន**



ជ្រាន លីជាង កំពុងបង្រៀនមេរៀនគំរូពីប្រវត្តិសាស្ត្រខ្មែរក្រហម

# រូបថតធ្វើឱ្យនឹកឃើញដល់អតីតកាល



ញ៉ែម សុផាន អាយុ៥៧ឆ្នាំ មានរូបថតជាច្រើនសន្លឹកដែលបានថតកាលពីរបបខ្មែរក្រហម ។ ក្នុងចំណោមរូបថតទាំងអស់ មានរូបមួយសន្លឹកថតដោយបងប្រុសជាទីស្រឡាញ់របស់សុផាន ដែលជាលេខាស្រុកសូទ្រនិគម ភូមិភាគឧត្តរ ។ សុផាន បានរក្សាទុករូប នេះរហូតដល់សព្វថ្ងៃ ។ នោះគឺជារូបថតរបស់សុផានក្នុងឯកសណ្ឋានកម្មាភិបាលពេទ្យដែលថតនៅខេត្តសៀមរាប នៅឆ្នាំ១៩៧៥ ពេលដែល សុផាន មានអាយុ១៥ឆ្នាំ ។ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១១ កន្លងទៅនេះ សុផាន បានមកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានយករូបថតមួយសន្លឹកទៀតមកជាមួយដែលរូបថតនោះ សុផាន ទើបតែរកឃើញកាលពីពេលថ្មីៗនេះ ។ រូបនោះគឺជារូបរបស់បងថ្លៃប្រុស សុផាន ឈ្មោះ កែវ ដែលថតនៅប្រទេសចិន ឬកូរ៉េខាងជើងកាលពីរបបកម្ពុជាប្រជាធិបតេយ្យ ។ សុផាន បាននិយាយដោយរីករាយថា «មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលរូបថតចាស់ៗជាច្រើនទុក ដូច្នេះខ្ញុំចង់ប្រគល់រូបថតនេះដើម្បីឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាអាចជួយថែរក្សាផង» ។

មុននឹងទៅចូលរួមតាមដានអង្គសវនាការរបស់ នួន ជា និង អៀង ធីរិទ្ធ នៅថ្ងៃបន្ទាប់ សុផាន បានអង្គុយនៅលើសាឡុងនៅក្នុងសណ្ឋាគារមួយដែលគាត់កំពុងស្នាក់នៅ ហើយសម្លឹងមើលទៅរូបថតរបស់ កែវ ដែលគាត់មិនដែលបានជួបមុខផ្ទាល់ទាល់តែសោះ ។ ប៉ុន្តែ សុផាន ក៏បានដឹងរឿងទាក់ទងនឹង កែវ ខ្លះដែរ ។ នៅក្នុងរូបថតនោះ កែវ បានថតជាមួយនឹងអ្នកធ្វើការ និងមន្ត្រីទូតបរទេសទាំងអស់មានចំនួនដប់ប្រាំនាក់ផ្សេងទៀតដែលម្នាក់ៗស្ថិតនៅក្នុងសម្លៀកបំពាក់ផ្លូវការ ។ កែវ គឺជាប្រតិភូម្នាក់ដែលត្រូវបានបញ្ជូនទៅប្រទេសចិន ឬកូរ៉េខាងជើងនៅដើមឆ្នាំ១៩៧៦ ។ សុផាន បាននិយាយថា «នៅពេលដែលបង កែវ ត្រឡប់មកស្រុកខ្មែរវិញ គាត់បានប្រគល់រូបថតជាច្រើនសន្លឹកមកឲ្យបងស្រីរបស់ខ្ញុំ (ដែលត្រូវជាប្រពន្ធរបស់ កែវ) » ។

សុផាន បានរៀបរាប់ថែ្លមទៀតថា រូបថតរបស់ កែវ មួយនេះគឺជារូបថតមួយក្នុងចំណោមរូបថតជាច្រើនដែលគាត់បានរក្សាទុក ។ នៅអំឡុងពាក់កណ្តាលរបបកម្ពុជាប្រជាធិបតេយ្យ ពេលដែលយុទ្ធនាការបោសសម្អាតបានធ្លាក់មកលើគ្រួសាររបស់ សុផាន សមាជិកគ្រួសារគាត់បានបោះចោលរូបថតជាច្រើន តែរូបថតរបស់ កែវ មួយនេះមិនបានបាត់បង់ទេដោយសារតែបាន

លាក់ទុកនៅក្រោមបាតវ៉ាលី ។ គ្រួសាររបស់ សុផាន បាននាំគ្នាបោះចោលរូបថត កែវ ទាំងអស់ ដើម្បីសុវត្ថិភាពក្រុមគ្រួសារទាំងមូល ក្រោយពេលដែល កែវ បានបាត់ខ្លួន ។

ក្រោយឆ្នាំ១៩៧៩ រូបថតនេះបានបាត់ម្តងទៀត ។ ក្រុមគ្រួសាររបស់ សុផាន បានស្វែងរករូបថតនេះគ្រប់ទីកន្លែងទាំងអស់នៅក្នុងផ្ទះ ។ អស់រយៈពេលប៉ុន្មានឆ្នាំក្រោយ ជាភ័ព្វសំណាង សុផាន បានរកឃើញរូបថតនោះវិញ ។ សុផាន បាននិយាយថា «នៅថ្ងៃមួយ នៅពេលដែលខ្ញុំកំពុងតែដុតសៀវភៅចាស់ៗចោល ខ្ញុំបានឃើញរូបថតមួយនេះនៅក្នុងសៀវភៅមួយក្បាល» ។

## ប្រវត្តិជីវិតគ្រួសារ

សុផាន មានបងប្អូនចំនួនប្រាំបួននាក់ (ប្រុសបី ស្រីប្រាំមួយ) សុទ្ធតែចូលបម្រើបដិវត្តន៍ ។ សុផាន គឺជាមនុស្សចុងក្រោយនៅក្នុងគ្រួសារដែលចូលបម្រើបដិវត្តន៍កាលពីឆ្នាំ១៩៧៣ ។ ដូចបងប្អូនផ្សេងទៀតដែរ សុផាន បានចូលបម្រើបដិវត្តន៍តាមរយៈ



ញ៉ែម សុផាន ជាមួយមិត្តភក្តិឈ្មោះ គា (ស្តាំ) ក្នុងឆ្នាំ១៩៧៥

បងប្រុសទីពីររបស់គាត់គឺ ញ៉ែម នឿន ដែលបានចូលបម្រើបដិវត្តន៍មុនគេ ហើយបានក្លាយជាលេខាស្រុកសូទ្រនិគមនៅឆ្នាំ១៩៧៤ ។ សុផាន បានចូលបម្រើបដិវត្តន៍ដោយស្ម័គ្រចិត្ត ដើម្បីគេចផុតពីការគំរាមកំហែងគ្រប់បែបយ៉ាងពីទាហាន លន់ នល់ ។ សុផាន បាននិយាយថា «កាលនោះ ទាហាន លន់ នល់ បានចូលវាយលុកភូមិរបស់ខ្ញុំ ហើយបានចាប់រំលោភក្មេងស្រី ហើយអ្នកភូមិក៏មិនហ៊ានតវ៉ាប្រឆាំងដែរ» ។

មិនយូរប៉ុន្មានក្រោយពេលដែល សុផាន ចូលបម្រើបដិវត្តន៍ សុផាន ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅភ្នំដីក្នុងខេត្តកំពង់ធំដោយរស់នៅជាមួយប្រជាជនមូលដ្ឋាន ពីព្រោះ សុផាន មិនត្រូវបានខ្មែរក្រហមជឿទុកចិត្តទាំងស្រុងទេដោយសារតែគាត់ទើបតែមកពីតំបន់ដែលគ្រប់គ្រងដោយ ទាហាន លន់ នល់ ។

នៅឆ្នាំ១៩៧៥ សុផាន បានទៅលេងខេត្តសៀមរាប ព្រោះបងប្រុសរបស់គាត់ឈ្មោះ ញ៉ែម នឿន បានឲ្យនិរសារម្នាក់យកម៉ូតូមកទទួលទៅលេងសៀមរាប ។ សុផាន បាននិយាយថា «ការធ្វើដំណើរត្រូវចំណាយពេលពេញមួយថ្ងៃ ហើយខ្ញុំបានទៅដល់ខេត្តសៀមរាបនៅពេលព្រលប់ ។ ខ្ញុំសប្បាយចិត្តនៅពេលដែលបានជួបបងរបស់ខ្ញុំ ។ គាត់បានថតរូបខ្ញុំមួយប៉ុស្តិ៍ ។ នៅទីនោះ គាត់រស់នៅក្នុងផ្ទះតូចមួយ» ។ ពេលនោះគឺជាពេលចុងក្រោយបង្អស់ដែល សុផាន បានជួបបងប្រុសគាត់ ។

ភ្លាមៗក្រោយពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ញ៉ែម ថុល បងស្រីរបស់ សុផាន ត្រូវបានបញ្ជូនមកឲ្យធ្វើការនៅមន្ទីរពាណិជ្ជកម្មនៅទីក្រុងភ្នំពេញ ដែលមានតួនាទីជាអនុប្រធានផ្នែកនារីមន្ទីរក-១ ខណៈពេលដែលប្តីរបស់គាត់ ឈ្មោះ កែវ ធ្វើការជាមន្ត្រីទូត ។ ថុល បានមកលេងផ្ទះម្តង ហើយក៏បាននាំ សុផាន ទៅខេត្តកំពង់ចាមដើម្បីធ្វើពេទ្យ ហើយក្រោយមកក៏ធ្វើជាពេទ្យធ្មេញ ។ ថុល បានសម្រាកមួយយប់ជាមួយនឹង សុផាន នៅខេត្តកំពង់ចាម ។ ពេលនោះហើយគឺជាពេលដែល ថុល បាននិយាយប្រាប់ សុផាន ពីកិច្ចការរបស់ប្តីគាត់ ។

មានពេលមួយក្នុងឆ្នាំ១៩៧៦ ថុល បាននាំ សុផាន ទៅភ្នំពេញដើម្បីទៅលេងការិយាល័យរបស់ ថុល ដែលស្ថិតនៅក្បែរផ្សារចាស់ ។ សុផាន បានឃើញពីសភាពស្ងាត់ជ្រងំនៅទីក្រុង

ភ្នំពេញ ហើយបាននិយាយថា «ទីក្រុងភ្នំពេញស្ងាត់ជ្រងំ មិនមានមនុស្សច្រើនដូចមុនទេ គឺស្ងាត់ជ្រងំតែម្តង» ។

ចាប់តាំងពីពេលនោះមក សុផាន មិនដែលបានជួបបងស្រីគាត់ម្តងទៀតទេ ហើយក៏មិនដឹងថាបងស្រីគាត់នៅទីណាដែរ ។ ក្រោយមកនៅឆ្នាំ១៩៨១ សុផាន បានមកមើលសារមន្ទីរទួលស្លែង ដើម្បីរកមើលរូបថតរបស់ ថុល និង កែវ តែរកមិនឃើញឡើយ ។ ចាប់តាំពីពេលនោះមក សុផាន បានបាត់បង់នូវក្តីសង្ឃឹមថានឹងដឹងពីជោគវាសនារបស់បងស្រី បងប្រុស និងបងថ្លៃរបស់គាត់ ។


I09091

ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៣ គឺជាថ្ងៃដ៏គួរឲ្យភ្ញាក់ផ្អើលបំផុតមួយសម្រាប់ សុផាន នៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានាំយកប្រវត្តិរូបរបស់ ញ៉ែម ថុល និង ញ៉ែម នឿន ពីមន្ទីរស-២១ ប្រគល់ជូនគាត់ ។ ពេលនោះហើយទើប សុផាន ដឹងថា បងស្រី និងបងប្រុសស្លាប់នៅទួលស្លែង ។

## ប្រវត្តិរូបមន្ទីរស-២១ និងបណ្តាញបោសសម្អាត

យុទ្ធនាការបោសសម្អាតមកលើគ្រួសារ សុផាន បានចាប់ផ្តើមឡើងបន្ទាប់ពីព្រឹត្តិការណ៍ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅពេលដែលមានការវាយប្រហារដ៏តូចមួយកើតឡើងនៅក្រុងសៀមរាប ហើយក្រោយមកមជ្ឈិមបក្សមានការសង្ស័យទៅលើ កុយ ធួន ដែលជាលេខាភូមិភាគឧត្តរ ។ ទីក្រុងសៀមរាបស្ថិតនៅចម្ងាយប្រមាណសែសិបគីឡូម៉ែត្រប៉ុណ្ណោះពីការិយាល័យរបស់ នឿន ក្នុងស្រុកសូទ្រនិគម ។ នឿន និង កុយ ធួន មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នា ។ មិនដល់រយៈពេលពីរខែក្រោយហេតុការណ៍វាយប្រហារនៅសៀមរាបបានផ្ទុះឡើង កុយ ធួន ត្រូវបានកោះហៅមកទីក្រុងភ្នំពេញ និងដកហូតតំណែងដែលជាលេខាភូមិភាគឧត្តរ ហើយត្រូវបានចាត់តាំងឲ្យទទួលបន្ទុកខាងមន្ទីរពាណិជ្ជកម្មវិញ ។

បន្ទាប់មកទៀត នឿន ត្រូវបានចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរស-២១ ។ នៅក្នុងចម្លើយសារភាពចំនួនដប់បួនទំព័រនៅមន្ទីរស-២១ នឿន បានសរសេរថា គាត់កើតនៅឆ្នាំ១៩៣៨ ហើយជាកូនសិស្សរបស់ កុយ ធួន នៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម ក្នុងអំឡុងឆ្នាំ១៩៦២ ។ នោះគឺជាពេលដែល នឿន បានរៀនសូត្រពីមនោគមន៍វិជ្ជាកុម្មុយនីស្ត ហើយបានចូលជាសមាជិកបក្សនៅខែមិថុនា ឆ្នាំ១៩៧០ ។ នឿន ត្រូវបានតែងតាំងជាលេខាស្រុកសូទ្រនិគមក្នុងឆ្នាំ១៩៧៤ ។ ប្រពន្ធរបស់ នឿន ឈ្មោះ រស់ ស៊ីថាត គឺជាកម្មាភិបាលឃុំម្នាក់ដែលទទួលបន្ទុកខាងតម្បាញ ។ ប្រវត្តិរូបនេះបានរៀបរាប់ព័ត៌មានលម្អិតអំពីប្រវត្តិរបស់ នឿន និងបងប្អូន ឪពុកម្តាយរបស់គាត់ និងប្រវត្តិការងារ និងប្រវត្តិគ្រួសាររបស់ ស៊ីថាត ។ ក្រោយពេលដែល នឿន ត្រូវបានចាប់ខ្លួន បងប្អូនប្រុសម្នាក់ឈ្មោះ ញ៉ែម នឿ ក៏ត្រូវបានបញ្ជូនទៅឃុំឃាំងនៅគុកនៅខេត្តសៀមរាបជាមួយនឹង




ឪពុក ។ ជាអកុសល ទៀ មិនបានរួចរស់ជីវិតដូចឪពុករបស់គាត់ទេ ។

ក្រោយមកទៀត ការបោសសម្អាតក៏បានធ្លាក់មកលើ ញ៉ែម ថុល ដែលត្រូវបានចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរស-២១ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅពេលដែលគាត់មានអាយុម្ភៃប្រាំបួនឆ្នាំ ។ កាលនោះ ថុល មានកូនម្នាក់ ។

ចំណែកឯ ជោគវាសនារបស់ កែវ ដែលជាប្តីរបស់ ថុល វិញនៅតែគ្មានដំណឹងដដែល ។ចុងក្រោយ ការបោសសម្អាតចុងបានធ្លាក់មកលើ សុផាន ។ សុផាន ត្រូវបានដកចេញពីតំណែងជាកម្មាភិបាលពេទ្យធ្មេញ ហើយត្រូវបានបញ្ជូនទៅធ្វើការងារដកស្ទូងជាមួយនឹងប្រជាជនផ្សេងៗទៀត ។ សុផាន បានរៀបរាប់ហេតុការណ៍កាលពីថ្ងៃនោះថា “មានថ្ងៃមួយបុរសម្នាក់បានមកប្រាប់ខ្ញុំឲ្យឡើងឡានជាមួយគាត់ ហើយក៏ជិះចេញទៅបាត់ ។ បន្ទាប់មក បុរសនោះប្រាប់ខ្ញុំថា បងប្អូនប្រុសរបស់ខ្ញុំជាជនក្បត់បដិវត្តន៍ ។ ខ្ញុំគិតថា ពេលនោះខ្ញុំប្រាកដជាស្លាប់ហើយ” ។

នៅឆ្នាំ ២០០៨ សុផាន បានដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីខ្មែរក្រហមដើម្បីស្វែងរកយុត្តិធម៌សម្រាប់បងស្រី និងបងប្រុសរបស់គាត់ដែលត្រូវបានសម្លាប់នៅទួលស្លែង ។ សុផាន មានបំណងតែមួយគាត់គឺថា “ខ្ញុំត្រូវការយុត្តិធម៌សម្រាប់បងប្អូនខ្ញុំ” ។

**ញាណ សុជាតិ**


ញ៉ែម សុផាន ក្នុងឆ្នាំ១៩៧៤ នៅខេត្តសៀមរាប

# អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបើក សវនាការស្ដីពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា

**១) សេចក្ដីផ្ដើម ៖**

នៅថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការជាសាធារណៈដើម្បីផ្ដល់ឱកាសឲ្យភាគីទាំងអស់សួរសំណួរទៅសាស្ត្រាចារ្យ ចន ខាំប៊ែល ដែលជាគ្រូពេទ្យជំនាញថែទាំមនុស្សចាស់ទាក់ទងនឹងវិធីសាស្ត្រ និងការសន្និដ្ឋានរបស់លោកស្ដីពីសម្បទាក្នុងការចូលរួមនៅក្នុងសវនាការរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា នៅក្នុងសំណុំរឿង០០២ ។ របៀបវារៈរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានធ្វើការបែងចែកសវនាការជាបីផ្នែកគឺ ទី១) ការសួរដេញដោលដោយភាគីដែលពាក់ព័ន្ធទាំងអស់ទៅសាស្ត្រាចារ្យ ខាំប៊ែល ពីវិធីសាស្ត្រក្នុងការកំណត់សម្បទារបស់ជនជាប់ចោទ ទី២) ការសួរដេញដោលទៅសាស្ត្រាចារ្យ ខាំប៊ែល ទាក់ទងទៅនឹងការរកឃើញជាសំខាន់របស់លោកស្ដីពីសុខភាពរបស់ អៀង ធីរិទ្ធ និង ទី៣) ការសួរដេញដោលទៅលោកសាស្ត្រាចារ្យ ខាំប៊ែល ទាក់ទងទៅនឹងការរកឃើញជាសំខាន់របស់គាត់ស្ដីពីសុខភាពរបស់ជនជាប់ចោទនួន ជា ។

ការសួរដេញដោលទៅលោកសាស្ត្រាចារ្យ ខាំប៊ែល ទាក់ទងទៅនឹងវិធីសាស្ត្រវាយតម្លៃរបស់គាត់បានចំណាយពេលស្មើរមួយថ្ងៃនៃសវនាការក្នុងថ្ងៃទីមួយ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល ត្រូវបានសួរជាដំបូងដោយចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ។ យោងតាមការសួររបស់ចៅក្រម ខាតវ៉្រាយត៍ បានបង្ហាញយ៉ាងច្បាស់ថា សាស្ត្រាចារ្យ ខាំប៊ែល ត្រូវបានគេចាត់ទុកថាមានជំនាញវិជ្ជាជីវៈខ្ពស់ទាក់ទងទៅនឹងមុខជំនាញរបស់គាត់ និងមាន



និស្សិតសាកលវិទ្យាល័យទទួលទទួលឯកសារ

បទពិសោធន៍ព្យាបាលយ៉ាងទូលំទូលាយ នៅក្នុងមុខជំនាញវិជ្ជាជីវៈថែទាំជំងឺមនុស្សចាស់ ។ លោកសាស្ត្រាចារ្យ ឌាំបែល បានពន្យល់ផងដែរពីប្រភពដែលគាត់បានយកមកពិភាក្សាមុនពេលឈានទៅដល់ការកំណត់ពីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា ។ នៅជិតបញ្ចប់សវនាការ មានភស្តុតាងបង្ហាញថា សាស្ត្រាចារ្យ ឌាំបែល មានក្តីបារម្ភយ៉ាងខ្លាំងអំពីសម្បទាផ្នែកស្មារតីរបស់ អៀង ធីរិទ្ធ ដូចដែលសាស្ត្រាចារ្យ ឌាំបែល បានបង្ហាញសង្ខេបពីការធ្វើកោសល្យពិច័យពីភាពធ្ងន់ធ្ងរនៃដំណើរការបញ្ញាស្មារតី និងបានធ្វើនូវជំហ៊ានផ្សេងៗទៀត ដើម្បីធ្វើឲ្យប្រសើរឡើងនូវរូបភាពនៃប្រវត្តិសុខភាពផ្លូវចិត្តរបស់ អៀង ធីរិទ្ធ ដែលវិធានការទាំងនេះលោកសាស្ត្រាចារ្យយល់ឃើញថាមិនចាំបាច់ប្រើក្នុងពេលវាយតម្លៃសម្បទារបស់ នួន ជា ។

## ២) សម្បទារបស់ អៀង ធីរិទ្ធ ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់

### ក) បញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ

សំណួរជាច្រើនបានចោទទៅលោកសាស្ត្រាចារ្យ ឌាំបែល ដោយក្រុមមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ បញ្ជាក់ពីចម្ងល់ចំពោះសាស្ត្រាចារ្យ ឌាំបែល ដែលបានសន្និដ្ឋាននៅក្នុងរបាយការណ៍ពិនិត្យសុខភាពដែលរបាយការណ៍នេះនៅតែរក្សាជាការសម្ងាត់មកដល់បច្ចុប្បន្នដោយញ្ជាក់ថា អៀង ធីរិទ្ធ អាចនឹងមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការនីតិវិធី ។ មេធាវីការពារក្តីឲ្យ អៀង ធីរិទ្ធ នៅក្នុងសារណាថ្មីៗ និងនៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈបានផ្តល់នូវភាពច្បាស់លាស់ដែលកំពុងស្ថិតក្រោមការសន្មតថា អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការដោយផ្អែកទៅលើបញ្ហាស្មារតី ។ ច្បាស់ណាស់ថាមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង ធីរិទ្ធ មានការយល់ស្របទាំងស្រុងចំពោះការរកឃើញរបស់អ្នកជំនាញលោកសាស្ត្រាចារ្យ ឌាំបែល ដូចដែលមេធាវីបានសួរទៅលោកសាស្ត្រាចារ្យនៅក្នុងលក្ខណៈមួយដែលសង្កត់ធ្ងន់ទៅលើពីភាពជំនាញ និងបទពិសោធន៍របស់លោក ហើយជាទូទៅគឺសួរសំណួរក្នុងបំណងបង្កើតនូវភាពជឿទុកចិត្តចំពោះសមត្ថភាពរបស់លោកសាស្ត្រាចារ្យ ។

អំឡុងពេលដំណាក់កាលដំបូងនៃការចោទសួរដែលកំណត់ត្រឹមតែវិធីសាស្ត្រនោះ សហមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ បានបង្វែរទៅរកចំណុចមួយនៅក្នុងបញ្ហាសំខាន់នៃការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ ឌាំបែល ។ នៅក្នុងពេលផ្លាស់ប្តូនោះ លោកសាស្ត្រាចារ្យ ឌាំបែល បានយល់ស្របទៅនឹងប្រយោគដែលលើកឡើងដោយមេធាវីការពារក្តីថា លោកសាស្ត្រាចារ្យបានវិនិច្ឆ័យរោគឲ្យ អៀង ធីរិទ្ធ នៅពេលដែលជនជាប់ចោទរូបនេះកំពុងទទួលរងនូវការចុះខ្សោយបញ្ញាស្មារតី ដែលភាគច្រើនស្រដៀងទៅនឹងជំងឺវង្វេងវង្វាន់ ។ ការបង្ហាញនេះគឺជាកម្រិតមួយនៃការស្ទាបស្ទង់ជាសាធារណៈក្នុងខែនីមួយៗ និងពាក្យចចាមអារ៉ាមដែលកំពុងតែព្រួយបារម្ភចំពោះសុខភាពផ្លូវចិត្តរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និងប្រាកដជាមានផលប៉ះពាល់ចម្បងមួយទៅលើដំណើរការនីតិវិធីនៅក្នុងករណី០០២ ដូចជារោគវិនិច្ឆ័យនោះបង្កឲ្យមានមន្ទិលសង្ស័យទៅដល់សម្បទាជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ។ ទាក់ទងនឹងការបង្ហាញជាចម្បងនេះ សំណួរនៅតែបន្តសួរ ហើយលោកសាស្ត្រាចារ្យ ឌាំបែល បានលើកឡើងថា អៀង ធីរិទ្ធ បានបរាជ័យចំពោះការធ្វើពិសោធន៍ផ្នែកស្មារតីយល់ដឹងចំនួនពីរដងរួចមកហើយ ដោយចង្អុលបង្ហាញសញ្ញាណផ្សេងៗនៃការចុះខ្សោយបញ្ញាស្មារតី និងការថតនៃដំណើរការខួរក្បាលដែលកាន់តែមានសភាពខ្សោយទៅៗរបស់ អៀង ធីរិទ្ធ ។ កត្តាទាំងអស់នេះបានរួមចំណែកដល់ការវិនិច្ឆ័យចុងក្រោយរបស់លោកសាស្ត្រាចារ្យ ឌាំបែល ។

ការណែនាំដំបូងនៅក្នុងការវិនិច្ឆ័យពេញលេញរបស់លោកសាស្ត្រាចារ្យ ឌាំបែល ក្រោយមកមានភាពជាក់លាក់ ខណៈពេលដែលជាដំណាក់កាលសំខាន់នៃការសាកសួរអំពីសុខភាពជនជាប់ចោទ អៀង ធីរិទ្ធ ។ ស្ថិតក្នុងដំណាក់កាលនេះ លោកសាស្ត្រាចារ្យ ឌាំបែល បានពន្យល់អំពីការវិនិច្ឆ័យរបស់ខ្លួនគាត់ទៅលើជនជាប់ចោទ អៀង ធីរិទ្ធ កាន់តែពេញលេញថែមទៀត ។ តាមរយៈសំណួរ លោកសាស្ត្រាចារ្យ ឌាំបែល បានមានប្រសាសន៍ថា ការវិនិច្ឆ័យរោគដែលលោកធ្វើនេះ គឺជនជាប់ចោទ អៀង ធីរិទ្ធ ទទួលរងពី «ជំងឺវិកលចរិតមធ្យមទៅធ្ងន់ធ្ងរ» ស្ទើតែកំណត់បានថាជាជំងឺវង្វេងវង្វាន់ ដែលជាស្ថានភាព «រ៉ាំរ៉ៃជាលំដាប់» ។ លោកសាស្ត្រាចារ្យ ឌាំបែល ពន្យល់បន្ថែមទៀតថា នៅក្នុងគំនិតរបស់លោកស្ថានភាពរបស់ អៀង ធីរិទ្ធ បង្កើតជា «សញ្ញា» មួយនៃ

ការចុះខ្សោយនូវភាពយល់ដឹងនៅក្នុងទំនាក់ទំនងការងារមួយ ហើយលោកសាស្ត្រាចារ្យ ខាំប៊ែល មានមន្ទិលសង្ស័យថា ការរួមបញ្ចូលខ្លះនៃការព្យាបាលមួយចំនួននឹងក្លាយជាលទ្ធផល "ចាំបាច់នៃការធ្វើឲ្យប្រសើរឡើង" ។ នៅពេលដែលរៀបរាប់ពីការធ្វើបទសម្ភាសន៍ជាមួយ អៀង ធីរិទ្ធ លោកសាស្ត្រាចារ្យ ខាំប៊ែល បានមានប្រសាសន៍ថា ជនជាប់ចោទ អៀង ធីរិទ្ធ មានការ "ភ្លេចភ្លាំងនិងច្រឡំ" នៅពេលដែលសួរអំពីព័ត៌មានមួយចំនួនទាក់ទងនឹងប្រវត្តិផ្ទាល់ខ្លួន ដូចជាសំណួរអំពីពេលដែលជនជាប់ចោទរូបនេះសិក្សានៅប្រទេសបារាំង ។ លោកសាស្ត្រាចារ្យ ខាំប៊ែល បានចង្អុលបង្ហាញផងដែរថា តាមរយៈការវាយតម្លៃរបស់លោកចំពោះជនជាប់ចោទ អៀង ធីរិទ្ធ លោក "មានការបារម្ភ" អំពីលទ្ធភាពដែល អៀង ធីរិទ្ធ បានមានបំណងពន្លាតពីភាពលំបាកខាងផ្នែកស្មារតីជ្រុលហួសហេតុ ហើយលោក "មិនបានរកឃើញថា អៀង ធីរិទ្ធ អាចព្យាយាមបោកបញ្ឆោតលោកទេ" ។ សវនាការថ្ងៃទីមួយបញ្ចប់នៅមុនពេលដែលមេធាវីការពារឲ្យជនជាប់ចោទ អៀង ធីរិទ្ធ បញ្ចប់សំណួរទៅលោកសាស្ត្រាចារ្យ ខាំប៊ែល ។


លោកសាស្ត្រាចារ្យ ចន ខាំប៊ែល (រូបថត : អ.វ.ត.ក)

## ១) មតិយោបល់របស់លោកសាស្ត្រាចារ្យ ខាំប៊ែល ចំពោះសមត្ថភាពផ្នែកបញ្ញារបស់ជនជាប់ចោទ អៀង ធីរិទ្ធ

បន្ទាប់ពីការបង្ហាញអស់រយៈពេលប៉ុន្មានថ្ងៃទាក់ទងទៅនឹងការកើតមានបញ្ហាវង្វេងវង្វាន់ស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ រួចមក លោកសាស្ត្រាចារ្យ ខាំប៊ែល បានរៀបរាប់លម្អិតពីមូលហេតុដែលនាំឲ្យលោកសាស្ត្រាចារ្យឈានទៅដល់ការវាយតម្លៃបែបនេះ និងពន្យល់ពីការចាប់អារម្មណ៍របស់លោកចំពោះភាពជាក់លាក់នៃសមត្ថភាពផ្នែកបញ្ញារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល បានផ្តល់សក្ខីកម្មថា នៅអំឡុងពេលនៃការធ្វើកោសល្យវិច័យរបស់លោក លោកឃើញថា ជនជាប់ចោទ អៀង ធីរិទ្ធ បាននិយាយទៅកាន់ខ្លួនឯងទាក់ទងទៅនឹងរឿងកាលពីអតីតកាល និងយុវភាពរបស់ខ្លួន ជារួមនិយាយគឺផ្តោតទៅលើបញ្ហាទាំងឡាយផ្សេងៗដែលមិនមានការជាប់ពាក់ព័ន្ធ ហើយជនជាប់ចោទក៏មិនបានចងចាំថាខ្លួនមានកូនប៉ុន្មាននាក់ រួមទាំងព័ត៌មានផ្ទាល់ខ្លួនមួយចំនួនផ្សេងទៀតក៏ជនជាប់ចោទមិនអាចចងចាំបានដែរ ។ នៅពេលខ្លះ ជនជាប់ចោទ អៀង ធីរិទ្ធ មិនទាំងដឹងថាខ្លួនកំពុងនៅកន្លែងណា និងវង្វេងផ្លូវ សូម្បីតែនៅកន្លែងដែលមានទំហំតូច និងសាមញ្ញដូចជានៅក្នុងបរិវេណបន្ទប់ឃុំឃាំងក៏ដោយ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល ថែមទាំងបានលើកឡើងពីបទសម្ភាសន៍របស់លោកជាមួយនឹងស្វាមីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺជនជាប់ចោទ អៀង សារី ។ អៀង សារី បានប្រាប់លោកសាស្ត្រាចារ្យ ខាំប៊ែល ថា ឥរិយាបថរបស់ អៀង ធីរិទ្ធ "មានការផ្លាស់ប្តូរយ៉ាងខ្លាំង" ។ អៀង ធីរិទ្ធ បានភ្លេចអស់នូវរឿងរ៉ាវកាលពីពេលមុន ដូចជារឿងដែលបងស្រីនិងឪពុកម្តាយរបស់ខ្លួនបានស្លាប់ទៅហើយនោះ ទោះបីជាមានការរំឭកពី អៀង សារី ចំពោះព្រឹត្តិការណ៍ទាំងនោះក៏ដោយ ។ ហើយឥឡូវ អៀង ធីរិទ្ធ ជាញឹកញាប់តែងមានអារម្មណ៍ឆាប់ខឹងសម្បា ដោយសារតែការដែលរស់នៅក្នុងស្ថានភាពឯកោ ។

ខាងភាគីមេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ បានសួរពីមតិយោបល់របស់លោកសាស្ត្រាចារ្យ ខាំប៊ែល ស្តីអំពីរបាយការណ៍សុខភាពដែលបានមកពីមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ ។ មុនដំបូង អង្គជំនុំជម្រះបានអនុញ្ញាតឲ្យមានការបង្ហាញរបាយការណ៍សុខភាពមួយនៅលើកញ្ចក់អេក្រង់ទូរទស្សន៍របស់អង្គជំនុំជម្រះ ប៉ុន្តែក្រោយមកអង្គជំនុំជម្រះបានសម្រេចថា ឯកសារនោះមិនត្រូវបង្ហាញជាសាធារណៈឡើយ ដោយសារតែនៅក្នុងឯកសារនោះមានព័ត៌មានសម្ងាត់ ។ ឯកសារនោះបានបង្ហាញពីរឿងរ៉ាវ

ជាច្រើននៅក្នុងមន្ទីរឃុំឃាំងនៅអំឡុងពេលដែលជនជាប់ចោទ អៀង ធីរិទ្ធ ស្រែកជេរដោយពាក្យសម្តីទៅលើអនុរក្សមន្ទីរឃុំឃាំង និងជនជាប់ចោទ នួន ជា ។

បន្ទាប់មក ខាងភាគីមេធាវីការពារក្តីបានសួរនូវសំណួរជាច្រើនដែលទាញចេញពីបទដ្ឋានអន្តរជាតិទាក់ទងទៅនឹងបញ្ហាសម្បទារបស់ជនជាប់ចោទ ដោយលើកឡើងពីសំណុំរឿងករណីថ្មីមួយរវាងរដ្ឋអាជ្ញា និង ស្រ្ទូហ្គា នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ ការធ្វើពិសោធទៅលើកាយសម្បទាតាមបទដ្ឋានដែលមាននៅក្នុងករណី ស្រ្ទូហ្គា គឺដើម្បីធានាថា ជនជាប់ចោទអាចអនុវត្តដោយប្រសិទ្ធភាពនូវសិទ្ធិស្មើភាពគ្នាចំពោះមុខសវនាការរបស់ខ្លួន ។ ដើម្បីធ្វើឲ្យមានការធានាដូច្នេះ ការធ្វើពិសោធន៍ទៅលើរូប ស្រ្ទូហ្គា បានរាប់បញ្ចូលនូវសមត្ថភាពចំបាច់ចំនួនប្រាំពីរចំណុចដែលជនជាប់ចោទអាចធ្វើបានដោយរាប់បញ្ចូលសមត្ថភាព ៖

១) អាចដាក់ពាក្យបណ្តឹង

២) អាចយល់ដឹងពីបទល្មើសដែលចោទប្រកាន់មកលើខ្លួន

៣) អាចយល់ដឹងពីនីតិវិធីនៅក្នុងតុលាការ

៤) អាចយល់ដឹងលម្អិតពីភ័ស្តុតាង

៥) អាចទាក់ទងជាមួយមេធាវីការពារក្តីរបស់ខ្លួន

៦) អាចយល់ពីផលវិបាកដែលបណ្តាលមកពីសាលក្រម

៧) អាចធ្វើសក្ខីកម្មបាន

ខាងភាគីមេធាវីការពារក្តីឲ្យជនជាប់ចោទបានស្នើទៅលោកសាស្ត្រាចារ្យ ខាំបែល ឲ្យបញ្ចេញនូវមតិយោបល់ផ្ទាល់ខ្លួនរបស់លោកទាក់ទងទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ ថាតើជនជាប់ចោទបច្ចុប្បន្ននេះអាចយល់ពី «បទល្មើសដែលគេចោទមកលើខ្លួន» និង «ទស្សនៈនៃការមាន និងគ្មានទោស» ដែលឬទេ ។ ជាការឆ្លើយតប លោកសាស្ត្រាចារ្យ ខាំបែល បានលើកឡើងថា ជនជាប់ចោទ អៀង ធីរិទ្ធ នឹងមានការលំបាកក្នុងការយល់ពីដំណើរការរបស់តុលាការ ។ នៅពេលសួរថាតើជនជាប់ចោទ អៀង ធីរិទ្ធ នៅពេលសព្វថ្ងៃនេះអាចយល់ពីភ័ស្តុតាង និងធ្វើការតទល់ជាមួយនឹងការផ្តល់សក្ខីកម្មរបស់សាក្សីបានដែរឬទេ លោកសាស្ត្រាចារ្យ ខាំបែល បានអះអាងថា ជនជាប់ចោទមានការពិបាកនឹងធ្វើដូច្នេះណាស់ ។ លោកសាស្ត្រាចារ្យបន្តទៀតថា ជនជាប់ចោទ អៀង ធីរិទ្ធ នឹងមានការលំបាកកាន់តែខ្លាំងក្នុងការផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ នៅមុនពេលបញ្ចប់ សហមេធាវីរបស់ជនជាប់ចោទបានសួរទៅលោកសាស្ត្រាចារ្យ ខាំបែល ថាតើលោកសាស្ត្រាចារ្យចាត់ទុកបញ្ហាប្រឈមមុខរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការធ្វើការទំនាក់ទំនងជាមួយមេធាវីរបស់ខ្លួនជារឿងលំបាកដែរឬទេ ។ លោកសាស្ត្រាចារ្យ ខាំបែល បានឆ្លើយតបថា «ស្ថានភាពរបស់ អៀង ធីរិទ្ធ នៅពេលបច្ចុប្បន្ននេះ ខ្ញុំជឿថាវាពិតជារឿងលំបាកមែនសម្រាប់ជនជាប់ចោទរូបនេះ» ។

បន្ទាប់ពីធ្វើការចង្អុលបង្ហាញយ៉ាងច្បាស់តាមមតិយោបល់ផ្ទាល់របស់លោកសាស្ត្រាចារ្យ ខាំបែល បានឲ្យដឹងថា នៅក្នុងពេលបច្ចុប្បន្ន ជនជាប់ចោទ អៀង ធីរិទ្ធ ពិតជាមិនអាចអនុវត្តមុខនាទីចាំបាច់ចំពោះការយល់ដឹងជាមូលដ្ឋានដើម្បីធ្វើឲ្យឃើញថាជនជាប់ចោទមានសម្បទាក្នុងការចូលរួមក្នុងសវនាការរួចមក សហមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានសួរពីលទ្ធភាពក្នុងការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នៅពេលខាងមុខ ។ ក្រោយពីការសួរសំណួរលោកសាស្ត្រាចារ្យ ខាំបែល បានអះអាងថា ស្ថានភាពរបស់ អៀង ធីរិទ្ធ នាពេលនេះបានបង្ហាញថា មិនមានការវិវឌ្ឍទៅរកភាពល្អប្រសើរឡើយ បន្ទាប់ពីមានការដកចេញនូវថ្នាំពីរប្រភេទក្នុងចំណោមថ្នាំបីប្រភេទដែលអាចជះឥទ្ធិពលដល់ការចងចាំដែលជនជាប់ចោទធ្លាប់បានប្រើប្រាស់កាលពីពេលមុន ។ បន្ថែមពីលើនេះ លោកសាស្ត្រាចារ្យ ខាំបែល គិតថា ការផ្លាស់ប្តូររបបថ្នាំរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នឹងអាចធ្វើឲ្យមានការវិវឌ្ឍប្រសើរឡើងចំពោះស្ថានភាពបញ្ញាស្មារតីរបស់ជាប់ចោទរូបនេះ ។ លោកសាស្ត្រាចារ្យ ខាំបែល បានផ្តល់អនុសាសន៍ឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ជ្រើសរើសថ្នាំដែលជួយធ្វើឲ្យប្រសើរឡើងចំពោះរោគសញ្ញាជំងឺវង្វេងវង្វាន់បានប្រមាណជា៣០ភាគរយនៃអ្នកជំងឺ ។ ប្រសិនបើជនជាប់ចោទ អៀង ធីរិទ្ធ មានការឆ្លើយតបជាវិជ្ជមានចំពោះការព្យាបាលប្រភេទនេះ វានឹងអាចបន្ថយការប្រឈមមុខចំពោះផ្នែកបញ្ញាស្មារតីរបស់ជនជាប់ចោទរូបនេះ ប៉ុន្តែទោះបីជាយ៉ាងណា ភាពល្អប្រសើរនេះគ្រាន់តែស្ថិតនៅជាបណ្តោះអាសន្ន

ប៉ុណ្ណោះ ហើយថ្នាំទាំងនោះមិនអាចទប់ស្កាត់ដំណើរការទាំងមូលនៃជំងឺវង្វេងវង្វាន់ស្មារតីនេះបានឡើយ ។

បន្ទាប់ពីការសួរសំណួររបស់ភាគីមេធាវីការពារក្តីរបស់ជនជាប់ចោទ ភាគីសហព្រះរាជអាជ្ញានិងភាគីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឱកាសឲ្យចោទជាសំណួរទៅលោកសាស្ត្រាចារ្យ ខាំប៊ែល ។ ទាំងភាគីសហព្រះរាជអាជ្ញា និងភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីហាក់បីដូចជាមានការយល់ស្របទៅនឹងការសន្និដ្ឋានរបស់លោក ខាំប៊ែល ទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ ភាគីទាំងពីរនេះមិនបានសួរសំណួរដែលមានលក្ខណៈយល់ស្របទាំងស្រុងចំពោះការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យឡើយ សហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរនូវសំណួរតាមរបៀបជាការស្នើសុំទៅលោក ខាំប៊ែល ឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់ពីវិធីសាស្ត្រទាំងឡាយដែលលោកសាស្ត្រាចារ្យបានប្រើប្រាស់ក្នុងការវាយតម្លៃទៅលើកាយសម្បទានិងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ នៅក្នុងជំហរដែលមានភាពស្របគ្នារបស់ភាគីសហព្រះរាជអាជ្ញា និងភាគីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ភាគីទាំងពីរនឹងមិនជំទាស់ដាច់ខាតចំពោះការដែលរកឃើញថាជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាក្នុងការចូលរួមនៅក្នុងសវនាការនាពេលបច្ចុប្បន្ននោះទេ ។

### ក) លទ្ធភាពពាក់ព័ន្ធដែលអាចកើតមានពីការវិនិច្ឆ័យរោគវង្វេងវង្វាន់របស់ អៀង ធីរិទ្ធ

ការធ្វើសក្ខីកម្មដែលចេញមកពីលោកសាស្ត្រាចារ្យ ខាំប៊ែល បានធ្វើឲ្យមានភាពច្បាស់លាស់ថាលោកជឿជាក់ទៅលើការវិនិច្ឆ័យរបស់ខ្លួនថា ជនជាប់ចោទ អៀង ធីរិទ្ធ ទទួលរងជំងឺវង្វេងវង្វាន់ ។ លើសពីនេះទៅទៀត វាក៏បានក្លាយទៅជាភស្តុតាងសម្រាប់គំនិតដែលប្រកបដោយវិជ្ជាជីវៈរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល ដែលថាជំងឺរបស់ជនជាប់ចោទ អៀង ធីរិទ្ធ មានសភាពធ្ងន់ធ្ងរទៅៗ ហើយដល់ចំណុចមួយដែលជនជាប់ចោទរូបនេះមិនអាចចូលរួមយ៉ាងសំខាន់នៅក្នុងការការពារខ្លួននោះ ។ ការធ្វើការវិនិច្ឆ័យទាំងនេះមានភាពជាក់ពិតយ៉ាងខ្លាំងដល់សម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ យោងតាមយោបល់ដែលបានផ្តល់ឲ្យដោយលោកសាស្ត្រាចារ្យ ខាំប៊ែល ស្ថានភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ សព្វថ្ងៃរារាំងជនជាប់ចោទរូបនេះពីលទ្ធភាពដែលអាចទទួលបានខ្ពស់បំផុត ប្រសិនបើករណីទាំងអស់នៅ ស្ទួហ្កា មិនទាមទារឲ្យមានសម្បទា ។ ឧទាហរណ៍ បញ្ហាចងចាំរបស់ជនជាប់ចោទ អៀង ធីរិទ្ធ អាចបន្ថយលទ្ធភាពទាំងពីររបស់គាត់ក្នុងការយល់ដឹងទាំងភស្តុតាង និងសក្ខីកម្ម ។

ដូចជាអវត្តមានចំពោះការងាកចេញពីការវិនិច្ឆ័យរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល នៅក្នុងការវាយតម្លៃពីអ្នកជំនាញបន្ទាប់ គឺ អៀង ធីរិទ្ធ បង្ហាញខ្លួននៅពេលនេះត្រូវបានសន្មតថា


អៀង ធីរិទ្ធ (រូបថត ៖ អ.វ.ត.ក)

មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ លើសពីនេះទៅទៀត ដូចដែលការវង្វេងវង្វាន់ គឺជាជំងឺដែលមានសភាពអន់ថយទៅៗ ដែលមិនអាចព្យាបាលបាន វាបានលេចឡើងយ៉ាងខ្លាំងបំផុតដែល អៀង ធីរិទ្ធ ដូចជាមិនអាចស្តារឡើងវិញនូវសម្បទារបស់ខ្លួនចំពោះការព្យាបាលនោះឡើយ ។ ដូច្នេះ ជនជាប់ចោទ អៀង ធីរិទ្ធ អាចមានលទ្ធភាពនៅរស់បានច្រើនឆ្នាំទៀតក្នុងស្ថានភាពគ្មានសម្បទាគ្រប់គ្រាន់ ប្រសិនបើសម្បទារបស់គាត់ត្រូវបានគេរកឃើញបច្ចុប្បន្នថាមានភាពល្អប្រសើរដូចលោកសាស្ត្រាចារ្យបានថ្លែងថា អៀង ធីរិទ្ធ មិនមាន «បញ្ហាកាយសម្បទាជាក់លាក់» មិនដូច្នោះគាត់អាចការពារខ្លួនពីវត្តមាននៅក្នុងតុលាការ ។

## ៣) នួន ជា ទំនងជាមានសម្បទាគ្រប់គ្រាន់ ប៉ុន្តែស្នើសុំការវាយតម្លៃបន្ថែម

### ក) បញ្ហាសុខភាពរបស់ជនជាបចោទ នួន ជា

ខណៈពេលដែលសារធារណជនកំពុងតែផ្តោតការយកចិត្តទុកដាក់ទៅលើការប្រកាសថា ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានធ្វើការវិនិច្ឆ័យលើជំងឺវង្វេងវង្វាន់ ព័ត៌មានពាក់ពន្ធ័ទៅនឹងសម្បទារបស់ជនជាប់ចោទ និងឥរិយាបថរបស់ក្រុមមេធាវីការពារក្តីរបស់គាត់ចំពោះបញ្ហានេះត្រូវបានបង្ហាញឡើង ។ ផ្ទុយគ្នាពីមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ មេធាវីការពារក្តីរបស់ នួន ជា បានសួរសំណួរទៅកាន់លោកសាស្ត្រាចារ្យ ខាំប៉ែល ក្នុងលក្ខណៈមួយដែលរំលេចឲ្យឃើញពីចេតនាក្នុងការច្រានចោលមតិយោបល់របស់លោកសាស្ត្រាចារ្យទៅលើសម្បទារបស់ជនជាប់ចោទ នួនជា ហើយមេធាវីការពារក្តីថែមទាំងបានយោងទៅលើនីតិវិធីនៃការសួរ «សំណួរឆ្លង» ពីរទៅបីដង ។ ឥរិយាបថនេះគឺជាលទ្ធផលដែលមេធាវីការពារក្តីមិនយល់ស្របតាមការយល់ឃើញរបស់លោកសាស្ត្រាចារ្យថា នួន ជា គឺមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការ ហើយក៏មិនមានការដាក់កំហិតណាមួយដែលអាចនឹងរារាំងដល់សមត្ថភាពរបស់ជនជាប់ចោទក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនដែរ ។

បន្ទាប់ពីការសួរសំណួរដោយសង្ខេបទៅកាន់លោកសាស្ត្រាចារ្យ ខាំប៉ែល ដោយមេធាវីការពារក្តីទៅលើវិធីសាស្ត្រនៅក្នុងថ្ងៃដំបូងនៃសវនាការ ជនជាប់ចោទ នួន ជា បានលើកឡើង និងបាននិយាយដោយផ្ទាល់នៅក្នុងអំឡុងពេលសវនាការពេលព្រឹកមុនពេលដល់ខ្លួនថយទៅកាន់បន្ទប់ឃុំឃាំងសម្រាប់មួយថ្ងៃ ។ ជនជាប់ចោទ នួន ជា បានទាមទារថា ខ្លួនមានបំណងចូលរួមគ្រប់នីតិវិធីទាំងអស់នៃសវនាការក្នុងសំណុំរឿងរបស់ខ្លួន ដរាបណាសុខភាពរបស់ខ្លួនអនុញ្ញាត ។ ក៏ប៉ុន្តែ ជនជាប់ចោទបានលើកឡើងថា សុខភាពរបស់ខ្លួនទ្រុឌទ្រោម ហើយវាកាន់តែយ៉ាប់យ៉ឺនឡើងៗ ហើយនៅពេលបច្ចុប្បន្ននេះ ខ្លួនមិនអាចអង្គុយបាន ហើយផ្ចង់អារម្មណ៍បានតែរយៈពេលមួយម៉ោងកន្លះ ។ ជនជប់ចោទបានលើកឡើងថា បន្ទាប់ពីរយៈពេលនេះ ភ្នែករបស់គាត់ចាប់ផ្តើមស្រវាំង ហើយខ្លួនចាប់ផ្តើមអស់កម្លាំង ហើយត្រូវតែសម្រាក ។ ជនជាប់ចោទ នួន ជា បានទាមទារទៀតថា ខ្លួនមិនមានសមត្ថភាពដើម្បីផ្ចង់អារម្មណ៍នៅក្នុងសវនាការលើសពីរយៈពេលមួយម៉ោងកន្លះនោះទេ ហើយវាក៏មិនបានធ្វើឲ្យប្រសើរដែរចំពោះការដកខ្លួនទៅកាន់បន្ទប់រង់ចាំ ដែលជាកន្លែងដែលអាចសម្រាក ហើយអាចមើលនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍ ។ ជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានដោយស្នើសុំការវាយតម្លៃផ្សេងទៀត ដោយអ្នកជំនាញដែលអាចផ្តល់ការណែនាំជាពិសេសទាក់ទងទៅនឹងការលំបាកដោយការអស់កម្លាំង និងសម្បទារបស់ជនជាប់ចោទ ។

នៅពេលដែលការសួរសំណួរបានបន្ត មេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា បានលើកយកនូវចំណុចសំខាន់ពីរដែលមានភាពខ្វះខាតត្រូវបានសង្កេតឃើញនៅក្នុងចំណោមបទពិសោធន៍ដ៏ទូលំទូលាយ និងគុណវឌ្ឍរបស់លោកសាស្ត្រាចារ្យ ។ ទីមួយ មេធាវីការពារក្តីឲ្យជនជាប់ចោទផ្តោតទៅលើអង្គហេតុដែលលោកសាស្ត្រាចារ្យ ខាំប៉ែល មិនដែលធ្វើជាអ្នកជំនាញប្រឹក្សាលើសម្បទារបស់បុគ្គលណាម្នាក់នៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះទេ ថ្វីបើបទពិសោធន៍ដ៏ទូលំទូលាយរបស់គាត់មាននៅក្នុងនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។ ទីពីរ ក្រុមមេធាវីការពាក្តីបានចោទសួរសំណួរលោកសាស្ត្រាចារ្យចំពោះបញ្ហាជំនាញពិសេសរបស់លោកក្នុងផ្នែក «ផ្ចង់អារម្មណ៍» របស់អ្នកជំងឺ ។ តាមរយៈការចោទសួររបស់មេធាវីការពារក្តីទៅកាន់លោកសាស្ត្រាចារ្យ ខាំប៉ែល លើប្រធានបទវិធីសាស្ត្ររបស់លោក បញ្ហាសម្បទារបស់ជនជាប់ចោទ នួន ជា

មិនត្រូវបានលើកឡើងម្តងទៀតទេ រហូតដល់នីតិវិធីសវនាការនៅថ្ងៃទីពីរក្រោយពីការបញ្ចប់ការសួរសំណួរលើបញ្ហាសុខភាពសំខាន់របស់ជនជាប់ចោទ អៀង ធីរិទ្ធ ។

នៅក្នុងកិច្ចបន្តនេះ មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា បានធ្វើការស្នើសុំជាបឋមមួយថា សារសំខាន់នៃការសួរសំណួរទៅលើប្រធានបទនៃការរកឃើញរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល ពាក់ពន្ធ័ទៅ នឹងសុខភាពរបស់ជនជាប់ចោទ នួន ជា ត្រូវធ្វើឡើងនៅក្នុងសវនាការជាសម្ងាត់ដើម្បីការពារផលប្រយោជន៍ជាឯកជនចំពោះព័ត៌មានពីការពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ។ ការស្នើសុំនេះត្រូវបានជំទាស់ដោយតំណាងអយ្យការនិងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញពីការសន្មតទុកជាមុននូវសវនាការជាសាធារណៈ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ប្រជាជនកម្ពុជាក្នុងរឿងសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមក្នុងសវនាការ ។ អង្គជំនុំជម្រះបានពិភាក្សាសម្រេច និងបដិសេធចោលការស្នើសុំរបស់មេធាវីការពារក្តី ក៏ប៉ុន្តែអង្គជំនុំជម្រះបានលើកឡើងថា មិនមានឯកសារសម្ងាត់ណាមួយនឹងត្រូវបានបង្ហាញជាសាធារណៈនៅក្នុងអំឡុងពេលសវនាការនោះទេ ជាពិសេសរបាយការណ៍លើសុខភាពរបស់ជនជាប់ចោទ នួន ជា នឹងត្រូវបានពិភាក្សាតែក្នុងលក្ខណៈទូទៅតែប៉ុណ្ណោះ ដើម្បីការពារផលប្រយោជន៍ឯកជនរបស់ជនជាប់ចោទ ។

ចៅក្រម ខាតព្រ៊ាយត៍ បានសួរទៅកាន់លោកសាស្ត្រាចារ្យ ខាំប៊ែល លើការវាយតម្លៃរបស់លោកលើសុខភាពរបស់ជនជាប់ចោទ នួន ជា ជាមុនសិន ។ អំឡុងពេលនៃការសួរសំណួរនេះ លោកសាស្ត្រាចារ្យ ខាំប៊ែល បានឆ្លើយម្តងទៀតថា គាត់មិនមានការព្រួយបារម្ភពិសេសចំពោះសម្បទាក្នុងការចូលរួមក្នុងសវនាការរបស់ជនជាប់ចោទ នួន ជា នោះទេ និងបានផ្តល់នូវហេតុផលជាមូលដ្ឋានយ៉ាងល្អិតល្អន់ក្នុងការយល់ឃើញនេះ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល ក៏បានផ្តល់នូវបញ្ជីជំងឺដែលជនជាប់ចោទ នួន ជា ទទួលរងកន្លងមក និងជំងឺដែលកំពុងទទួលរងក្នុងពេលបច្ចុប្បន្ន ។ ប្រធានបទនៃការចាប់អារម្មណ៍គឺជំងឺដាច់សសៃឈាមខួរក្បាលដែលជនជាប់ចោទ នួន ជា បានទទួលរងនៅក្នុងឆ្នាំ១៩៩៥ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល បានពន្យល់ថា រាល់ភ័ស្តុតាងទាំងអស់បានឲ្យជាគំនិតថាជំងឺដាច់សសៃឈាមខួរក្បាលនោះគឺតិចតួច ទោះជាមានដាច់សរសៃខួរក្បាលយ៉ាងណាក៏ដោយ ក៏មិនមានឥទ្ធិពលទៅលើតួនាទីចម្បងរបស់ខួរក្បាល និងបន្តជះឥទ្ធិពលតិចតួចប៉ុណ្ណោះទៅលើសុខភាពរាងកាយ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល បានលើកឡើងថា ការទាមទាររបស់ជនជាប់ចោទ នួន ជា ដែលថាខ្លួនមិនអាចអង្គុយនៅក្នុងសវនាការ និងមិនអាចផ្ចង់អារម្មណ៍លើពីរយៈពេលមួយម៉ោងកន្លះនោះ គឺមានហេតុផលសមស្របដោយសារវ័យចំណាស់ និងបញ្ហាបេះដូងរបស់ជនជាប់ចោទរូបនេះ ប៉ុន្តែលោកសាស្ត្រាចារ្យបានលើកឡើងថា នេះទំនងគ្រាន់តែជាការចុះខ្សោយទូទៅ ហើយអាចនឹងនិយាយបានថា វាកើតឡើងអាចជាមធ្យោបាយមួយ ។ ជាពិសេស លោកសាស្ត្រាចារ្យ ខាំប៊ែល “រកមិនឃើញ” ការណែនាំណាមួយទាក់ទងទៅនឹងការចុះខ្សោយនេះនៅក្នុងការពិនិត្យទៅលើ នួន ជា ។

នៅត្រង់ចំណុចនេះ នៅពេលជិតបញ្ចប់នៅថ្ងៃទីពីរ នៃសវនាការ នួន ជា ទៅជាធ្វើឲ្យមានការរំជើបរំជួល ហើយបាន


នួន ជា (រូបថត ៖ អ.វ.ត.ក)

ស្នើសុំដើម្បីនិយាយទៅកាន់សវនាការម្តងទៀត ។ ការស្នើសុំនេះត្រូវបានអនុញ្ញាត ប៉ុន្តែ នួន ជា ត្រូវបានបង្គាប់ឲ្យរង់ចាំរហូតដល់សវនាការនៅព្រឹកបន្ទាប់ ដោយសារតែសវនាការកំពុងតែរៀបនឹងបិទ ហើយជនជាប់ចោទបាននិយាយខុសពេលវេលា ។ ទោះយ៉ាងណាក៏ដោយ ជនជាប់ចោទ នួន ជា ធ្វើមិនអើពើចំពោះការបង្គាប់បញ្ជានេះ ហើយចាប់ផ្តើមនិយាយពីបញ្ហាសុខភាពរបស់ខ្លួន ។ ជនជាប់ចោទ នួន ជា ទទួលស្គាល់ថា នៅក្នុងពេលបច្ចុប្បន្ន និងពីអតីតកាលខ្លួនមានសម្បទាគ្រប់គ្រាន់មែន ប៉ុន្តែជនជាប់ចោទបានលើកឡើងថា នេះគឺមានការប្រែប្រួល ហើយខ្លួនគាត់មានការចុះខ្សោយក្នុងពេលបច្ចុប្បន្ននេះ ។ ជនជាប់ចោទ នួន ជា បានលើកឡើងថា «អតីតកាល និងបច្ចុប្បន្នគឺវាខុសគ្នា ស្ថានភាពរបស់ខ្ញុំគឺវាប្រែប្រួល ។ នៅពេលបច្ចុប្បន្ននេះខ្ញុំអាចដើរបាន ទោះបីបន្ទាប់ពីមានជំងឺដាច់សរសៃឈាមខួរក្បាលក៏ដោយ ក្រោយមកគ្រាន់តែដើរ ដោយឈើច្រត់ ហើយពេលបច្ចុប្បន្ននេះឲ្យ «ដើរជើងប្រាំមួយ» (មានការជួយពីមនុស្សពីរនាក់ទៀត) ។ សុខភាពរបស់ខ្ញុំមានការថយចុះ មិនមែនខ្ញុំមិនជឿលើគ្រូពេទ្យ ប៉ុន្តែសុខភាពរបស់ខ្ញុំវាមានការប្រែប្រួល វាមានបញ្ហាយ៉ាប់ទៅៗ ទាំងរូបរាងកាយ និងសតិអារម្មណ៍ក៏ដូចជាសមត្ថភាពប្រាជ្ញាស្មារតី» ។ ជនជាប់ចោទបានបន្តទៀតស្ទើរតែដូចកវីនិពន្ធជាមួយនឹងឃ្លាថា «បច្ចុប្បន្នជះឥទ្ធិពលដល់អ្វីដែលអាចកើតឡើងនៅពេលអនាគត វាប្រែប្រួល ហើយវាប្រែប្រួលក្នុងផ្លូវអវិជ្ជមានគ្មានអ្វីដែលទៀងទាត់នោះទេ អ្វីៗនឹងរឹតតែអាក្រក់ទៅ ហើយសុខភាពរបស់ខ្ញុំនឹងយ៉ាប់ទៅ» ។

តាមរយៈការផ្ទុះឡើងនេះ សវនាការបានផ្អាកសម្រាប់ថ្ងៃនេះ ហើយលើកការចោទសួរសំណួរទៅលោកសាស្ត្រាចារ្យ ខាំប៉ែល ដោយមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា ទៅថ្ងៃបន្ទាប់ ។ អំឡុងពេលសួរសំណួរដោយក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា លោកសាស្ត្រាចារ្យ ខាំប៉ែល បាននិយាយលម្អិតពីមូលដ្ឋានក្នុងការសម្រេចរបស់លោក ។ នៅពេលដែលសួរសំណួរថាតើការពិនិត្យរបស់លោកទូលំទូលាយឬទេនោះ លោកសាស្ត្រាចារ្យ ខាំប៉ែល បានលើកឡើងថា «ខ្ញុំមិនដែលមានអារម្មណ៍ថាខ្ញុំមានពេលវេលាខ្លី ហើយស្នើសុំឲ្យមានកាពិនិត្យបន្ថែមត្រូវធ្វើម្តងណាឡើយ» ។ លោកសាស្ត្រាចារ្យ ខាំប៉ែល បានបញ្ចេញមតិថាការទាមទាររបស់ជនជាប់ចោទ នួន ជា ថាខ្លួនមិនអាចផ្តង់អារម្មណ៍និងអង្គុយលើសពីមួយម៉ោងកន្លះនោះ គឺវាសមហេតុផលដោយសារតែជំងឺផ្សេងៗរបស់ជនជាប់ចោទ នួន ជា ក៏ប៉ុន្តែលោកសាស្ត្រាចារ្យបានលើកឡើងថា សវនាការក៏បានប្រើវិធីសាស្ត្រចាំបាច់ដើម្បីជួយសម្រួលជនជាប់ចោទរួចហើយ ។ នៅក្នុងអំឡុងពេលសវនាការពេលព្រឹកនៃថ្ងៃបញ្ចប់ ជនជាប់ចោទ នួន ជា ជាថ្មីម្តងទៀតស្នើសុំដើម្បីចាកចេញ ជនចាប់ចោទថែមទាំងស្នើសុំថាគាត់នឹងត្រូវអនុញ្ញាតឲ្យបោះបង់សិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងដំណើរការនីតិវិធីទាំងស្រុង និងស្នើសុំត្រឡប់ទៅកាន់បន្ទប់ឃុំឃាំងដោយមិនចង់ទៅកាន់បន្ទប់រង់ចាំដែលនៅជិតបន្ទប់សវនាការហើយអាចអង្កេតតាមរយៈមធ្យោបាយសោតទស្សន៍នោះទេ ។ ជនជាប់ចោទ នួន ជា ត្រូវបានអនុញ្ញាតឲ្យចាកចេញពីបន្ទប់សវនាការ ប៉ុន្តែបង្គាប់ឲ្យរក្សានៅក្នុងបន្ទប់រង់ចាំ ។ បន្ទាប់ពីសម្រាក មេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា បានជូនដំណឹងទៅកាន់សវនាការថា ជនជាប់ចោទ នួន ជា បានស្នើសុំជាក់លាក់ថាការស្នើសុំរបស់គាត់គឺទៅកាន់បន្ទប់ឃុំឃាំង ហើយក៏បានជូនដំណឹងទៀតថា ជនជាប់ចោទបានបិទទូរទស្សន៍នៅក្នុងបន្ទប់រង់ចាំរបស់ខ្លួន ពីព្រោះគាត់កំពុងឈឺខ្លាំងពេលមើលដំណើរការតាមរយៈទូរទស្សន៍ ។ មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា បានបន្តទៀតថា «បន្ទប់រង់ចាំមិនគួរបង្កើតឡើងដើម្បីបំភាន់ថាជនជាប់ចោទចូលរួមសវនាការប្រកបដោយប្រសិទ្ធភាពនោះទេ កាលដែលគាត់មិនអាចចូលរួមបាន» ។

ក្នុងការឆ្លើយតបទៅកាន់ការស្នើសុំរបស់មេធាវីដែលថា នួន ជា ត្រូវត្រឡប់ទៅបន្ទប់ឃុំឃាំងវិញ នោះអង្គជំនុំជម្រះបង្គាប់ឲ្យគ្រូពេទ្យនៅក្នុងសវនាការធ្វើការពិនិត្យនៅពេលសម្រាកអាហារថ្ងៃត្រង់ ដើម្បីកំណត់ថាតើស្ថានភាពបច្ចុប្បន្នចាំបាច់ដើម្បីប្តូរទីកន្លែងឬទេ ។ ក្នុងអំឡុងពេលនៃការពិនិត្យនេះ អង្គជំនុំជម្រះជាថ្មីម្តងទៀត បានបដិសេធចោលសំណើរបស់ជនជាប់ចោទ នួន ជា ។ រំពុកឡើងវិញពីសវនាការនៅពេលព្រឹក មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា បានចោទសួរសំណួរទៅកាន់លោកសាស្ត្រាចារ្យ ខាំប៉ែល ជាមួយនឹងការលេចឡើងនូវគោលដៅមួយដែលបង្ហាញ

ចេញនូវហេតុផលថា ការទាមទាររបស់ជនជាប់ចោទ នួន ជា ថាខ្លួនមិនអាចផ្តល់អារម្មណ៍គឺសម្រាប់ពន្យឺតពេលវេលា ។ មេធាវីការពារក្តីធ្វើដូច្នេះ ដោយការសួរសំណួរតាមលំដាប់ និងសំណួរដែលមានលក្ខណៈចង្អៀតដោយផ្តោតទៅលើទ្រឹស្តីដែលអាចកើតមាន ប៉ុន្តែការពិតមិនទំនងជាមាននោះទេ ការរៀបចំឡើងយ៉ាងច្បាស់លាស់នេះដើម្បីទាញយកចម្លើយ «មែន» ឬ«មិនមែន» ពីលោកសាស្ត្រាចារ្យ ខាំប៊ែល ។ ក៏ប៉ុន្តែ លោកសាស្ត្រាចារ្យ ខាំប៊ែល មិនមានឆន្ទៈដើម្បីសហការឆ្លើយសំណួរធម្មតា ហើយជំនួសដោយការឆ្លើយដដែលៗ បែបពន្យល់មូលហេតុដែលទ្រឹស្តីនីមួយៗ ត្រូវបានប្រើប្រាស់មកលើគាត់មិនទំនងជាអាចកើតមាន ។ ឧទាហរណ៍មេធាវីការពារក្តីរបស់ នួន ជា បានសួរលោកសាស្ត្រាចារ្យថាតើជំងឺដាច់សរសៃឈាមខួរក្បាល (ប្រភេទជំងឺដែល នួន ជា ទទួលរងកាលពីឆ្នាំ១៩៩៥) អាចនឹងធ្វើឲ្យបាត់បង់ការចងចាំ និងស្មារតីជាបញ្ហាដែរឬទេ ។ បំណងពិតប្រាកដនៃសំណួរនេះ គឺដើម្បីបង្ខំឲ្យលោកសាស្ត្រាចារ្យ ខាំប៊ែល ឆ្លើយនូវចម្លើយសាមញ្ញមួយ «ពិតមែន» ព្រោះការសន្មតជាមុនដូចជា លទ្ធផលនៅក្នុងទ្រឹស្តីគឺវាអាចទៅរួច ។ ក៏ប៉ុន្តែលោកសាស្ត្រាចារ្យ ខាំប៊ែល បានឆ្លើយជំនួសមកវិញយ៉ាងច្បាស់ថា «ទេ» ហើយលោកបរិយាយយ៉ាងល្អិតល្អន់ថា ជំងឺដាច់សរសៃឈាមខួរក្បាល គឺមិនប៉ះទង្គិចទៅនឹងការចងចាំ ឬបាត់បង់សមត្ថភាពក្នុងការចូលរួមសវនាការទេ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល ក៏ត្រូវបានសួរផងដែរថាតើវាអាចទៅរួចទេដែលការប្រែប្រួលតួនាទីក្នុងខួរក្បាលរបស់ នួន ជា ជាលទ្ធផលពីជំងឺដាច់សរសៃឈាមខួរក្បាលកាលពីឆ្នាំ១៩៩៥ ដែលមិនមានភស្តុតាងក្នុងការពិសោធ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល បានឆ្លើយតបថា «ពិតមែន» ក៏ប៉ុន្តែមិនមានភស្តុតាងពីមន្ទីរព្យាបាលលើ នួន ជា ទេ ។ ការសួរសំណួររបៀបនេះបានបន្តមិនចេះចប់ ហើយពេលខ្លះសូម្បីតែមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ក៏ត្រូវការសួរដូចជាសំណួររៀបរាប់ពីមូលដ្ឋានសម្រាប់សំណើសុំរបស់ពួកគេលើការវាយតម្លៃបន្ថែមរបស់អ្នកជំនាញ ហើយការឆ្លើយតបរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល ហាក់បីដូចជាគ្រាន់តែធ្វើឲ្យសាធារណជនមានមន្ទិលសង្ស័យលើការទាមទាររបស់ជនជាប់ចោទ នួន ជា ។

បន្ទាប់ពីការសម្រាកអាហារថ្ងៃត្រង់ អង្គជំនុំជម្រះបានទទួលលទ្ធផលពិនិត្យសម្រាប់ជនជាប់ចោទ នួន ជា ។ លទ្ធផលទាំងនេះបានលាតត្រដាងថាមិនមានការព្រួយបារម្ភភ្លាមៗនោះទេ ហើយនៅក្នុងលទ្ធផលនៃការពិនិត្យគឺនៅក្នុងកម្រិតមួយធម្មតាដោយផ្អែកលើប្រវត្តិនៃកាពិនិត្យសុខភាព និងអាយុរបស់ជនជាប់ចោទ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា បានជូនដំណឹងទៅកាន់អង្គជំនុំជម្រះថា ជនជាប់ចោទ នួន ជា បានរាយការណ៍ថារូបខ្លួនអស់កម្លាំង ហើយមិនអាចផ្តល់អារម្មណ៍បានសូម្បីតែ «មើលទូរទស្សន៍» នៅក្នុងបន្ទប់រង់ចាំ ហើយគាត់បានបិទទូរទស្សន៍ មានចៅក្រមមួយចំនួនហាក់បីដូចមានការរួញរានឹងការសម្រេចលើការស្នើសុំរបស់ជនជាប់ចោទ នួន ជា ហើយចៅក្រម ខាតស្រ៊ាយត៍ បង្ហាញរបៀបរិះគន់ទៅលើការយោងរបស់មេធាវីការពារក្តីរបស់ជនជាប់ចោទអំពីការចូលរួមដោយប្រយោលរបស់ជនជាប់ចោទតាមរយៈបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍ដូចជាការ «មើលទូរទស្សន៍» ដោយលើកឡើងថា «ខ្ញុំមិនយល់ថាលោកមេធាវីមានន័យដូចម្តេចដែលថា «មើលទូរទស្សន៍» នោះ ប៉ុន្តែខ្ញុំយល់ឃើញថា លោកមេធាវីមានន័យសំដៅលើប្រព័ន្ធសោតទស្សន៍មិនមែនមើលឆាកល្ខោន» ។ បន្ទាប់មកអង្គជំនុំជម្រះបានសួរទៅកាន់លោកសាស្ត្រាចារ្យ ខាំប៊ែល ថាតើបន្ទប់រង់ចាំគឺ ស័ក្តិសមក្នុងការរក្សា នួន ជា ទុកដែរឬទេ ។ លោកសាស្ត្រាចារ្យ ខាំប៊ែល មានយោបល់ថា បន្ទាប់ពីបានទស្សនកិច្ចបន្ទប់រង់ចាំ លោកមិនឃើញមានមូលហេតុណាដែលជនជាប់ចោទ នួន ជា អាចនឹងមានផលលំបាកខាងផ្លូវកាយធ្ងន់ធ្ងរនៅក្នុងបន្ទប់រង់ចាំជាងកន្លែងដទៃទៀតនោះទេ ព្រោះជនជាប់ចោទអាចសម្រាកតាមតម្រូវការ ហើយទទួលបានការយកចិត្តទុកដាក់លើសុខភាពប្រសិនបើចាំបាច់ ។ ហើយអង្គជំនុំជម្រះក៏បង្គាប់ឲ្យរក្សាជនជាប់ចោទ នួន ជា នៅក្នុងបន្ទប់រង់ចាំរហូតដល់បញ្ចប់សវនាការ ។

សវនាការបានបន្តដោយការសួរសំណួររបស់តំណាងអយ្យការទៅលោកសាស្ត្រាចារ្យ ខាំប៊ែល ។ សំណួររបស់ព្រះរាជអាជ្ញាជាសំណួរដែលមានលក្ខណៈទូទៅ ហើយអនុញ្ញាតឲ្យលោកសាស្ត្រាចារ្យលម្អិត និងសង្ខេបហេតុផលដែលលោកជឿជាក់ថាជនជាប់ចោទ នួន ជា នាពេលបច្ចុប្បន្នមានសម្បទាក្នុងការចូលរួមនៅក្នុងសវនាការ ហើយនឹងស្នើសុំមិនឲ្យមានការវាយតម្លៃបន្ថែម ។

ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ខ្លួនមិនត្រូវការសួរសំណួរច្រើនទៀតទេ ពីព្រោះដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា ដំណើរការកិច្ចនីតិវិធីបានធ្វើឲ្យឃើញច្បាស់លាស់ហើយថា ជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការ ។

### ក) លទ្ធភាពពាក់ព័ន្ធដែលអាចកើតមានពីការលើបញ្ហាសុខភាពរបស់ នួន ជា

អំណះអំណាងដែលបានដាក់ទៅរបស់មេធាវីការពារក្តី នួន ជា បានបង្កើតជាដំណើររឿងថ្មីមួយចំពោះអង្គជំនុំជម្រះ ដើម្បីដោះស្រាយថា គួររកឲ្យឃើញថាបណ្តឹងលើបញ្ហាសុភាពរបស់ជនជាប់ចោទ នួន ជា គួរឲ្យជឿជាក់ឬទេ ។ ជនជាប់ចោទ នួន ជា បានបង្ហាញនូវចេតនាក្នុងការអនុវត្តសិទ្ធិក្នុងការចូលរួមនៅក្នុងសវនាការរបស់ខ្លួន ប៉ុន្តែជនជាប់ចោទបានលើកឡើងថា ខ្លួនមិនអាចចូលរួមក្នុងដំណើរការសវនាការប្រកបដោយប្រសិទ្ធភាពលើសពីមួយម៉ោងក្នុងមួយថ្ងៃទៅវិញ ។ ដូច្នេះ ជនជាប់ចោទ នួន ជា អះអាងថា ខ្លួនមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការ ពីព្រោះតាមរយៈការរក្សាទុកសមត្ថភាពស្មារតីរបស់ខ្លួនជាទូទៅ ខ្លួនមិនមានសុខភាពរាងកាយ និងស្មារតីក្នុងការរក្សាឲ្យបាននូវការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការនីតិវិធីលើសពីរយៈពេលខ្លីបានទេ ដែលជាលទ្ធផលរារាំងដល់ការអនុវត្តសិទ្ធិរបស់ខ្លួន ។

ការអះអាងនេះមិនបានបង្ហាញនូវការបញ្ចុះបញ្ចូលចំណុចយោងទៅព័ត៌មានដែលអាចរកបានជាសាធារណៈ និងការសង្កេតរបស់ នួន ជា តាមរយៈសវនាការនីតិវិធីទាំងឡាយនោះទេ ។ ការពិនិត្យរបស់លោកសាស្ត្រាចារ្យ ខាំប៊ែល មិនបានរកឃើញនូវមូលហេតុចំពោះចម្ងល់ទាក់ទងនឹងសម្បទាផ្លូវចិត្តរបស់ជនជាប់ចោទ នួន ជា និងវត្តមានរបស់ នួន ជា ប្រកបដោយសមត្ថភាពពេញលេញក្នុងការអនុវត្តសិទ្ធិទាំងឡាយរបស់ខ្លួនជាពិសេសនៅក្នុងការបំភ្លឺពីការបង្ខិតបង្ខំ និងការបញ្ជាក់នៅក្នុងសេចក្តីថ្លែងទាំងពីរលើករបស់ខ្លួននៅក្នុងសាលសវនាការ ។ ប៉ុន្តែការកំណត់អំពីសម្បទាជនជាប់ចោទក្នុងការចូលរួមសវនាការនោះថាតើជាការចាំបាច់ក្នុងការពិសោធបន្ថែមឬយ៉ាងណាមុនពេលធ្វើការកំណត់ នោះគឺជាការសម្រេចចុងក្រោយដែលត្រូវប្រគល់ឲ្យទៅចៅក្រមនៃអង្គជំនុំជម្រះតែមួយគត់ ។

### ៤) សេចក្តីសន្និដ្ឋាន ៖ សម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ស្ថិតនៅក្នុងមន្ទិលសង្ស័យ ចំណែកជនជាប់ចោទ នួន ជា ទំនងជាមានសម្បទាគ្រប់គ្រាន់

សវនាការបានផ្តល់នូវភាពច្បាស់លាស់ដ៏មានសារសំខាន់ពីទិដ្ឋភាពជាច្រើនដែលទាក់ទងទៅនឹងសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា ។ ទីមួយ សាស្ត្រាចារ្យ ខាំប៊ែល ដែលជាអ្នកជំនាញថែទាំមនុស្សចាស់បានធ្វើការឆ្លើយយ៉ាងត្រឹមត្រូវនៅក្នុងអំឡុងពេលសួរសំណួរចំនួនបីថ្ងៃពេញ ។ ភាពជំនាញរបស់សាស្ត្រាចារ្យ ខាំប៊ែល ក្នុងបញ្ហាសុខភាពមនុស្សចាស់គឺត្រូវបានបង្ហាញ ហើយសាស្ត្រាចារ្យ ខាំប៊ែល បានឆ្លើយយ៉ាងច្បាស់ និងយកចិត្តទុកដាក់នូវសំណួរទាំងអស់ដែលដែលបានសួរមកលើខ្លួនដែលបង្កើតនូវជំនឿជឿជាក់ក្នុងការរកឃើញរបស់ខ្លួន ។ ទីពីរ) ដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ គឺស្ថិតនៅក្នុងកម្រិតហានិភ័យខ្ពស់ ។ សាស្ត្រាចារ្យ ខាំប៊ែល បានបង្ហាញពីជំនឿជាក់យ៉ាងពេញលេញនៅក្នុងរោគវិនិច្ឆ័យរបស់ខ្លួនដែលថា អៀង ធីរិទ្ធ ទទួលរងផលប៉ះពាល់ពីជំងឺវង្វេងវង្វាន់ ហើយដែលជំងឺនេះបានឈានទៅដល់កម្រិតដែលជនជាប់ចោទ អៀង ធីរិទ្ធ មិនអាចចូលរួមបានពេញលេញក្នុងការការពារខ្លួន ដែលឈានដល់ការសន្និដ្ឋានជាមុនថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសនាការ ។ ទី៣) ជនជាប់ចោទ នួន ជា ទំនងជារក្សាសមត្ថភាពស្មារតីរបស់ខ្លួន ហើយនឹងមានសម្បទាពេញច្បាប់ដើម្បីចូលរួមសវនាការនៅក្នុងពេលបច្ចុប្បន្ន ។ ជាច្រើនដង ជនជាប់ចោទ នួន ជា បាននិយាយច្បាស់លាស់ ត្រឹមត្រូវ ហើយមានប្រសិទ្ធភាព នៅខណៈពេលដែលធ្វើការបង្ហាញដោយសង្ខេបអំពីតួនាទីពីអតីតជាកម្មាភិបាលខ្មែរក្រហម ។ ចុងបញ្ចប់ យុត្តិសាស្ត្រមេធាវីរបស់ជនជាប់ចោទ នួន ជា ដែលទាក់ទងការបង្ហាញសម្បទាដោយផ្អែកទៅលើការវិវឌ្ឍទៅមុខនៃបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលនឹងកើតឡើងនៅពេលខាងមុខប្រហែលជាកើតមានច្រើនប្រឆាំងនឹងសុខភាពរបស់ជនជាប់ចោទ ដួន ជា តាមរយៈការធ្វើសវនាការកាត់ទោស នួន ជា ទោះបីអង្គជំនុំ

ជម្រះរកឃើញថា នួន ជា បច្ចុប្បន្នមានសម្បទាគ្រប់គ្រាន់ក៏ដោយ ។

ការឈានទៅមុខនៃសវនាការនេះ បញ្ហាសុខភាពផ្នែកស្មារតីរបស់ អៀង ធីរិទ្ធ នឹងទំនងបន្តជាកម្មវត្ថុនៃការចាប់អារម្មណ៍ដ៏សំខាន់និងគំនិតមន្ទិលសង្ស័យក្នុងចំណោមអ្នកតាមដានសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ មតិរបស់អ្នកចូលរួមជាច្រើនមានការព្រួយបារម្ភថា អៀង ធីរិទ្ធ ប្រហែលជាធ្វើពុតជាមានបញ្ហាផ្នែកបញ្ញាស្មារតី ។ ក្តីបារម្ភទាំងនេះនៅតែបន្តមានទោះបីជាសាស្ត្រាចារ្យ ខាំប៊ែល បានធ្វើការពន្យល់យ៉ាងច្រើនពីឥទ្ធិពលផ្សេងៗដែលលោកបានពិចារណារាល់សំណើទាំងអស់ ថា អៀង ធីរិទ្ធ ទទួលរងផលប៉ះពាល់ពីជំងឺវង្វេងវង្វាន់ក៏ដោយ ។ មន្ទិលសង្ស័យទាំងនោះបានគូសបញ្ជាក់ថា តុលាការមានការលំបាកក្នុងការប្រឈមមុខនៅក្នុងការវាយតម្លៃពីសម្បទាស្មារតីដើម្បីចូលរួមសវនាការ ខណៈដែលបញ្ហាសុខភាពផ្នែកបញ្ញាស្មារតីកម្រមានភ័ស្តុតាងបង្ហាញឲ្យបានពិតប្រាកដតាមរយៈការធ្វើតេស្តពិសោធន៍ ... 

ពិច័យណាស់ ។ អង្គជំនុំជម្រះបានបញ្ជាឲ្យធ្វើកោសល្យពិច័យរួចរាល់ទៅហើយបន្ថែមលើជនជាប់ចោទ អៀង ធីរិទ្ធ ដោយអ្នកជំនាញខាងជំងឺវង្វេងចំនួនបួននាក់ ។ នេះប្រហែលជាបណ្តាលមកពីការយកចិត្តទុកដាក់ដ៏ច្រើនលើសលុប និងជារឿងមួយដែលមានភាពរសើប ទើបបង្កើតឲ្យមានភាពមន្ទិលសង្ស័យពីសាធារណជនទាក់ទងទៅនឹងការមិនមានសម្បទារបស់ អៀង ធីរិទ្ធ ។

កោសល្យពិច័យទាំងនោះប្រហែលជាអាចជួយសម្រាលនូវមន្ទិលសង្ស័យពីសាធារណជនខ្លះ ហើយការដែលមានគំនិតចង់បន្ថែមអ្នកជំនាញគឺជានិច្ចជាកាលជារឿងល្អមួយសម្រាប់ឲ្យចៅក្រមដើម្បីធ្វើការសម្រេចទាក់ទងទៅនឹងរឿងលំបាកដូចជាបញ្ហាសម្បទានេះ ។ ទោះបីជាយ៉ាងណា ការធ្វើកោសល្យពិច័យបន្ថែមគឺទំនងជាចំណាយពេលច្រើនខែ ។ ដូច្នេះ វាបង្ហាញថាដំណើរការលឿនដែលគេចង់បានបំផុតនោះគឺនឹងធ្វើការបំបែកសំណុំរឿងរបស់ អៀង ធីរិទ្ធ ចេញពីសំណុំរឿង០០២ ហើយបន្តដំណើរការនីតិវិធីប្រឆាំងជនជាប់ចោទ អៀង ធីរិទ្ធ ដាច់ដោយឡែក ។ ក្នុងករណីនេះនឹងធ្វើឲ្យនីតិវិធីកាត់ទោសជនជាប់ចោទ នួន ជា, អៀង សារី, ខៀវ សំផន មានភាពឆាប់រហ័សដោយសារអាយុរបស់ជនជាប់ចោទទាំងនោះកាន់តែច្រើន ហើយនៅក្នុងសេចក្តីថ្លែងការណ៍ពីបញ្ហាសុខភាពដែលបានលើកឡើងដោយការអះអាងរបស់ នួន ជា ថាបញ្ហាសុខភាពមានការចុះទ្រុឌទ្រោម ។

វាគឺមានសារសំខាន់ដើម្បីកត់សម្គាល់ថា ការបំបែកចេញពីគ្នានេះនឹងមិនមានតម្លៃស្មើនឹងការដកចោលនៃសំណុំរឿងប្រឆាំងនឹង អៀង ធីរិទ្ធ ទាំងមូលនោះទេ ប៉ុន្តែវានឹងអនុញ្ញាតត្រឹមការសួរដេញដោលពីសម្បទារបស់ អៀង ធីរិទ្ធ ដើម្បីដំណើរការនីតិវិធីដំណាលគ្នាទៅនឹងដំណើរការកាត់សេចក្តីប្រឆាំងនឹងជនជាប់ចោទនៅក្នុងសំណុំរឿង០០២ បច្ចុប្បន្នដែលមិនបានដំណើរការ ។ បន្ថែមលើនេះទៅទៀត ទោះបីជនជាប់ចោទ អៀង ធីរិទ្ធ ចុងក្រោយត្រូវបានរកឃើញថា មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ វាមិនទំនងថា អៀង ធីរិទ្ធ នឹងត្រូវតុលាការដោះលែងពីការឃុំឃាំងដោយគ្មានលក្ខខណ្ឌនោះទេ ។ បើតាមយុត្តិសាស្ត្រដែលពាក់ពន្ធ័ទៅនឹងបញ្ហានេះ គឺវាច្បាស់ណាស់ដែលថា ជនជាប់ចោទដែលមិនមានសម្បទាគ្រប់គ្រាន់គឺគ្រាន់តែដោះលែងដើម្បីទទួលបានការព្យាបាលដែលមានលក្ខណៈសមរម្យ ។ ការចេញបទបញ្ជាផ្សេងៗគឺដោយមិនមានភាពលម្អៀងដើម្បីបន្តនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទដែលមានសម្បទាគ្រប់គ្រាន់តាមការចង្អុលបង្ហាញនៅពេលខាងមុខឡើងវិញ ។

ដោយមិនគិតទៅដល់លទ្ធផលចុងក្រោយនៃសេចក្តីសម្រេចស្តីសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា ឬលទ្ធភាពនៃការបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីសុំណុំរឿង ០០២ សវនាការការស្តីពីសម្បទាជនជាប់ចោទបានធ្វើឲ្យការពិតមួយត្រូវបានបង្ហាញច្បាស់ថា ពេលវេលាគឺជារបស់មួយដែលចាំបាច់បំផុតនៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដែលតុលាការមិនអាចខ្ជះខ្ជាយពេលវេលាទាំងនោះ ដោយមិនបានគ្រប់គ្រងទៅលើភាពប្រថុយប្រថាននៃការបាត់បង់ជនជាប់ចោទមួយចំនួន ឬទាំងអស់នៅក្នុងសំណុំរឿង០០២ ដើម្បីតែរឿងមិនមានសម្បទាគ្រប់គ្រាន់ ឬការស្លាប់របស់ជនជាប់ចោទនោះទេ ។

**រ៉ែនដល ឌីហ្សាល់ក្ញ**

# ក្របខ័ណ្ឌស្តីពីសិទ្ធិបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

មាត្រា៨១(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងពីសិទ្ធិរបស់ជនជាប់ចោទ “ដែលត្រូវកាត់ទោសដោយមានវត្តមានក្នុងអង្គសវនាការ” ។ បើទោះបីជាសិទ្ធិបង្ហាញខ្លួនគឺជាគោលការណ៍មួយនៃច្បាប់អន្តរជាតិក៏ដោយ ក៏ការបកស្រាយខ្លឹមសារនៃសិទ្ធិនេះចេញពីទ្រឹស្តីមកជាការអនុវត្តនៅតែមានភាពចម្រូងចម្រាសដោយគ្មានការព្រមព្រៀងលើខ្លឹមសារនៃវត្តមាន ឬសារសំខាន់នៃវត្តមានរបស់ជនជាប់ចោទនៅក្នុងអង្គសវនាការនៅឡើយទេ ។ ដូច្នេះ សំណុំរឿង០០២នឹងជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការបកស្រាយដោយខ្លួនឯងលើសិទ្ធិចូលបង្ហាញខ្លួននៅក្នុងអង្គសវនាការរបស់ជនជាប់ចោទ ។ ជនជាប់ចោទទាំងបួននាក់គឺ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន សុទ្ធតែមានវ័យចិតសិបទៅប៉ែតសិបឆ្នាំ ហើយម្នាក់ៗសុទ្ធតែមានជំងឺ និងបញ្ហាសុខភាពទ្រុឌទ្រោម ។ ដោយសារតែបញ្ហាវ័យជរា និងបញ្ហាជំងឺទាំងអស់នេះហើយដែលបណ្តាលឲ្យជនជាប់ចោទទាំងបួននាក់នេះមានស្ថានភាពមិនប្រសើរ ដើម្បីមានវត្តមានចូលរួមនៅក្នុងដំណើរនីតិវិធីរបស់តុលាការសម្រាប់អង្គជំនុំជម្រះក្តីលើសំណុំរឿង០០២របស់ខ្លួនបាន ។

ក្នុងផែនការទប់ស្កាត់ និងដោះស្រាយបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែពិចារណាថាតើជនជាប់ចោទពិតជាមានបញ្ហាសុខភាពទ្រុឌទ្រោមពេកដែលមិនអាចមានវត្តមានចូលរួមនៅក្នុងអង្គសវនាការមែនដែរឬទេ និងថាតើជនជាប់ចោទអាចនឹងមានវត្តមានចូលរួមនៅក្នុងដំណើរការអង្គសវនាការនេះតាមប្រព័ន្ធសោតទស្សន៍បានដែរឬទេ ហើយនិងថាតើការចូលរួមនៅក្នុងដំណើរការអង្គសវនាការតាមប្រព័ន្ធសោតទស្សន៍អាចនឹងរំលោភសិទ្ធរបស់ជនជាប់ចោទក្នុងការមានវត្តមានចូលរួមក្នុងអង្គនីតិវិធីដែរឬយ៉ាងណា ។ មាត្រានេះឆ្លុះបញ្ចាំងឲ្យឃើញសំណួរទាំងអស់នេះ ហើយក៏បានណែនាំថា យោងតាមច្បាប់ករណីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងការខ្វះខាតគោលការណ៍ណែនាំពីច្បាប់កម្ពុជា អង្គជំនុំជម្រះសាលាដំបូងគួរតែអនុវត្តវិធីសាស្ត្រសមរម្យ និងមានគុណប្រយោជន៍ដើម្បីដោះស្រាយសំណួរដែលចោទសួរទាក់ទងនឹងការមានវត្តមានចូលរួមរបស់ជនជាប់ចោទនៅក្នុងអង្គសវនាការ ។ សំខាន់ជាងនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែត្រូវបានអនុញ្ញាតឲ្យអនុវត្តការមានវត្តមានចូលរួមរបស់ជនជាប់ចោទតាមរយៈប្រព័ន្ធសោតទស្សន៍ឲ្យតែដីកាអនុវត្តការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍គោរពតាមគោលការណ៍នៃច្បាប់នេះ ។

## ១) ក្របខ័ណ្ឌស្តីពីបញ្ហា : យុត្តិធម៌ និង ភាពឆាប់រហ័ស

សិទ្ធិត្រូវបានកាត់ទោសដោយមានវត្តមាននៅក្នុងអង្គសវនាការត្រូវបានការពារដោយមាត្រា១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ សិទ្ធិនេះគឺជា “ការធានារ៉ាប់រងអប្បបរមា” មួយរបស់ជនជាប់ចោទដែលជាផ្នែកមួយនៃសិទ្ធិទទួលបានការកាត់ទោសប្រកបដោយយុត្តិធម៌ ។ វិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមដែលសំដៅទៅលើវិធានចែងពីនីតិវិធី និងវិធានចែងពីភស្តុតាងដែលគ្រប់គ្រងដំណើរការនីតិវិធីរបស់តុលាការខ្មែរក្រហមបានចែងពីសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមានចូលរួមនៅក្នុងអង្គសវនាការ និងពីករណីលើកលែងនៃសិទ្ធិនេះនៅក្នុងវិធានផ្ទៃក្នុងទី៨១ ។ ករណីលើកលែងទីមួយនៃសិទ្ធិនេះគឺមានចែងនៅក្នុងវិធានផ្ទៃក្នុងទី៨១(៥) ដែលនិយាយពី “វិធាននៃប្រព័ន្ធសោតទស្សន៍” ។ វិធាននេះចែងថា ប្រសិនបើជនជាប់ចោទមានជំងឺធ្ងន់ធ្ងរមិនអាចចូលរួមនៅក្នុងដំណើរនីតិវិធីរបស់តុលាការ ហើយការអវត្តមានរបស់ជនជាប់ចោទនេះបានបណ្តាលឲ្យមាន “ការពន្យារយូរ” នោះអង្គជំនុំជម្រះសាលាដំបូងអាចនឹងបន្តដំណើរនីតិវិធីបានដោយគ្មានវត្តមានរបស់ជនជាប់ចោទ ហើយអាចចេញដីកាកោះហៅជនជាប់ចោទឲ្យចូលរួមអង្គនីតិវិធីបាន “តាមរយៈប្រព័ន្ធសោតទស្សន៍ដ៏សមស្រប” “ប្រសិនបើយុត្តិធម៌ត្រូវតែទាមទារឲ្យបាននោះ” ។

### ២) ក្របខ័ណ្ឌនៃប្រភពច្បាប់ ៖ អំណាចអាជ្ញាធរនៃទំនៀមទម្លាប់ច្បាប់ស៊ីវិលកម្ពុជា និងបទដ្ឋានច្បាប់អន្តរជាតិ

ក្រមនីតិវិធីព្រហ្មទណ្ឌអន្តរជាតិអនុញ្ញាតឲ្យមានអង្គសវនាការដោយគ្មានវត្តមានជនជាប់ចោទ ។ មាត្រា៣៣៣នៃក្រមនេះអនុញ្ញាតឲ្យតុលាការរៀបចំដំណើរការនីតិវិធីដោយគ្មានវត្តមានជនជាប់ចោទចូលរួមបានដោយមានប្រសិទ្ធភាព ។ ក្រមនេះចែងថា “បើទោះបីជាជនជាប់ចោទអវត្តមានក៏ដោយ ក៏តុលាការអាចស្វែងរកការពិត ស្តាប់ចម្លើយរបស់ភាគីផ្សេងៗទៀតដូចជាសាក្សីជាដើម និងអាចពិនិត្យមើលដំណើរការនីតិវិធីនេះបានដដែល” ។ ប្រសិនបើជនជាប់ចោទត្រូវបានចោទប្រកាន់ដោយមិនចំពោះមុខ ដំណោះស្រាយតែមួយគត់សម្រាប់ជនជាប់ចោទគឺប្តឹងសាលាឧទ្ធរណ៍លើសេចក្តីសម្រេចរបស់តុលាការដំបូង ហើយលើសពីនេះ ជនជាប់ចោទក៏មិនអាចស្នើសុំឲ្យមានអង្គសវនាការថ្មីប្រឆាំងនឹងអង្គសវនាការដែលបានចោទប្រកាន់ជនជាប់ចោទបានឡើយ បើទោះបីជាជនជាប់ចោទមិនមានវត្តមានក៏ដោយ ។

ការអនុវត្តនៃក្រមស្តីពីសិទ្ធិមានវត្តមានចូលរួមនៅក្នុងអង្គសវនាការបានរំលោភលើបទដ្ឋានអប្បបរមាដែលត្រូវបានកំណត់ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលជាអនុសញ្ញាច្បាប់អន្តរជាតិមួយដែលប្រទេសកម្ពុជាបានចូលជាសមាជិក ។ គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដែលជាភ្នាក់ងារទទួលខុសត្រូវលើការត្រួតពិនិត្យកិច្ចការអនុវត្តរបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងថា ប្រសិនបើរដ្ឋដែលជាសមាជិករបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយយល់ព្រមអនុញ្ញាតឲ្យមានអង្គសវនាការដែលគ្មានវត្តមានរបស់ជនជាប់ចោទនោះរដ្ឋនោះអាចចៀសវាងពីការរំលោភលើវិធានរបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានដោយធានាថា ជនជាប់ចោទមានសិទ្ធិស្នើសុំឲ្យមានអង្គសវនាការម្តងទៀត ។ ដោយសារតែក្រមរបស់កតិកាសញ្ញានេះមិនអនុញ្ញាតឲ្យមានការរៀបចំអង្គសវនាការសាជាថ្មីម្តងទៀត នោះច្បាប់កម្ពុជាមិនមានលក្ខណៈសមស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ ។ ផ្អែកលើមូលហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែដើរតាមសេចក្តីណែនាំរបស់បទដ្ឋានច្បាប់អន្តរជាតិជាជាងតាមច្បាប់កម្ពុជាទាក់ទងនឹងការអនុវត្តសិទ្ធិក្នុងការមានវត្តមានចូលរួមនៅក្នុងអង្គសវនាការ ។

#### ក) ក្របខ័ណ្ឌស្តីពីសិទ្ធិក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការ ៖ គំរូរបស់តុលាការអន្តរជាតិផ្សេងៗ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយគឺជាអនុសញ្ញាអន្តរជាតិមួយដែលតំណាងឲ្យកិច្ចព្រមព្រៀងរបស់



រដ្ឋជាភាគីចំនួន១៦៧ប្រទេស ។ ក្នុងសមាសភាពជាកិច្ចព្រមព្រៀងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមិនអាចធ្វើអ្វីបានច្រើនក្រៅពីផ្តល់ជាបទដ្ឋានដែលមានលក្ខណៈមូលដ្ឋានបំផុតនោះទេ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការខ្មែរក្រហមត្រូវតែបកស្រាយសិទ្ធិមានវត្តមានចូលរួមក្នុងអង្គសវនាការដោយផ្អែកតាមបទដ្ឋានអន្តរជាតិដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងតាម

ច្បាប់ករណីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសម្រាប់ប្រទេសរ៉ាន់ដា ។

**ខ) ក្របខ័ណ្ឌនៃខ្លឹមសារ "វត្តមានផ្ទាល់" "វត្តមានដោយប្រយោល"**

ទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហមមិនបានកំណត់និយមន័យនៃពាក្យ "វត្តមាន" នេះទេ ។ កង្វះខាតនេះបង្កើតជាសំណួរមួយថាតើសិទ្ធិក្នុងការមានវត្តមានចូលរួមនៅក្នុងអង្គ



នួន ជា និង អៀង សារី (ស្តាំ) (រូបថត ៖ អ.វ.ត.ក)

សវនាការនោះសំដៅទៅលើសិទ្ធិដែលត្រូវមានវត្តមានផ្ទាល់នៅក្នុងអង្គសវនាការ ឬថាតើវិធាននេះគួរតែត្រូវបានបកស្រាយដោយបញ្ចូលនិយមន័យនៃពាក្យ "វត្តមានដោយប្រយោល" ដែរឬយ៉ាងណា ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសរ៉ាន់ដាក្នុងរឿងក្តីរវាង ព្រះរាជអាជ្ញា និង ហ្សីជីរ៉ាន់យីរ៉ាហ្សូ បានអនុវត្តបទដ្ឋាន "វត្តមានផ្ទាល់" ដោយជឿជាក់ថា "វត្តមានផ្ទាល់របស់ជនជាប់ចោទនៅចំពោះមុខចៅក្រមគឺជាគោលការណ៍មូលដ្ឋាន និងទូទៅសម្រាប់អង្គជំនុំជម្រះដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌" ។

**គ) ក្របខ័ណ្ឌស្តីពីការប្រឆាំងមិនអនុវត្តតាមច្បាប់ ៖ និយាមដាច់ខាត ឬនិយាមបើកផ្លូវ**

ដោយសារតែការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍មិនអាចដើរតួឲ្យបានពេញលេញតាមសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការនោះ វិធានរបស់តុលាការខ្មែរក្រហមដែលអនុញ្ញាតឲ្យមានការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍មិនបានគោរពទៅតាមសិទ្ធិក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការទេ ។ យ៉ាងណាមិញ ប្រសិនបើសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការត្រូវបានចាត់ទុកជានិយាមដាច់ខាតដែលជាសិទ្ធិមិនអនុញ្ញាតឲ្យមានការប្រព្រឹត្តខុសពីច្បាប់ នោះវិធានដែលអនុញ្ញាតឲ្យមានការចូលរួមក្នុងអង្គសវនាការតាមរយៈសោតទស្សន៍នឹងរំលោភបំពានច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ប៉ុន្តែប្រសិនបើសិទ្ធិនេះត្រូវបានចាត់ទុកថាជានិយាមបើកផ្លូវដែលជាសិទ្ធិអនុញ្ញាតឲ្យមានការប្រឆាំងមិនអនុវត្តតាមច្បាប់ដោយឋិតនៅក្រោមលក្ខខណ្ឌជាក់លាក់ នោះយើងអាចនិយាយបានថា វិធានដែលអនុញ្ញាតឲ្យជនជាប់ចោទមានវត្តមានចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍គឺគោរពទៅតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ក្នុងការអនុវត្តនៃយុត្តិសាស្ត្ររបស់តុលាការបង្ហាញឲ្យឃើញថា សិទ្ធិក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការត្រូវបានចាត់ទុកជានិយាមបើកផ្លូវ ។ ការអនុវត្តសិទ្ធិនេះត្រូវបានធ្វើឡើងនៅក្នុងរឿងក្តីរវាងព្រះរាជអាជ្ញា និងជនជាប់ចោទមីឡូសេវីក ដែលតុលាការបានទទួលស្គាល់ថាសិទ្ធិក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការអាចនឹងត្រូវបាន "រឹតត្បិតដោយសាររាំងខានដល់ដំណើរការនៃអង្គជំនុំជម្រះក្តី" ។

**ឃ) ក្របខ័ណ្ឌស្តីពីភាពដែលអនុញ្ញាតឲ្យមានការប្រឆាំងមិនអនុវត្តតាមច្បាប់ ៖ ការវិភាគលើបញ្ហាសមាមាត្រភាព**

នៅក្នុងច្បាប់សាធារណៈអន្តរជាតិ ច្បាប់នេះបានចែងយ៉ាងត្រឹមត្រូវច្បាស់លាស់ថា ការឃ្លាតចាកពីការអនុវត្តសិទ្ធិមូលដ្ឋានមួយ ឧទាហរណ៍ដូចជាសិទ្ធិក្នុងការមានវត្តមានចូលរួមក្នុងអង្គ

សវនាការត្រូវបានណែនាំដោយគោលការណ៍សមាមាត្រភាព ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានចែងនៅក្នុងរឿងក្តីវ៉ាងព្រះរាជអាជ្ញា និងជនជាប់ចោទ ស្មានីស៊ីក ថាផ្អែកតាមគោលការណ៍សមាមាត្រភាព "ការរឹតត្បិតទាំងឡាយណាមកលើសិទ្ធិមូលដ្ឋានត្រូវតែបម្រើឲ្យវត្ថុបំណងសំខាន់មួយ ហើយត្រូវតែធ្វើសិទ្ធិទាំងឡាយណាដែលមិនមានសារសំខាន់ក្នុងការសម្រេចវត្ថុបំណងនោះបាត់បង់ឥទ្ធិពល" ។ គោលការណ៍នេះរួមមាន ៖ ១) គោលដៅដែលបណ្តាលឲ្យមានការងាកចេញពីការអនុវត្តសិទ្ធិមូលដ្ឋានត្រូវតែក្លាយជាការសម្រេចនៃវត្ថុបំណងដែល "សំខាន់" ឬដែល "ចាំបាច់"(លក្ខន្តិកៈមូលដ្ឋានច្បាប់) ។ ២) ការរឹតត្បិតលើសិទ្ធិក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការត្រូវតែមានសារសំខាន់ (លក្ខន្តិកៈនៃមធ្យោបាយរឹតត្បិត) ។ ៣) ការរឹតត្បិតត្រូវតែមានសមាមាត្រសមស្របទៅតាមវត្ថុបំណងដែលត្រូវសម្រេចលក្ខន្តិកៈ (សមាមាត្រភាព) ។

បើទោះបីជាគោលការណ៍ពាក់ព័ន្ធនឹងសិទ្ធិក្នុងការធ្វើជាតំណាង តែមិនមែនសិទ្ធិក្នុងការមានវត្តមានក្នុងអង្គសវនាការនោះក៏ដោយ ក៏រឿងក្តីរបស់ជនជាប់ចោទ មីឡូសេវីក បានផ្តល់ជាការពិភាក្សាដ៏មានខ្លឹមសារទៅលើគោលការណ៍ដែលឆ្លុះបញ្ចាំងពីបទដ្ឋានដែលនឹងត្រូវយកមកអនុវត្ត ដើម្បីធ្វើការវិភាគលើបញ្ហាសមាមាត្រភាព ។ នៅក្នុងរឿងក្តីរបស់ មីឡូសេវីក អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានចាត់តាំងមេធាវីការពារក្តីម្នាក់ឲ្យធ្វើជាតំណាងឲ្យជនជាប់ចោទ មីឡូសេវីក បើទោះបីជាជនជាប់ចោទទទូចសុំឡើងធ្វើតំណាងដោយខ្លួនឯងក៏ដោយ ។ នេះគឺជាសិទ្ធិដែលត្រូវបានការពារដោយមាត្រា១៤(៣)(ឃ) នៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ និងមាត្រា២១(៤)(ឃ) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ។ នៅក្នុងដីកាចាត់តាំងឲ្យមេធាវីការពារក្តីធ្វើជាតំណាងឲ្យជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថា ការទាមទាររបស់ មីឡូសេវីក ក្នុងការឡើងធ្វើតំណាងឲ្យខ្លួនឯង និងបញ្ហាសុខភាពទ្រុឌទ្រោមបានបណ្តាលឲ្យមានការពន្យារពេលដល់ដំណើរការអង្គជំនុំជម្រះក្តីរបស់តុលាការជារឿយៗ ។ ដោយសារតែការពន្យារពេលទាំងអស់នេះ អង្គជំនុំជម្រះបានយល់ឃើញថា ការដកហូតសិទ្ធិរបស់ មីឡូសេវីក មិនឲ្យឡើងតំណាងដោយខ្លួនឯងពិតជាមានសារសំខាន់ដើម្បីធានាថា អង្គជំនុំជម្រះក្តីអាចវិវត្តន៍ទៅមុខបានយ៉ាងឆាប់រហ័ស ។

ក្រោយមកទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានវិភាគមើលថា តើដីកាចាត់តាំងឲ្យមេធាវីការពារក្តីធ្វើជាតំណាងឲ្យជនជាប់ចោទ មីឡូសេវីក បានគោរពទៅតាមគោលការណ៍សមាមាត្រភាពដែរឬយ៉ាងណា ។ ដំបូង នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនក្នុងការបញ្ជូនរឿងក្តីទៅសាលាដំបូងវិញ ដោយធ្វើការកែប្រែលើដីកានោះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកត់សម្គាល់ឃើញថា មូលដ្ឋានច្បាប់ដែលគាំទ្រការប្រឆាំងមិនអនុវត្តតាមសិទ្ធិធ្វើជាតំណាងឲ្យខ្លួនឯងត្រូវបានបង្កើតឡើង ។ តាមគំនិតរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ការដែលជនជាប់ចោទ មីឡូសេវីក ឡើងធ្វើតំណាងឲ្យខ្លួនឯង "បានរំខានដល់ដំណើរការទៅមុខប្រកបដោយស្ថិរភាព និងភាពឆាប់រហ័សនៃអង្គជំនុំជម្រះក្តីរបស់តុលាការ" បើទោះបីជាការរំខាននេះបានកើតមានឡើងដោយយថាហេតុក៏ដោយ ។ ទីពីរ គ្មានវិធីសាស្ត្ររឹតត្បិតលើសិទ្ធិធ្វើជាតំណាងឲ្យខ្លួនឯងណាមួយមានលក្ខណៈធូរស្រាលជាងនេះទេ ។ ហើយមធ្យោបាយពន្យារពេលដំណើរការកាត់ទោសដែលត្រូវបានអនុវត្តកាលពីមុនក៏ត្រូវបានចាត់ទុកថាគ្មានប្រសិទ្ធភាពដែរ ។ ទីបី អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា ដីការបស់អង្គជំនុំជម្រះសាលាដំបូងមិនគោរពទៅតាមសិទ្ធិក្នុងការធ្វើជាតំណាងឲ្យខ្លួនឯងដែលបណ្តាលឲ្យមានការដកហូតសិទ្ធិក្នុងការធ្វើជាតំណាងឲ្យខ្លួនឯងរបស់ជនជាប់ចោទ មីឡូសេវីក ។ ដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានណែនាំថា ជំនួសឲ្យការចាត់តាំងឲ្យមេធាវីការពារក្តីធ្វើជាតំណាងឲ្យ មីឡូសេវីក តែម្នាង មេធាវីការពារក្តីអាចផ្តល់ជាការប្រឹក្សា និងជំនួយដើម្បីជួយឲ្យ មីឡូសេវីក ឡើងធ្វើតំណាងឲ្យខ្លួនឯង ។ ការកែប្រែនេះអាចក្លាយជាការរំលោភជាសមាមាត្រលើសិទ្ធិក្នុងការធ្វើជាតំណាងឲ្យខ្លួនឯងរបស់ជនជាប់ចោទ មីឡូសេវីក ពីព្រោះវាបានអនុញ្ញាតឲ្យ មីឡូសេវីក បានធ្វើជាតំណាងឲ្យខ្លួនឯង នៅពេលដែលជនជាប់ចោទរូបនេះមានស្ថានភាពសុខភាពប្រសើរ ដើម្បីចូលរួម

ក្នុងអង្គនីតិវិធីនៃអង្គជំនុំជម្រះក្តីរបស់ខ្លួន ។

រឿងក្តីរបស់ជនជាប់ចោទ មីឡូសេវីក បានឆ្លុះបង្ហាញពីបទដ្ឋានដែលត្រូវបានអនុម័តដោយតុលាការ និងអង្គជំនុំជម្រះអន្តរជាតិជាទូទៅក្នុងការអនុវត្តផ្នែកនីមួយៗនៃការវិភាគលើបញ្ហាសមាមាត្រភាព ។ លក្ខន្តិកៈមូលដ្ឋានច្បាប់ត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ហើយដើម្បីចៀសផុតពីឧបសគ្គនេះ ការពន្យារពេលរបស់អង្គជំនុំជម្រះក្តីដែលកើតមានឡើងជារឿយៗត្រូវបានទទួលស្គាល់ថាជាមូលដ្ឋានសម្រាប់ការប្រឆាំងមិនអនុវត្តសិទ្ធិរបស់ជនជាប់ចោទក្នុងការធ្វើតំណាងឲ្យខ្លួនឯង ។ ផ្ទុយទៅវិញ ការតម្រូវទៅតាមលក្ខន្តិកៈរឹតត្បិតដែលមានលក្ខណៈស្រាលនឹងទាមទារឲ្យមានការឆ្លុះបញ្ចាំងឲ្យឃើញថា មធ្យោបាយផ្សេងទៀតត្រូវបានចាត់ទុកថាគ្មានប្រសិទ្ធភាព និងថាគ្មានមធ្យោបាយផ្សេងទៀតណាអាចយកមកអនុវត្តដើម្បីធ្វើការរឹតត្បិតលើសិទ្ធិក្នុងការធ្វើជាតំណាងឲ្យខ្លួនឯងដែរ ។ យ៉ាងណាមិញ លក្ខន្តិកៈសមាមាត្រភាពគឺជាផ្នែកមួយដ៏ចម្រូងចម្រាសនៅក្នុងការវិភាគលើបញ្ហាសមាមាត្រភាពនេះ ។ សមាមាត្រភាពដែលមិនស៊ីជម្រៅមិនមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងវត្ថុបំណងដែលត្រូវសម្រេច និងការរឹតត្បិតដែលត្រូវអនុម័តបានទេ ។ ដូច្នេះ មានតែសមាមាត្រភាពដែលស៊ីជម្រៅតែប៉ុណ្ណោះដែលអាចឆ្លុះបង្ហាញពីទំនាក់ទំនងរវាងវត្ថុបំណងដែលត្រូវសម្រេច និងការរឹតត្បិតដែលត្រូវអនុម័ត ។

### ៣) ក្របខ័ណ្ឌស្តីពីដីកានៃការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ ៖ ការពិចារណាអនុវត្តគោលការណ៍សមាមាត្រភាពនៅក្នុងវិធានស្តីពីអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍របស់តុលាការខ្មែរក្រហម

វិធានផ្ទៃក្នុងទី៨១(៥) របស់តុលាការខ្មែរក្រហមដែលស្តីពីការចូលរួមរបស់ជនជាប់ចោទក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍នៅពេលដែលអវត្តមានរបស់ជនជាប់ចោទដោយសារបញ្ហាសុខភាព "បណ្តាលឲ្យមានការពន្យារពេលយូរដល់ដំណើរការនៃអង្គជំនុំជម្រះក្តី" មានលក្ខណៈស្របគ្នាទៅនឹងការអនុវត្តនៃដំណើរនីតិវិធីរបស់តុលាការ និងអង្គជំនុំជម្រះអន្តរជាតិ ។ នៅក្នុងការអនុវត្តការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ដែលត្រូវបានចាត់ទុកជាករណីលើកលែងមួយទាក់ទងនឹងសិទ្ធិក្នុងការធ្វើជាតំណាងឲ្យខ្លួនឯង វិធានស្តីពីការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍គឺមានលក្ខណៈគោរពទៅតាមបទដ្ឋានអន្តរជាតិដែលចែងថា សិទ្ធិក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការគឺសំដៅលើការមានវត្តមានផ្ទាល់របស់ជនជាប់ចោទ ។ ដូចគ្នាដែរ នៅក្នុងការអនុញ្ញាតឲ្យមានការអនុវត្តការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ បើទោះបីជាជនជាប់ចោទមិនបានបោះបង់ចោលសិទ្ធិក្នុងការធ្វើជាតំណាងឲ្យខ្លួនឯង ក៏វិធាននេះមានលក្ខណៈគោរពតាមការអនុវត្តបទដ្ឋានអន្តរជាតិដែលចាត់ទុកសិទ្ធិក្នុងការមានវត្តមានចូលរួមក្នុងអង្គសវនាការដោយផ្ទាល់ជានិយាមបើកចំហ មិនមែនជានិយាមដាច់ខាតទេ ។

ប្រឆាំងនឹងបទដ្ឋានខាងលើវិធានផ្ទៃក្នុងទី៨១(៥) ដែលចែងពីវិធានដែលអនុញ្ញាតឲ្យមានការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍គឺជាការដាក់កម្រិតជាទូទៅមួយទៅលើសិទ្ធិក្នុងការធ្វើជាតំណាងដោយខ្លួនឯង ។ យ៉ាងណាមិញ វិធាននេះបានបណ្តាលឲ្យខ្លឹមសារលម្អិតស្តីពីដំណើរការនីតិវិធីមិនត្រូវបានសម្រេចនៅឡើយទេ ។ បញ្ហាថាតើខ្លឹមសារលម្អិតទាំងនោះនឹងត្រូវបានសម្រេចនៅក្នុងដីកាដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងនឹងជះឥទ្ធិពលលើការអនុញ្ញាតឲ្យមានការចូលរួមក្នុងអង្គសវនាការ តាមរយៈប្រព័ន្ធសោតទស្សន៍ដែរឬយ៉ាងណា ។ ស្របតាមបទដ្ឋានអន្តរជាតិ ខ្លឹមសារនៃដីកា និងការអនុវត្តរបស់ខ្លឹមសារនោះត្រូវគោរពតាមគោលការណ៍សមាមាត្រភាព ។

#### ក) លក្ខន្តិកៈមូលដ្ឋានច្បាប់

គោលការណ៍សមាមាត្រភាពរបស់លក្ខន្តិកៈមូលដ្ឋានច្បាប់គឺជាប់ពាក់ព័ន្ធនឹងចំណោទសួរថាតើគោលបំណងក្នុងការអនុញ្ញាតឲ្យមានការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍គឺជាការលើកកម្ពស់វត្ថុបំណងសំខាន់ឬយ៉ាងណា ។ ការកាត់បន្ថយផលប៉ះពាល់នៃភាពយឺតយ៉ាវដើម្បីសម្រេចឲ្យបាននូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ត្រូវបានទទួលស្គាល់ថាជាមូលដ្ឋានដ៏សមស្របមួយសម្រាប់ការប្រឆាំងមិនគោរពតាមសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ទោសដោយយុត្តិធម៌ ។

ដោយសារតែវិធានស្តីពីការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍អនុញ្ញាតឲ្យមានការអនុវត្តវិធានខាងលើនេះ ដើម្បីជាការឆ្លើយតបនឹង «ការពន្យារពេលដ៏យូររបស់អង្គជំនុំជម្រះក្តី» នោះអង្គជំនុំជម្រះសាលាដំបូងគួរតែសម្រេចថា ការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ត្រូវតែដាក់ឲ្យអនុវត្តដើម្បីធ្វើឲ្យអង្គជំនុំជម្រះក្តីដំណើរការទៅមុខដោយឆាប់រហ័ស ។

## ១) លក្ខន្តិកៈស្តីពីមធ្យោបាយរឹតត្បិតស្រាល

វិធានស្តីពីការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ចែងថា វិធាននេះអាចនឹងត្រូវយកមកអនុវត្ត ប្រសិនបើ «ការអវត្តមានរបស់ជនជាប់ចោទបានឈានដល់កម្រិតមួយដែលបណ្តាលឲ្យមានការពន្យារពេលយូរ» ។ ការប្រើប្រាស់ឃ្លាថា «ដែលបណ្តាលឲ្យ» ជាជាងឃ្លា «នឹងបណ្តាលឲ្យ» ឬ «អាចបណ្តាលឲ្យ» បានគូសបញ្ជាក់ថាការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍គឺមិនត្រូវបានសម្រេចចាត់ទុកជាយន្តការការពារមួយទេ ។ ផ្ទុយទៅវិញ វាបានឆ្លុះបញ្ចាំងឲ្យឃើញថាតុលាការធ្លាប់បានប្រឈមមុខនឹងបញ្ហាពន្យារពេលដែលមានរយៈពេលយូរ ដែលនេះមានន័យថាការពន្យារពេលពិតជាកើតមានឡើង ។ នេះគឺជាបញ្ហាមួយដែលត្រូវបានចាត់ទុកថាជាមូលដ្ឋានមួយសម្រាប់ការអនុវត្តការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ ។ ដូច្នេះ វិធានស្តីពីការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍នេះតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងគោរពតាមការអនុវត្តសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមានផ្ទាល់ក្នុងអង្គសវនាការ និងអនុគ្រោះដល់ការអវត្តមានរបស់ជនជាប់ចោទដែលបណ្តាលឲ្យមានការពន្យារពេលរហូតដល់ការពន្យារពេលនៃអង្គជំនុំជម្រះក្តីរបស់ជនជាប់ចោទឈានដល់ដំណាក់កាល«យូរ» ។ ទម្រាំនឹងអង្គជំនុំជម្រះសាលាដំបូងអាចនឹងអនុវត្តវិធានស្តីពីការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍បាននោះ ដំណោះស្រាយទាំងពីរខាងលើដែលអង្គជំនុំជម្រះសាលាដំបូងត្រូវបានទទួលរងផលអវិជ្ជមានទៅហើយ ។ ដូច្នេះ ផលអវិជ្ជមាននៃដំណោះស្រាយទាំងនេះនឹងក្លាយជាភ័ស្តុតាងបញ្ជាក់ថាការអនុវត្តការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍មានលក្ខណៈរឹតត្បិតស្រាលប៉ុណ្ណោះ ។

យ៉ាងណាមិញ ឧបសគ្គក្នុងការបំពេញទៅតាមលក្ខន្តិកៈស្តីពី «មធ្យោបាយរឹតត្បិតស្រាល» អាចបណ្តាលមកពីកង្វះខាតនូវសេចក្តីណែនាំទាក់ទងនឹងអ្វីទៅដែលចាត់ទុក និងមិនមែនចាត់ទុកថាជា «ការពន្យារពេលយូរ» ។ ដោយសារតែកង្វះខាតសេចក្តីណែនាំនេះ វាអាចទៅរួចដែលថាអង្គជំនុំជម្រះសាលាដំបូងមានបំណងអនុវត្តការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍នៅដំណាក់កាលដែលការពន្យារ ពេលបានកើតមានឡើង ប៉ុន្តែការពន្យារពេលនេះមិនទាន់មានរយៈពេលយូរនៅឡើយទេ បើទោះបីជាគ្មានយុត្តិសាស្ត្រអន្តរជាតិណាគាំទ្រជម្រើសនេះក៏ដោយ ។ នៅក្នុងរឿងក្តីរវាងព្រះរាជអាជ្ញា និង ហ្សីរ៉ូវីរ៉ា ការអវត្តមានរបស់ជនជាប់ចោទបានពន្យារពេលដំណើរការនីតិវិធីអស់រយៈពេលបីថ្ងៃ ហើយអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតរ៉្វាន់ដាបានសម្រេចឲ្យអង្គជំនុំជម្រះក្តីបន្តដំណើរការរបស់ខ្លួនដោយអវត្តមានរបស់ជនជាប់ចោទ ។ គួរឲ្យកត់សម្គាល់ដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដាបានសម្រេចថា រយៈពេលបីថ្ងៃមិនអាចចាត់ទុកថាជាការពន្យារពេលយូរនោះទេ ហើយអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ។ ស្រដៀងគ្នានោះដែរ ចៅក្រមរបស់រឿងក្តីរបស់ជនជាប់ចោទ មីឡូសេវិក ក៏បានសម្រេចថា ការពន្យារពេលរហូតទៅរយៈពេលប្រាំបីខែទើបត្រូវបានចាត់ទុកថាជាការពន្យារពេលយូរ ។

លទ្ធផលនៅក្នុងរឿងក្តីរបស់ជនជាប់ចោទ ហ្សីរ៉ូវេរ៉ា និង មីឡូសេវិក គូសបញ្ជាក់ថា ការពន្យារពេលយូរគឺសំដៅទៅលើរយៈពេលដែលប៉ះពាល់ដល់ដំណើរការចប់ចុងចប់ដើមរបស់តុលាការ ។ នោះមានន័យថាការពន្យារពេលត្រូវបានពន្យារដល់ដំណាក់កាលដ៏រសើបបំផុតដែលការពន្យារពេលនោះមិនអាចកែខៃបានឡើយ ។ ដូច្នេះ ការពន្យារពេលត្រូវតែវិភាគទៅតាមករណី ។ ឧទាហរណ៍ដូចជា សក្ខីកម្ម ឬភ័ស្តុតាង ដែលត្រូវបានពន្យារ ដំណាក់កាលនៃអង្គជំនុំជម្រះដែលត្រូវផ្អាក ចំនួនថ្ងៃដែលអង្គជំនុំជម្រះត្រូវបានពន្យារ និងលទ្ធភាពដែលការពន្យារពេលអាចនឹងបន្តកើត

មានឡើង ប្រសិនបើជនជាប់ចោទនៅតែបន្តអនុវត្តសិទ្ធិរបស់ខ្លួនជាដើម ។

## ៤) លក្ខន្តិកៈស្តីពីសមាមាត្រភាព

ការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ ចែងថាគ្មានសេចក្តីណែនាំស្តីពីនីតិវិធីនៃទំនាក់ទំនងប្រព័ន្ធសោតទស្សន៍ត្រូវបានអនុវត្តនោះទេ ។ វិធាននេះគ្រាន់តែទាមទារថា ទំនាក់ទំនងនៃប្រព័ន្ធសោតទស្សន៍ត្រូវមានលក្ខណៈ “ត្រឹមត្រូវតាមក្បួនខ្នាត” ប៉ុណ្ណោះ ។ ក្នុងករណីខ្វះខាតសេចក្តីណែនាំផ្សេងទៀត លក្ខន្តិកៈស្តីពីភាពត្រឹមត្រូវតាមក្បួនខ្នាតអាចយកមកអនុវត្ត ជំនួសឲ្យលក្ខន្តិកៈស្តីពីសមាមាត្រភាពបានដែលនឹងអនុញ្ញាតឲ្យការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍មានលក្ខណៈ “ត្រឹមត្រូវតាមក្បួនខ្នាត” ប្រសិនបើលក្ខន្តិកៈនេះត្រូវបានអនុវត្តក្នុងឥរិយាបថដែលរឹតត្បិតស្រាលលើសិទ្ធិក្នុងការមានវត្តមានក្នុងអង្គសវនាការរបស់ជនជាប់ចោទ ។

ដំបូង អំឡុងពេលនៃការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍គួរតែមានរយៈពេលខ្លី ។ សម្រាប់អំឡុងពេលដែលសមរម្យបំផុត អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការខ្មែរក្រហមគួរតែមិនត្រូវកំណត់ការចូលរួមរបស់ជនជាប់ចោទក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ទៅតាមដំណាក់កាលវិវត្តន៍របស់តុលាការទេ ។ ជំនួសឲ្យការធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគួរតែកំណត់រយៈពេលនៃការចូលរួមរបស់ជនជាប់ចោទក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍តាមថ្ងៃដែលជនជាប់ចោទមានស្ថានភាពសុខភាពទ្រុឌទ្រោមខ្លាំងដែលមិនអាចមានវត្តមានផ្ទាល់ក្នុងអង្គសវនាការ ប៉ុន្តែជនជាប់ចោទមានបំណងចង់ចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការ ។ ជាឧទាហរណ៍ នៅក្នុងរឿងក្តីរបស់ ស្តានីស៊ីក អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានចេញដីកាអនុញ្ញាតឲ្យ “ជនជាប់ចោទចូលរួមនៅក្នុងអង្គនីតិវិធីពីមន្ទីរឃុំឃាំងរបស់អង្គការសហប្រជាជាតិនៅថ្ងៃដែលជនជាប់ចោទមានស្ថានភាពសុខភាពមិនអំណោយផល” ។ ដីការបស់រឿងក្តី ស្តានីស៊ីក បានដាក់កម្រិតលើសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមានក្នុងអង្គសវនាការសម្រាប់តែថ្ងៃដែលការអនុវត្តសិទ្ធិនោះអាចបណ្តាលឲ្យមានការផ្អាកដំណើរការរបស់តុលាការ ។ ឧទាហរណ៍ ដូចជាថ្ងៃដែលជនជាប់ចោទមានស្ថានភាពសុខភាពទ្រុឌទ្រោមពេកដែលមិនអាចចូលរួមក្នុងអង្គសវនាការបាន ប៉ុន្តែមានបំណងចង់ចូលរួម ។ ស្រដៀងគ្នានេះដែរ នៅក្នុងរឿងក្តីរបស់ មីឡូសេវិក អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានបដិសេធច្រានចោលដីការបស់អង្គជំនុំជម្រះសាលាដំបូងដែលចាត់តាំងឲ្យមេធាវីការពារក្តីធ្វើតំណាងឲ្យជនជាប់ចោទ ដោយកែប្រែដីកានេះឲ្យមេធាវីការពារក្តីផ្តល់ជាការប្រឹក្សា និងជំនួយដល់ជនជាប់ចោទដើម្បីជួយជនជាប់ចោទធ្វើតំណាងឲ្យខ្លួនឯងវិញ ។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកត់សម្គាល់ ដីកាដែលកែប្រែនោះបានរក្សា“ការសន្មតទុកមុនថា នៅពេលដែល មីឡូសេវិក អាចចូលរួមក្នុងអង្គសវនាការដោយផ្ទាល់បាន នោះ មីឡូសេវិក នឹងឡើងមកធ្វើជាតំណាងឲ្យរឿងក្តីដោយខ្លួនឯង....” ។

ដីកាស្តីពីការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍របស់តុលាការខ្មែរក្រហមគួរតែរក្សាទុកការសន្មតជាមុនថា នៅពេលដែលជនជាប់ចោទអាចចូលរួមក្នុងដំណើរនីតិវិធីបាន នោះជនជាប់ចោទនឹងត្រូវបានអនុញ្ញាតឲ្យចូលរួម ។ ដីកាដែលកំណត់លើសិទ្ធិក្នុងការមានវត្តមានក្នុងអង្គសវនាការបានបង្កើតជាការសន្មតទុកជាមុនថាជនជាប់ចោទមិនអាចចូលរួមនៅក្នុងអង្គនីតិវិធីបានទេដែលនេះបណ្តាលឲ្យមានការរំលោភដែលខុសសមាមាត្រលើសិទ្ធិក្នុងការមានវត្តមានក្នុងអង្គសវនាការ ។ ដូច្នេះ ការរឹតត្បិតទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមានក្នុងអង្គសវនាការដែលធ្វើឡើងដោយទុកជាមុនអាចនឹងនាំមកនូវការអនុវត្តសិទ្ធិជ្រុលហួសហេតុពេកក្នុងការធានាឲ្យមាននូវអង្គជំនុំជម្រះក្តីដែលឆាប់រហ័ស ដែលការធ្វើដូច្នេះទាមទារឲ្យតុលាការកំណត់មិនត្រឹមតែថ្ងៃដែលជនជាប់ចោទមានស្ថានភាពសុខភាពយ៉ាប់យ៉ឺនពេកដែលជនជាប់ចោទមិនអាចចូលរួមក្នុងដំណើរការនីតិវិធីតែប៉ុណ្ណោះទេ ថែមទាំងកំណត់ថ្ងៃដែលជនជាប់ចោទអាចចូលរួមក្នុងដំណើរការនីតិវិធីទៀតផង ។

ទីពីរ ទំនាក់ទំនងតាមប្រព័ន្ធសោតទស្សន៍គួរតែត្រូវបានរៀបចំឡើងក្នុងបរិបទដែលអនុញ្ញាតឲ្យជនជាប់ចោទចូលរួមក្នុង

ដំណើរអង្គជំនុំជម្រះក្តីបានដោយពេញលេញនិងប្រកបដោយប្រសិទ្ធភាព ។ បើទោះបីជាជនជាប់ចោទមិនអាចចូលរួមក្នុងបន្ទប់សវនាការដោយផ្ទាល់ក៏ដោយ ក៏ជនជាប់ចោទអាចនឹងចូលរួមក្នុងអង្គជំនុំជម្រះក្តីរបស់ខ្លួនបានដោយពេញលេញនិងប្រសិទ្ធភាពដែរ ។ នេះក៏ឆ្លុះបញ្ចាំងឲ្យឃើញថាការរំលោភលើសិទ្ធិក្នុងការមានវត្តមានក្នុងអង្គសវនាការមានលក្ខណៈស្រាល ។ នៅក្នុងរឿងក្តីរបស់ជនជាប់ចោទ ស្តានីស៊ិក ទំនាក់ទំនងតាមប្រព័ន្ធសោតទស្សន៍ត្រូវបានអនុវត្តក្នុងសណ្ឋានច្រើនបែបក្នុងគោលបំណងបង្ហាញឲ្យឃើញពីលក្ខណៈនៃការចូលរួមមានវត្តមានក្នុងបន្ទប់សវនាការដែលក្នុងនោះរួមមាន ការបំពាក់កាមេរ៉ាថតរូបនៅជុំវិញសាក្សី ការដាក់បង្ហាញប្រតិចារឹករបស់តុលាការ ទំនាក់ទំនងតាមប្រព័ន្ធទូរស័ព្ទទៅកាន់មេធាវីរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការ និងទំនាក់ទំនងតាមប្រព័ន្ធម៉ៃក្រូហ្វូនទៅកាន់ចៅក្រម ។ ដូចព្រះរាជអាជ្ញាក្នុងរឿងក្តីរបស់ ស្តានីស៊ិក បានអះអាងទំនាក់ទំនងក្នុងសណ្ឋានបែបនេះ “បានរឹតត្បិតស្រាលបំផុតលើសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមានក្នុងអង្គសវនាការដោយផ្ទាល់តាមតែអាចធ្វើបាន” ដោយការបង្ហាញឲ្យឃើញនូវវត្តមានរូបភាពគ្រប់បែបយ៉ាងដែលធ្វើឲ្យជនជាប់ចោទចូលរួមក្នុងដំណើរការនីតិវិធីបានយ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាព” ។ ដូច្នេះ ក្នុងការសម្រេចជ្រើសរើសសណ្ឋាននៃការទាក់ទងតាមរយៈប្រព័ន្ធសោតទស្សន៍ដើម្បីធានាឲ្យមានការរំលោភលើសិទ្ធិរបស់ជនជាប់ចោទតិចតួចតាមតែអាចធ្វើបាននោះ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការខ្មែរក្រហមគួរតែពិចារណាអនុវត្តការដាក់បង្ហាញរូបភាពតាមប្រព័ន្ធកាមេរ៉ាដល់ជនជាប់ចោទ ការកំណត់ពេលវេលាលើការចាក់បង្ហាញរូបភាព និងសំឡេងដល់ជនជាប់ចោទ និងលទ្ធភាពរបស់ជនជាប់ចោទក្នុងការទាក់ទងជាមួយនឹងមេធាវីការពារក្តីរបស់ខ្លួន និងចៅក្រមនៅឯបន្ទប់សវនាការ ។

### សេចក្តីសន្និដ្ឋាន

ភាពជាប់ពាក់ព័ន្ធនៃការវិភាគលើបញ្ហាសមាមាត្រភាពទៅនឹងវិធានការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍របស់តុលាការខ្មែរក្រហមគូសបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការខ្មែរក្រហមអាចនឹងចេញដីកាអនុវត្តការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ក្នុងគោលបំណងធានាឲ្យបាននូវអង្គនីតិវិធីដែលមានដំណើរការឆាប់រហ័សទៅមុខសម្រាប់សំណុំរឿង០០២ដោយគ្មានការរំលោភធ្ងន់ធ្ងរលើសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមានក្នុងអង្គសវនាការ ។ ប៉ុន្តែ មានការចោទជាសំណួរទាក់ទងនឹងការចូលរួមក្នុងអង្គសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ថាតើតុលាការនឹងធ្វើយ៉ាងដូចម្តេចដើម្បីរក្សាឲ្យបាននូវតុល្យភាពរវាងអង្គជំនុំជម្រះដែលមានល្បឿនលឿន និងអង្គជំនុំជម្រះដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ។ ផ្អែកលើហេតុផលនេះ សេចក្តីអំណះអំណាងគាំទ្រលើជម្រើសទាំងពីរមិនអាចសម្រេចជាលទ្ធផលបានទេ ។ ឲ្យតែការប្រឆាំងមិនអនុវត្តតាមច្បាប់មានលក្ខណៈគោរពតាមគោលការណ៍សមាមាត្រភាព នោះការអនុញ្ញាតឲ្យមានការប្រឆាំងមិនអនុវត្តឲ្យមានសិទ្ធិក្នុងការមានវត្តមានក្នុងអង្គសវនាការនឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការខ្មែរក្រហមចៀសផុតពីការអនុវត្តច្បាប់ហួសហេតុ និងកាត់បន្ថយតុល្យភាពរវាងសិទ្ធិក្នុងការទទួលបានអង្គជំនុំជម្រះដែលមានភាពឆាប់រហ័សនិងសិទ្ធិក្នុងការទទួលបានអង្គជំនុំជម្រះដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ។ **គីមបឺលី អេច**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ វិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់

ខណ្ឌចំការមន ក្រុងភ្នំពេញ

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org;*

*www.cambodiatribunal.org*

# ខ្មែរក្រហមនៅក្នុងបរិបទសង្គ្រាមត្រជាក់

សង្គ្រាមត្រជាក់ហាក់ដូចជានៅឆ្ងាយពីអ្នកគ្រប់គ្នាណាស់នាពេលឥឡូវនេះ ។ សង្គ្រាមនេះបានបញ្ចប់អស់រយៈពេលម្ភៃឆ្នាំកន្លងទៅហើយ ។ ក៏ប៉ុន្តែ សង្គ្រាមត្រជាក់នោះគឺជាធាតុផ្សំមួយយ៉ាងសំខាន់នៅក្នុងប្រវត្តិសាស្ត្រពិភពលោកអស់រយៈពេលជិត ៥០ឆ្នាំ គឺចាប់ផ្តើមពីឆ្នាំ១៩៤៦ហើយបញ្ចប់ទៅវិញនៅដើមទសវត្សរ៍៩០ ។ ប្រទេសកម្ពុជាបានធ្លាក់ចូលទៅក្នុងសង្គ្រាមនេះ ហើយខ្មែរក្រហមមុខជាមិនអាចឡើងកាន់អំណាចបានទេ ប្រសិនបើគ្មានសង្គ្រាមត្រជាក់ ។ ក៏ប៉ុន្តែពលរដ្ឋកម្ពុជាដែលមិនមែនជាកុម្មុយនីស្តភាគច្រើនមិនមានចំណាប់ចំណូលចិត្តជាមួយភាគីណាមួយនៃសង្គ្រាមនេះទេ មានន័យថា អ្នកទាំងនោះមិនដែលចង់នៅខាងលោកសេរីដែលដឹកនាំដោយសហរដ្ឋអាមេរិក ឬក៏ខាងប្លុកកុម្មុយនីស្តដែលដឹកនាំដោយចិននិងសហព័ន្ធសូវៀតទេ ។

នៅចុងទសវត្សរ៍៦០ ពេលដែលកងទ័ពវៀតណាមខាងជើងបានចូលមកតាំងទីក្នុងទឹកដីកម្ពុជាជាសម្ងាត់ ហើយនៅពេលដែលសហរដ្ឋអាមេរិកចាប់ផ្តើមទម្លាក់គ្រាប់បែកមកលើខ្សែបណ្តាញរបស់វៀតណាមនៅក្នុងប្រទេសកម្ពុជានោះ កម្ពុជាត្រូវបានបង្ខំឲ្យធ្លាក់ទៅក្នុងឥទ្ធិពលនៃសង្គ្រាមត្រជាក់ ។ នៅក្រោមរបប លន់ នល់ កម្ពុជាត្រូវបានបង្ខំឲ្យចូលទៅក្នុងលោកសេរី ។ នៅក្រោមរបប ប៉ុល ពត និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ដំបូងកម្ពុជាស្ថិតនៅក្រោមឥទ្ធិពលចិន និងក្រោយមកនៅក្រោមឥទ្ធិពលសូវៀត និងវៀតណាម ។ កម្ពុជាអាចគេចផុតពីសង្គ្រាមត្រជាក់នៅពេលដែលសង្គ្រាមនេះបានបញ្ចប់ទៅនៅឆ្នាំ១៩៨៩ ។ ខ្ញុំនឹងលើកយករយៈកាលនោះមកពិភាក្សា ដោយសារតែឥទ្ធិពលរបស់សង្គ្រាមត្រជាក់ដែលមានមកលើប្រវត្តិសាស្ត្រកម្ពុជា និងការពាក់ព័ន្ធជាពិសេសទៅនឹងខ្មែរក្រហម ដើម្បីដូច្នេះខ្ញុំអាចពិភាក្សាប្រវត្តិសាស្ត្រប្រទេសកម្ពុជាទៅក្នុងបរិបទមួយដ៏ទូលំទូលាយជាងនេះ ។

វិធីមួយទៀតក្នុងការបញ្ចូលប្រវត្តិសាស្ត្រប្រទេសកម្ពុជាចូលទៅក្នុងបរិបទពិភពលោកគឺការសួរសំណួរដូចជា ៈ តើខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យត្រូវតែកើតមានឬយ៉ាងណា? តើការដែលខ្មែរក្រហមត្រូវឡើងកាន់អំណាចជាព្រឹត្តការណ៍មួយដែលមិនអាចចៀសផុត បង្កមកពីកត្តាអន្តរជាតិឬយ៉ាងណា? ខ្ញុំមិនគិតដូច្នេះទេ ប៉ុន្តែខ្ញុំនឹងអះអាងនៅពេលនេះថា ការឡើងកាន់អំណាចរបស់ខ្មែរក្រហមអាចប្រព្រឹត្តទៅបាន ដោយសារតែព្រឹត្តិការណ៍ពីខាងក្រៅដែលកើតមានចាប់តាំងពីខែមីនា ឆ្នាំ១៩៤៥ និងដោយសារតែសង្គ្រាមត្រជាក់ជាជាងដោយមូលហេតុផ្សេងៗទៀត ។

នៅពេលខ្លះ អ្នកប្រវត្តិសាស្ត្រសាកល្បងលេងល្បែងស្រមើស្រមៃអំពីភាពផ្លាស់ប្តូរនៃប្រវត្តិសាស្ត្រ ដោយសួរថាតើនឹងមានរឿងអ្វីខ្លះ ប្រសិនបើព្រឹត្តិការណ៍ណាមួយមិនបានកើតឡើង ។ តើនឹងមានរឿងអ្វីកើតឡើង ប្រសិនបើ ណាប៉ូឡេអុងបានទទួលជ័យជម្នះនៅវ៉ាតធើលូ ឬប្រសិនបើប្រធានាធិបតីអាមេរិក ចន ខេណេឌី មិនត្រូវបានគេធ្វើឃាតនោះ?

មុនពេលដែលខ្ញុំបន្តទៅពិភាក្សាពីទំនាក់ទំនងរវាងខ្មែរក្រហម និងសង្គ្រាមត្រជាក់ ខ្ញុំចង់សួរសំណួរ “ចុះបើ”ជាមុនសិនដូចជា ៈ តើនឹងមានរឿងអ្វីកើតឡើងនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា បើសិនជាជប៉ុនមិនបានប្រគល់អំណាចទៅអាជ្ញាធរក្នុងស្រុកនៅតំបន់ឥណ្ឌូចិននៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥?

ព្រឹត្តិការណ៍ដែលយើងស្ទើរតែភ្លេចពាក់កណ្តាលទៅហើយនោះ ដែលបានកើតមានឡើងក្នុងរយៈពេលមួយឆ្នាំមុនសង្គ្រាមត្រជាក់ចាប់ផ្តើមគឺពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសនៅក្នុងតំបន់ឥណ្ឌូចិន ។ ប្រទេសកម្ពុជាក៏ស្ថិតនៅក្នុងតំបន់ឥណ្ឌូចិននេះដែរ ហើយខ្ញុំជឿជាក់ថា ខ្មែរក្រហមប្រហែលជាមិនអាចឡើងកាន់អំណាចបានទេប្រសិនបើព្រឹត្តិការណ៍ថ្ងៃ៩ ខែមីនា

ឆ្នាំ១៩៨៥ និងព្រឹត្តិការណ៍ដែលកើតឡើងក្នុងរយៈពេលប្រាំមួយខែបន្ទាប់មកនោះមិនកើតមានទេ ។ រយៈពេលពីរបីខែក្រោយមក សង្គ្រាមត្រជាក់បានចាប់ផ្តើម ហេតុនេះរូបភាពប្រវត្តិសាស្ត្រមានភាពច្របូកច្របល់បន្តិច ប៉ុន្តែព្រឹត្តិការណ៍ថ្ងៃទី៩ ខែមីនា កំណត់ឲ្យឃើញពីចំណុចរបត់មួយដ៏សំខាន់នៃប្រវត្តិសាស្ត្រនៅក្នុងតំបន់ ។

ផ្ទុយទៅវិញ ព្រឹត្តិការណ៍ខែមីនាឆ្នាំ១៩៤៥ ក៏កើតឡើងដោយផ្អែកទៅលើកម្រងព្រឹត្តិការណ៍ដែលកើតមានពីមុនៗមកដែរ ។ ព្រឹត្តិការណ៍ទាំងនោះរួមមាន ការឡើងគ្រប់គ្រងរបស់ជប៉ុនមកលើតំបន់ឥណ្ឌូចិនចាប់តាំងពីឆ្នាំ១៩៤១ ការផ្តួលរំលំបារាំងដោយអាល្លឺម៉ង់នៅឆ្នាំ១៩៤០ និងជំនាញរៀបចំ ព្រមទាំងកម្លាំងនយោបាយក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិនដែលបង្កើតឡើងដោយហូជីមិញនៅឆ្នាំ១៩៣០ ។

បក្សកុម្មុយនីស្តឥណ្ឌូចិនគឺជាបក្សសម្ងាត់មានរបៀបរៀបរយប្រកបដោយឧត្តមគតិ និងជាបក្សមិនស្របច្បាប់ ដែលមានគោលដៅបណ្តេញបារាំងចេញពីអំណាច ព្រមទាំងចង់ដាក់បញ្ចូលរបបម៉ាក្សលេនីននៅលើរដ្ឋសក្តិភូមិរបស់ឥណ្ឌូចិន ។ នៅខែមីនាឆ្នាំ១៩៤៥ មេដឹកនាំបក្សជាច្រើនត្រូវបារាំងចាប់ឃុំឃាំង នៅពេលដែលមេដឹកនាំបក្សហូជីមិញ និងកងទ័ពក្រោមបង្គាប់របស់គាត់កំពុងតែបង្កទ័ពនៅលើភ្នំនៅវៀតណាមខាងជើង ។ កាលនោះឱកាសដែលក្រុមនោះអាចទទួលបានអំណាចដូចជាស្តួចស្តើងខ្លាំងណាស់ ។ បន្ទាប់ពីព្រឹត្តិការណ៍ថ្ងៃទី៩ ខែមីនា វាសនារបស់បក្សកុម្មុយនីស្តឥណ្ឌូចិនបានផ្លាស់ប្តូរយ៉ាងគំហុក ហើយអ្វីដែលបក្សបានធ្វើឲ្យមានឥទ្ធិពលយ៉ាងខ្លាំងមកលើប្រវត្តិសាស្ត្រកម្ពុជាទើបតែមាននៅពេលក្រោយមកទេ ។

ដំបូងនេះ ខ្ញុំចង់ជម្រាបជូនបន្តិចអំពីប្រវត្តិខ្លះមុននឹងចូលដល់ខ្លឹមសារសំខាន់ ។

នៅឆ្នាំ១៩៤០ ក្រោយពីប្រទេសបារាំងត្រូវប្រទេសអាល្លឺម៉ង់ផ្តួលរំលំមក បារាំងមិនមានអំណាចអ្វីដើម្បីតស៊ូប្រឆាំងនឹងការវាតទីអំណាចរបស់កងទ័ពជប៉ុនទៅក្នុងទឹកដីឥណ្ឌូចិនទេ ។ រីឯពួកបារាំងដែលនៅនឹងទីតាំងផ្ទាល់ក៏ជ្រើសរើសមិនធ្វើការតស៊ូអ្វីដែរ ដែលផ្ទុយទៅនឹងពួកអង់គ្លេសនៅប្រទេសភូមា និងម៉ាឡេស៊ី ពួកអាមេរិកាំងនៅប្រទេសហ្វីលីពីន និងពួកហូឡង់នៅប្រទេសឥណ្ឌូនេស៊ី ។ ដោយមានការអនុញ្ញាតពីជប៉ុន អាជ្ញាធរបារាំងនៅតែមានអំណាចត្រួតត្រាទៅលើរចនាសម្ព័ន្ធគ្រប់គ្រងប្រចាំថ្ងៃនៅតំបន់ឥណ្ឌូចិន បើទោះជាកងកម្លាំងជប៉ុនបានមកបោះតាំងទីនៅលើទឹកដីឥណ្ឌូចិន- បារាំងក៏ដោយ ។

នៅដើមឆ្នាំ១៩៤១ ក្រោយពីមានសង្គ្រាមមួយរយៈរវាងប្រទេសថៃនិងបារាំងរួចមក ដែលបារាំងបានចាញ់សង្គ្រាមបាត់បង់ទឹកដី ហើយថៃបានចាញ់សង្គ្រាមនៅសមុទ្រ ជនជាតិជប៉ុនបានកាត់ក្តី ដោយឲ្យភាគីទាំងពីរចុះសន្ធិសញ្ញាសន្តិភាពមួយ ដែលសន្ធិសញ្ញានេះផ្តល់ប្រយោជន៍ទៅឲ្យថៃច្រើនជាង ។ ខេត្តបាត់ដំបង និងសៀមរាប (លើកលែងទីតាំងតំបន់អង្គរ) ក៏ដូចជាផ្នែកខ្លះនៃប្រទេសឡាវត្រូវបានប្រគល់ទៅឲ្យប្រទេសថៃជាអ្នកគ្រប់គ្រង ។

បួនឆ្នាំក្រោយមក បារាំងនិងជប៉ុនក្លាយជាសម្ព័ន្ធមិត្តនឹងគ្នា ប៉ុន្តែសម្ព័ន្ធមិត្តនេះមានសភាពទន់ខ្សោយ ផុយស្រួយ មិនរឹងមាំ និងជាការគំរាមកំហែងដល់បារាំង ។ រហូតដល់ចុងឆ្នាំ១៩៤៤ ជប៉ុនដឹងស្ទើរតែច្បាស់ណាស់ថាខ្លួននឹងចាញ់សង្គ្រាម ។ ទន្ទឹមនឹងនោះដែរ នៅប្រទេសបារាំង រដ្ឋាភិបាលបង្កើតថ្មីរបស់ ហ្សាលដឺហ្គោល ចង់ចូលរួមនៅក្នុងសង្គ្រាមប៉ាស៊ីហ្វិក ប៉ុន្តែបារាំងមិនបញ្ជូនទ័ពទៅកាន់តំបន់នោះទេ ហើយចង់បង្កើតនូវចលនាតស៊ូសម្ងាត់ និងមិនសូវមានប្រសិទ្ធភាពនៅតំបន់ឥណ្ឌូចិន ។ ជប៉ុនបានដឹងពីដំណើរវិវឌ្ឍន៍នេះ ។ ជប៉ុនក៏មានការភ័យខ្លាចចំពោះការវាយលុកពីសំណាក់សម្ព័ន្ធមិត្តដែរ ។ ដោយសារខ្លួនជាអ្នកជាតិនិយមមួយនៅអាស៊ី ខ្លួនមិនចង់ឲ្យអឺរ៉ុបត្រឡប់មកកសាងអាណានិគមឡើងវិញនោះទេ ។ ជប៉ុនដើរតាមគោលនយោបាយមួយគឺ «អាស៊ីដើម្បីជនជាតិអាស៊ី» ដែលទាញបាននូវការគាំទ្រពីសំណាក់ប្រជាជននៅក្នុងតំបន់ រួមទាំងតំបន់ឥណ្ឌូចិន- បារាំង កន្លែងដែលបារាំងបានធ្វើការគាបសង្កត់ទៅលើអ្នកជាតិនិយម ។ គោលនយោបាយនេះក៏ទាក់ទាញការចាប់អារម្មណ៍ជាពិសេសពីបក្សកុម្មុយនីស្តឥណ្ឌូចិន គណបក្សដែលបារាំងមើលឃើញថាជាគំរាមកំហែងដល់ការធ្វើអាណានិគមរបស់ខ្លួន ។ កាលនោះ គំនិតជាតិនិយមនៅមិនទាន់មានភាពខ្លាំងក្លានៅឡើយ រីឯគណបក្សនយោបាយក៏មិនទាន់បង្កើតនៅឡើយដែរ ។ នៅមុនឆ្នាំ១៩៤៦ ប្រទេសកម្ពុជាមិនទាន់មានគណបក្សនយោបាយមួយនៅឡើយ ។

នៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ អាជ្ញាធរជប៉ុនបានវាយឈ្នះបារាំងដោយទឹកស្មានមិនដល់ ។ ជប៉ុនបានធ្វើការផ្តួលរំលំបារាំង ដោយកងទ័ពចាប់មន្ត្រី និងទាហានបារាំងដាក់មន្ទីរឃុំឃាំង ។ ជប៉ុនផ្តល់ប្រឹក្សាដល់មេដឹកនាំប្រទេសនៅឥណ្ឌូចិន (រួមមានអធិរាជវៀតណាម ស្តេចលាវ និងសម្តេចព្រះនរោត្តម សីហនុ ដែលមានព្រះជន្មទើបតែម្ភៃបីព្រះវស្សា) ឲ្យធ្វើការប្រកាសឯករាជ្យ ។

នៅពីរបីខែក្រោយមក ជប៉ុនបានធ្វើការដោះលែងអ្នកទោសនយោបាយ ដែលក្នុងនោះភាគច្រើនជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិនចេញពីមន្ទីរឃុំឃាំងអាណានិគម ។ អ្នកទាំងនេះភាគច្រើនចេញធ្វើការតស៊ូនយោបាយភ្លាមៗ ជាពិសេសនៅវៀតណាមខាងជើង ដោយមិនខ្លាចត្រូវគេចាប់ខ្លួនម្តងទៀតឡើយ ។

នៅពេលនោះ ក្រុមតស៊ូរបស់បក្សកុម្មុយនីស្តឥណ្ឌូចិនដោយគ្មានការគំរាមកំហែងពីកងកម្លាំងទាហានបារាំងបានផ្លាស់ចេញពីតំបន់ជួរភ្នំដែលខ្លួនធ្លាប់លាក់ខ្លួននៅតាមបណ្តោយព្រំដែនប្រទេសចិន ហើយបានកាន់កាប់តំបន់វៀតណាមភាគខាងជើងយ៉ាងស្ងៀមស្ងាត់ ។ ជប៉ុនមិនបានចាត់វិធានការណាមួយដើម្បីការពារកុំឲ្យរឿងនេះកើតឡើងទេ ហើយនៅខែកញ្ញា ឆ្នាំ១៩៤៥ ក្រោយពីជប៉ុនបានចុះចាញ់សម្ព័ន្ធមិត្តជាផ្លូវការនៅប្រទេសជប៉ុន ហើយនៅពេលដែលកងកម្លាំងបារាំងនៅឥណ្ឌូចិនស្ថិតក្នុងការឃុំឃាំងនៅឡើយ ហូ ជីមិញ បានថ្លែងប្រកាសនៅមហាសន្និបាតដ៏ធំមួយនៅហាណូយថា វៀតណាមបានទទួលឯករាជ្យពេញបរិបូរណ៍ហើយ តែវាមិនមែនជាឯករាជ្យដែលជាអំណោយពីជប៉ុននោះទេ ជារបបដែលបង្កើតឡើងដោយអធិរាជវៀតណាម បៅដាយ បានធ្វើការលាលែងចេញពីតំណែងភ្លាមៗនោះដែរ ។ បន្ទាប់ពីការបំពាក់អាវុធរបស់ជប៉ុន របបថ្មីដែលដឹកនាំដោយបក្សកុម្មុយនីស្តឥណ្ឌូចិនបានរៀបចំខ្លួន ដើម្បីចរចាជាមួយបារាំង ដោយឈរលើជំហរមួយរឹងមាំ ។

ស្ថានភាពនៅក្នុងប្រទេសកម្ពុជាប៉ុន្មានខែក្រោយពីការបង្ក្រាបដោយកម្លាំងរបស់ជប៉ុនមានសភាពមិនច្បាស់លាស់ ។ គ្មានគណបក្សនយោបាយទាំងឡាយណាអាចធ្វើការប្រកាសឯករាជ្យពេញបរិបូណ៌បាននោះទេ ហើយពេលនោះសម្តេចព្រះនរោត្តម សីហនុ មានព្រះជន្មទើបតែម្ភៃបីព្រះវស្សា ដូច្នេះទ្រង់មិនអាចរៀបចំខ្លួនដើម្បីឈានជំហានដ៏គំហុកនេះដោយខ្លួនទ្រង់បានទេ ។ ផ្ទុយទៅវិញ អ្នកស្នេហាជាតិ សឺង ង៉ុកថាញ់ នាយករដ្ឋមន្ត្រីដែលជប៉ុនបានតែងតាំងព្យាយាមរក្សាឯករាជ្យភាពដ៏ទន់ខ្សោយរបស់ប្រទេសកម្ពុជា ដោយគ្មានជំនួយឧបត្ថម្ភ ឬអាវុធអ្វីទាំងអស់ ។ ប៉ុន្តែ សឺង ង៉ុកថាញ់ គ្មានលទ្ធភាពនឹងធ្វើដូច្នោះទេ ។ បារាំងបាននាំកម្លាំងត្រឡប់ទៅវៀតណាមខាងត្បូងនៅខែតុលា ឆ្នាំ១៩៤៥ ហើយបានធ្វើការដោះលែងមន្ត្រី និងទាហានដែលជប៉ុនបានឃុំខ្លួន ។ ភ្លាមៗនោះបារាំងបានចាប់ខ្លួន សឺង ង៉ុកថាញ់ ។ សម្តេចព្រះនរោត្តម សីហនុ ប្រហែលជាស្ទាក់ស្ទើរ ឬមិនស្ទាក់ស្ទើរក្នុងការស្វាគមន៍ការវិលត្រឡប់មកវិញរបស់បារាំង ។

ប្រសិនបើជប៉ុនមិនត្រូវបានធ្វើការផ្តួលរំលំនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ បារាំងប្រហែលនឹងនៅគ្រប់គ្រងឥណ្ឌូចិនរហូតដល់ចុងបញ្ចប់សង្គ្រាមលោកលើកទីពីរ ។ ប្រសិនបើពិតជាដូច្នោះមែន វៀតណាមប្រាកដជាមិនអាចប្រកាសឯករាជ្យភាពរបស់ខ្លួនដោយបង្ខំយ៉ាងនេះទេ ហើយចលនាឯករាជ្យកម្ពុជា (មិននិយាយដល់ខ្មែរក្រហម) ប្រហែលជាត្រូវការពេលវែងជាងនេះដើម្បីវិវឌ្ឍខ្លួន ។ រឿងមួយទៀតក៏អាចទៅរួចដែរគឺថា ចលនាមិនមែនកុម្មុយនីស្តដើម្បីឆ្ពោះទៅកាន់ឯករាជ្យក៏អាចនឹងកើតមានឡើង ។

ជាការពិតណាស់ ព្រឹត្តិការណ៍ថ្ងៃទី៩ ខែមីនា បានកើតមានឡើង ហើយព្រឹត្តិការណ៍ដែលកើតមកតាមក្រោយគឺស្ទើរតែមិនអាចចៀសផុតបានទេ ។

នៅចុងឆ្នាំ១៩៤៥ បារាំងដឹងថាខ្លួនត្រូវតែធ្វើសម្បទានខ្លះទៅឲ្យឥណ្ឌូចិន យ៉ាងហោចណាស់ក៏នៅខណៈពេលខ្លួនមានកងទ័ពតិចតួចប៉ុណ្ណោះនៅតាមមូលដ្ឋាន ។ ប្រជាជនកម្ពុជាមួយចំនួនរួមទាំងសម្តេចព្រះនរោត្តម សីហនុ នៅមានសេចក្តីរីករាយជាមួយនឹងរស់ជាតិរបស់ឯករាជ្យភាពដ៏ខ្លីនេះ ប៉ុន្តែអ្នកទាំងអស់នេះក៏បានដឹងថា ក្រោយពីព្រឹត្តិការណ៍ថ្ងៃ៩ ខែមីនា បារាំងមិនសូវជារឹងមាំដូចកាលពីមុននោះទេ ។ គ្រាប់ពូជឯករាជ្យបានដាំរួចទៅហើយ ។ ប្រឈមមុខនឹងស្ថានភាពថ្មីនេះ បារាំងបានធ្វើការចរចាដោយប្រុងប្រយ័ត្នជាមួយកម្ពុជាចំពោះបញ្ហាចំណងទំនាក់ទំនងរវាងប្រទេសទាំងពីរ ។

នៅដើមឆ្នាំ១៩៤៦ បារាំងបានយល់ព្រមអនុញ្ញាតឲ្យគណបក្សនយោបាយ នៅកម្ពុជាបង្កើតរដ្ឋធម្មនុញ្ញ (ជាលើកដំបូងបំផុតនៅកម្ពុជា) និងបោះឆ្នោតជ្រើសរើសសមាជិកសភា ។ គណបក្សប្រជាធិបតេយ្យប្រឆាំងបារាំងដែលត្រូវបានបង្កើតឡើងនៅពេលនោះបានឈ្នះការបោះឆ្នោតនៅឆ្នាំ១៩៤៦និងឆ្នាំ១៩៤៧ ។ ចលនានយោបាយនេះបានធ្វើឲ្យបារាំងមានកង្វល់ជាខ្លាំង បើទោះបីជាបក្សប្រជាធិបតេយ្យនេះមិនសូវជាមានឥទ្ធិពលក៏ដោយ ។ ទោះជាយ៉ាងណាក្តី បារាំងនៅតែជាអ្នកទទួលបន្ទុកក្នុងការចំណាយទាំងអស់នៅកម្ពុជា ហើយបក្សប្រជាធិបតេយ្យក៏គ្មានអាវុធដើម្បីចាត់វិធានការអ្វីមួយដែរ ។

ច្បាប់រដ្ឋធម្មនុញ្ញថ្មីត្រូវបានតាក់តែងឡើងទៅតាមគំរូរបស់រដ្ឋធម្មនុញ្ញរបស់បារាំង (ជាគំរូតែមួយគត់ដែលកម្ពុជាធ្លាប់ឃើញ) ហើយអនុញ្ញាតឲ្យមានប្រធានរដ្ឋ និងសភាជាតិ ដែលមានសិទ្ធិអំណាចតិចតួច ប៉ុន្តែអំណាចពិតប្រាកដនៅតែនៅក្រោមកណ្តាប់ដៃរបស់បារាំងដដែល ។ នៅឆ្នាំ១៩៤៥-១៩៤៩ កម្ពុជាស្ថិតនៅឆ្ងាយពីឯករាជ្យភាពនៅឡើយទេ ហើយបារាំងនៅមិនទាន់ប្រឈមមុខនឹងការតស៊ូដោយអាវុធធំដុំនៅឡើយដែរ ។ ទោះជាមិនមានអំណាច សម្តេចព្រះនរោត្តម សីហនុ ក៏មិនមានអារម្មណ៍ថាត្រូវបានទទួលការគំរាមកំហែងដោយការរៀបចំរចនាសម្ព័ន្ធដូចនេះដែរ ជាពិសេសដោយសារទ្រង់នៅពេញចិត្តនឹងការជួយគាំទ្ររបស់បារាំងនៅឡើយ ។

នៅក្នុងដំណើរវិវឌ្ឍមួយទៀត នៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ ប្រទេសថៃដែលមានអ្នកដឹកនាំតែងតែប្រឆាំងនឹងការដាក់អាណាព្យាបាលរបស់បារាំងព្យាយាមផ្តល់ការជ្រកកោនដល់អ្នកជាតិនិយមកម្ពុជា ហើយបានធ្វើការឧបត្ថម្ភចលនាឯករាជ្យកម្ពុជាដែលមិនមែនជាកុម្មុយនីស្តដែលត្រូវបានស្គាល់ថាជាខ្មែរឥស្សរៈ ។ ចលនានោះនៅមានទំហំតូច គ្មានការដឹកនាំច្បាស់លាស់ ហើយគ្មានគ្រឿងសព្វាវុធ ដែលខុសពីចលនាកុម្មុយនីស្តនៅវៀតណាមខាងជើង ។ ចលនានេះមិនអាចភ្ជាប់ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលប្រជាធិបតេយ្យថ្មីនៅភ្នំពេញដែលអ្នកដឹកនាំរដ្ឋាភិបាលនោះសង្ឃឹមថានឹងសម្រេចបាននូវឯករាជ្យបន្តិចម្តងៗ ដោយគ្មានការតស៊ូអាវុធ ។ ក្នុងករណីណាក៏ដោយ អស់រយៈពេលពីរបីឆ្នាំក្រោយមក ថៃដែលជាដៃគូរបស់ខ្លួនបានបោះបង់ចោលចលនានេះ ហើយសមាជិករបស់ចលនានេះជាច្រើនជាពិសេសនៅប្រទេសកម្ពុជាភាគខាងកើតបានចូលរួមក្នុងការតស៊ូដែលដឹកនាំដោយបក្សកុម្មុយនីស្តឥណ្ឌូចិនប្រឆាំងនឹងបារាំង ។

ពេលនោះដែរ សង្គ្រាមត្រជាក់បានផ្ទុះឡើងក្រោយពីសង្គ្រាមលោកលើកទីពីរបញ្ចប់ទៅមិនយូរប៉ុន្មានផង ។ បក្សកុម្មុយនីស្តដែលគាំទ្រដោយសហភាពសូវៀតបានចូលគ្រប់គ្រងប្រទេសមួយចំនួននៅអឺរ៉ុបខាងកើត រួចគំរាមថានឹងមកគ្រប់គ្រងនៅផ្នែកខ្លះនៃអឺរ៉ុបខាងលិចទៀត ។ បក្សកុម្មុយនីស្តរបស់បារាំងមានឥទ្ធិពលខ្លាំងនិងមានអំណាចជាងគេនៅតំបន់អឺរ៉ុប ។ សហរដ្ឋអាមេរិកដែលបានហៅខ្លួនឯងថាមេដឹកនាំរបស់លោកសេរីមានការភ័យខ្លាចចំពោះជ័យជម្នះរបស់កុម្មុយនីស្តនៅបារាំង ហើយមានទស្សនវិស័យថា សង្គ្រាមត្រជាក់គឺជាការប្រឈមមុខដាក់គ្នាជាសកលរវាងពួកល្អនិងពួកអាក្រក់ ។ ការបកស្រាយស្ថានការណ៍តាមរយៈសាសនានេះហាក់ដូចជាត្រូវ នៅពេលដែលកុម្មុយនីស្តបានចូលទៅគ្រប់គ្រងលើប្រទេសចិនឆ្នាំ១៩៤៩ និងពេលដែលកុម្មុយនីស្តវាយលុកទៅលើកូរ៉េខាងត្បូងនៅខែមិថុនា ឆ្នាំ១៩៥០ ។

ជ័យជម្នះរបស់កុម្មុយនីស្តនៅប្រទេសចិនបានផ្លាស់ប្តូរមុខមាត់របស់សង្គ្រាមឥណ្ឌូចិនដំបូងដែលប្រឈមមុខដាក់គ្នារវាងបារាំងនិងចលនាតស៊ូនៅនៅឥណ្ឌូចិន ជាពិសេសនៅវៀតណាមខាងជើងនៅចុងឆ្នាំ១៩៤៦ ។ ក្នុងរយៈពេលបីបួនឆ្នាំ បារាំងបានទទួលផលចំណេញពីកងទ័ព ប៉ុន្តែក្រោយពីនោះមកមិនយូរប៉ុន្មាន នៅឆ្នាំ១៩៤៩ ចិនបានផ្តល់មូលដ្ឋានស្នាក់នៅ អាវុធនិងការគាំទ្រទៅដល់ចលនាវៀតណាមកាន់តែច្រើនឡើងៗ ។ នៅឆ្នាំ១៩៥០ វៀតណាមចាប់ផ្តើមវាយលុក ហើយឈ្នះសង្គ្រាមជាមួយបារាំង ។

នៅឆ្នាំ១៩៤៩ ក្នុងបរិបទនៃដំណើរវិវឌ្ឍនេះ បារាំងអាចបញ្ចុះបញ្ចូលមន្ត្រីអាមេរិកថា សង្គ្រាមឥណ្ឌូចិនដំបូងមិនមែនជាសង្គ្រាមដែលឆ្លើយតបទៅនឹងការគាបសង្កត់របស់អាណានិគមនោះទេ ប៉ុន្តែជាផ្នែកមួយដ៏សំខាន់នៃសង្គ្រាមសកលប្រឆាំងនឹងកុម្មុយនីស្ត ។ សហរដ្ឋអាមេរិកខឹងសម្បាទៅនឹងការបាត់បង់ប្រទេសចិនដែលយល់ព្រមថានឹងផ្តល់ជំនួយផ្នែកយោធាដ៏ធំដល់ប្រទេសបារាំង តែតាមរយៈប្រទេសនៅតំបន់ឥណ្ឌូចិនតែប៉ុណ្ណោះ ។

នៅចុងឆ្នាំ១៩៤៩ បារាំងបានយល់ព្រមផ្តល់ឲ្យនូវអ្វីដែលសម្តេចសីហនុ ហៅថា "ឯករាជ្យ៥០ភាគរយ" សម្រាប់ប្រទេសកម្ពុជា ឡាវ និងផ្នែកខ្លះនៃប្រទេសវៀតណាម ។ អំណាចទៅលើផ្នែកហិរញ្ញវត្ថុ ការពារជាតិ និងកិច្ចការបរទេសនៅតែស្ថិតនៅក្នុងកណ្តាប់ដៃបារាំងដដែល ។

ដោយមិនបានកត់សម្គាល់កាលពីមុនទិដ្ឋភាពសំខាន់មួយនៃការរៀបចំដារចនាសម្ព័ន្ធរបស់បារាំងខាងលើនេះគឺថា ក្រសួងអប់រំរបស់កម្ពុជាបានស្ថិតនៅក្រោមការគ្រប់គ្រងប្រជាជនក្នុងតំបន់ ហើយបក្សប្រជាធិបតេយ្យប្រឆាំងនឹងបារាំងអាចធ្វើការប្រមែប្រមូលឈ្មោះនិស្សិតដែលបានបញ្ជូនឲ្យទៅរៀននៅប្រទេសបារាំងបាន ។ និស្សិតដែលគាំទ្រលទ្ធិប្រជាធិបតេយ្យមានឈ្មោះនៅឆ្នាំ១៩៤៩-១៩៥២ រួមមាន ប៉ុល ពត, សុន សេន, អៀង សារី និងខៀវ សំផន ដែលអ្នកទាំងអស់នោះបានក្លាយជាសមាជិកបក្សកុម្មុយនីស្តបារាំង រួមទាំងនិស្សិតផ្សេងទៀតដែលមិនបានក្លាយជាសមាជិកបក្សទេ ។

នៅចុងទសវត្សរ៍៤០ និងដើមទសវត្សរ៍៥០ នៅតាមបណ្តោយព្រំដែនខាងកើតនៃប្រទេសកម្ពុជា ពួកខុទ្ទាមកុម្មុយនីស្តវៀតណាម ឬហៅថាវៀតមិញ បានជ្រើសរើសយុវជនខ្មែរមួយចំនួនដែលកុម្មុយនីស្តវៀតណាមចាត់ទុកថាជាក្រុមអ្នកតស៊ូឥណ្ឌូចិនជាជាងជាក្រុមអ្នកតស៊ូខ្មែរដើម្បីជួយខ្លួនធ្វើការតស៊ូប្រឆាំងនឹងបារាំង ។ នៅឆ្នាំ១៩៥១ ពេលដែលសង្គ្រាមកាន់តែមានសភាពដុនដាបទោសម្រាប់បារាំង វៀតណាមបានជួយបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ ។ មេដឹកនាំបក្សនេះគឺជាខ្មែរដែលទទួលឥទ្ធិពលពីវៀតណាម ។

ហេតុនេះ ប្រសិនបើយើងចាត់ទុកនិស្សិតដែលទៅរៀននៅប៉ារីសថាជាអ្នកស្នេហាជាតិ ហើយមានចិត្តចង់បណ្តេញបារាំងចេញពីអំណាច (ទោះជាក្រោយមកអ្នកទាំងនោះបានប្រព្រឹត្តអំពើឃោរឃៅជាច្រើនក៏ដោយ) យើងឃើញថា រហូតដល់ដើមទសវត្សរ៍៥០ មានខ្មែរបណ្តាញកម្ពុជាបីដែលប្រឆាំងនឹងបារាំង ។ ខ្សែបណ្តាញមួយក្នុងចំណោមនោះដែលគ្រប់គ្រងដោយវៀតណាមស្ថិតនៅជិតគ្នានៅភាគខាងកើតនៃប្រទេសដែលទទួលបានការគាំទ្រមួយចំណែកធំពីកសិករក្រីក្រ ។ ក្រុមអ្នកតស៊ូទីពីរដែលក្រោយមកក្លាយទៅជាក្រុមមនុស្សសំខាន់ដែរនោះស្ថិតនៅក្នុងចំណោមនិស្សិតមកពីសិក្សានៅប្រទេសបារាំងដែលប្រែក្លាយទៅជាអ្នកជាតិនិយមប្រឆាំងនឹងនិន្នាការវៀតណាមជាជាងជាជនជាតិកម្ពុជាដែលវាយប្រឆាំងនឹងបារាំងពិតប្រាកដ ។ ក្រុមទីបី គឺក្រុមដែលមានសភាពស្ងប់ស្ងាត់ជាងគេដែលក្នុងនោះរួមមាន ខាងក្រុមប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា និងអ្នកផ្សេងទៀតដែលរួមមានទាំងសម្តេចព្រះនរោត្តម សីហនុ ដែលចង់បានឯករាជ្យពីបារាំងដោយមិនចាំបាច់ធ្វើការតទល់គ្នាដោយអាវុធ ។ ពីរក្រុមខាងលើដំបូង មួយក្រុមគាំទ្រដោយវៀតណាម និងមួយក្រុមទៀតរួមមានប្រជាជនកម្ពុជាដែលបានក្លាយជាក្រុមកុម្មុយនីស្តនៅប្រទេសបារាំងសុទ្ធតែមានជាប់ពាក់ព័ន្ធទៅនឹងសង្គ្រាមត្រជាក់ ។ ក្រុមទីបីមិនជាប់ពាក់ព័ន្ធ ឬអាចនិយាយបានថា មិនទាន់ជាប់ពាក់ព័ន្ធ? ប្រសិនបើយើងធ្វើការកត់សម្គាល់ថា គ្មានក្រុមអ្នកជាតិនិយមស្មោះត្រង់នៅមុនឆ្នាំ១៩៥៥ទេនោះ យើងអាចឃើញបុព្វការីជននៃក្រុមនយោបាយទាំងបួនដែលកើតចេញពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ។

ការតស៊ូប្រយុទ្ធគ្នាភាគច្រើននៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយបានបង្កឡើងនៅវៀតណាមភាគខាងជើង ហេតុនេះ អ្នកគាំទ្ររបស់បក្សប្រជាជនបដិវត្តន៍ខ្មែរទទួលបាននូវបទពិសោធន៍ចម្បាំងតិចតួច ។ ទោះជាយ៉ាងនេះក៏ដោយ អ្នកគាំទ្រភាគច្រើនដែលបានទទួលនូវការបណ្តុះបណ្តាលផ្នែកនយោបាយពីវៀតណាមបានធ្វើការបណ្តុះបណ្តាលអ្នកដែលបញ្ចុះបញ្ចូលខ្លួនថា រដ្ឋកុម្មុយនីស្តអាចនឹងក្លាយទៅជារាជរដ្ឋបាន ។ និស្សិតកុម្មុយនីស្តនៅប្រទេសបារាំងយល់ស្រប ប៉ុន្តែសង្ឃឹមថា រដ្ឋបែបនេះនឹងនៅឯករាជ្យពីការគ្រប់គ្រងរបស់វៀតណាម ។ ការតស៊ូទាំងពីរនេះសុទ្ធតែមានការឆ្លើយតបទៅនឹងឥទ្ធិពលរបស់បរទេសពីបក្សកុម្មុយនីស្តឥណ្ឌូចិននៅឥណ្ឌូចិន និងពីបក្សកុម្មុយនីស្តបារាំងនៅបារាំង ។ ក្រុមតស៊ូដែលមានសភាពស្ងប់ស្ងាត់ជាងនេះបានឆ្លើយតបទៅនឹងលក្ខខណ្ឌនៅក្នុងប្រទេសកម្ពុជា ហើយមិនបានទទួលឥទ្ធិពលពីសង្គ្រាមត្រជាក់ លើកលែងតែសង្គ្រាមត្រជាក់ធ្វើឲ្យបារាំងផ្តល់អំណាចឲ្យពួកប្រជាធិបតេយ្យកាន់តែច្រើននៅឆ្នាំ១៩៤៩ ។

ពេលដែលសង្គ្រាមមានសភាពកាន់តែដុបដាបសម្រាប់បារាំង

ហើយដោយសារអ្នកប្រជាធិបតេយ្យបានពង្រឹងកម្លាំងនយោបាយនៅភ្នំពេញ សម្តេចព្រះនរោត្តម សីហនុ ក៏ធ្វើការសម្រេចចិត្តវាយប្រហារដោយអង្គឯង ។ នៅឆ្នាំ១៩៥២-៥៣ ព្រះរាជបូជនីយកិច្ចដ៏ឈ្លាសវៃរៀបចំបានយ៉ាងល្អ និងទាន់ពេលវេលាដើម្បីទាមទារឯករាជ្យភាព ធ្វើឲ្យបារាំងប្រគល់ឯករាជ្យមកឲ្យប្រទេសកម្ពុជាវិញនៅចុងឆ្នាំ១៩៥៣ ហើយធ្វើឲ្យប្រជាជនកម្ពុជាមួយចំនួនធំជឿជាក់ថា ព្រះអង្គបានទទួលសមិទ្ធផលនេះតែម្នាក់ឯង ។ ក្នុងន័យនេះ ប្រជាជនទាំងអស់នេះយល់ត្រូវចំពោះប្រទេសបារាំងដែលថាប្រទេសបារាំងនឹងមិនចរចាអំពីឯករាជ្យភាពរបស់កម្ពុជាជាមួយអ្នកប្រជាធិបតេយ្យទេ ដែលបារាំងមិនជឿទុកចិត្ត ហើយប្រជាជនមិនចរចាជាមួយវៀតណាមដែលធ្វើការគ្រប់គ្រងបក្សប្រជាជនបដិវត្តន៍ខ្មែរដែរ ។

នៅក្នុងរដូវក្តៅក្នុងឆ្នាំ១៩៥៤ បន្ទាប់ពីការប្រយុទ្ធគ្នានៅសមរភូមិដៀនបៀនភូ សង្គ្រាមឥណ្ឌូចិនលើកទី១ត្រូវបានបញ្ចប់ដោយប្រទេសបារាំងទទួលរងនូវបរាជ័យដ៏គួរឲ្យអាម៉ាស់ ។ ដោយសារតែមេដឹកនាំមិនមែនកុម្មុយនីស្តនៅវៀតណាម និងឡាវមិនទាន់អាចរើបម្រះទាមទារសេរីភាពពីប្រទេសបារាំងបាន មេដឹកនាំទាំងនេះមិនសូវមានឥទ្ធិពលដូចគណៈប្រតិភូកម្ពុជានៅឯសន្និសីទក្រុងហ្សឺណែវដែលសន្និសីទនេះរៀបចំឡើងដើម្បីបញ្ចប់សង្គ្រាម ។ គណៈប្រតិភូកម្ពុជាអាចទាមទារបាននូវសម្បទានជាច្រើនពីប្រទេសបារាំង និងពីវៀតណាមកុម្មុយនីស្តនៅឯក្រុងហ្សឺណែវ ។ សម្បទានទាំងនេះបានបម្រើផលប្រយោជន៍ដល់កម្ពុជាយ៉ាងល្អបំផុតសម្រាប់រយៈពេលដប់ប្រាំឆ្នាំក្រោយមក ។

បន្ទាប់ពីការបរាជ័យរបស់បារាំង សហរដ្ឋអាមេរិកបានបង្កើតសម្ព័ន្ធមិត្តមួយដើម្បីប្រឆាំងនឹងកុម្មុយនីស្តដែលមានឈ្មោះថា សេអាតូ ។ សហរដ្ឋអាមេរិកសង្ឃឹមថា សេអាតូ នេះនឹងអាចទប់ស្កាត់ការរីករាលដាលនៃរបបកុម្មុយនីស្តនៅក្នុងតំបន់បាន ។ ជាអកុសលសម្រាប់សហរដ្ឋអាមេរិកនាពេលនោះមានតែប្រទេសអាស៊ីអាគ្នេយ៍ពីរប៉ុណ្ណោះ ពោលគឺប្រទេសថៃ និងហ្វីលីពីន ដែលចូលរួមនៅក្នុងសម្ព័ន្ធមិត្តនេះ ។

នៅក្នុងឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តម សីហនុ ដែលកំពុងមានប្រជាប្រិយភាពនៅក្នុងប្រទេសកម្ពុជាបានចូលរួមនៅក្នុងសន្និសីទប្រទេសមិនចូលបក្សសម្ព័ន្ធនៅបានឌុងប្រទេសឥណ្ឌូនេស៊ី ។ នៅទីនោះ ព្រះអង្គបានក្លាយជាមិត្តភក្តិរបស់មេដឹកនាំចិន ជូអេនឡាយ ប្រធានាធិបតី នេរុហ៍ របស់ឥណ្ឌា ប្រធានាធិបតី ស៊ូកាណូ របស់ឥណ្ឌូនេស៊ី និងមេដឹកនាំពិភពលោកផ្សេងទៀត ។ ព្រះអង្គបានជឿជាក់ភ្លាមៗថា គោលនយោបាយការបរទេសមិនចូលបក្សសម្ព័ន្ធនឹងអាចធ្វើឲ្យប្រទេសកម្ពុជាចាកចេញផុតពីសង្គ្រាមត្រជាក់ ហើយការធ្វើបែបនេះនឹងផ្តល់ផលប្រយោជន៍ដល់កម្ពុជាច្រើនជាងធ្វើជាសម្ព័ន្ធមិត្តរបស់លោកសេរី ឬប្លុកសូវៀត ។

នៅពេលដែលសម្តេចព្រះនរោត្តម សីហនុ កាន់អំណាច ព្រះអង្គទទួលជំនួយបរទេសពីប្រទេសជាច្រើនដែលព្រមផ្តល់ជំនួយ ប៉ុន្តែព្រះអង្គបានបដិសេធជំនួយពីសហរដ្ឋអាមេរិកនៅក្រោយឆ្នាំ១៩៦៣ ។ នៅក្នុងស្រុក ព្រះអង្គបានធ្វើទុក្ខបុកម្នេញក្រុមប្រឆាំងប្រកាន់លទ្ធិកុម្មុយនីស្តយ៉ាងខ្លាំង ។ ចលនាកុម្មុយនីស្តកម្ពុជានៅពេលនោះនៅមានលក្ខណៈតូចតាច និងបាក់បែកនៅឡើយ ។ តាមរយៈការរាប់អានមិត្តភក្តិមានអំណាចទាំងសងខាងនៃសង្គ្រាមត្រជាក់ និងទទួលយកជំនួយពីប្លុកទាំងពីរនេះ សម្តេចព្រះនរោត្តម សីហនុ និងប្រទេសកម្ពុជាទទួលបាននូវផលប្រយោជន៍ពីសង្គ្រាមត្រជាក់ទៅវិញនៅមុនដំបូង ប៉ុន្តែក្រោយមក សម្តេចព្រះនរោត្តម សីហនុ និងប្រទេសកម្ពុជាបានក្លាយទៅជាជនរងគ្រោះនៃសង្គ្រាមត្រជាក់មួយនេះ ។

ក្រោយមកនៅឆ្នាំ១៩៥៥ សម្តេចព្រះនរោត្តម សីហនុ អាចយកគំនិតរបស់ទ្រង់មកអនុវត្តបាន នៅពេលដែលព្រះអង្គបានដាក់រាជ និងបង្កើតជាចលនានយោបាយមួយដែលមានឈ្មោះថា សង្គមរាស្ត្រនិយម ។ បេក្ខជនសង្គមរាស្ត្រនិយមដែលត្រូវបានជ្រើសរើសដោយផ្ទាល់ដោយសម្តេចព្រះនរោត្តម សីហនុ បានឈ្នះការបោះឆ្នោតសភានៅក្នុងឆ្នាំ១៩៥៥ ។ អតីតព្រះមហាក្សត្រដែលមានជំនឿចិត្ត និងស្វាហាប់ បានក្លាយទៅជាប្រមុខរដ្ឋដ៏មានប្រសិទ្ធភាព ។

ខ្ញុំជឿជាក់ថា គោលនយោបាយអព្យាក្រឹតរបស់សម្តេចព្រះនរោត្តម សីហនុ និងការព្យាយាមមិនលូកដៃចូលទៅក្នុងសង្គ្រាមត្រជាក់ គឺពិតជាត្រឹមត្រូវណាស់សម្រាប់កម្ពុជា ដរាបណាអ្នកចូល

ប្រឡូកនៅក្នុងសង្គ្រាមត្រជាក់ ដែលរួមទាំងវៀតណាមខាងជើងនិងសហរដ្ឋអាមេរិកទុកឲ្យប្រទេសកម្ពុជានៅតែឯង ។ អព្យាក្រឹតភាពរបស់សម្តេចព្រះនរោត្តម សីហនុ គឺពឹងផ្អែកទៅលើឆន្ទៈនយោបាយរបស់ប្រទេសមានអំណាចទាំងឡាយ ។ ចាប់ពីពាក់កណ្តាលទសវត្សរ៍៦០ វាមានផលប្រយោជន៍សម្រាប់ប្រទេសមានអំណាចទាំងនេះក្នុងការព្រងើយកន្តើយ និងរំលោភលើអព្យាក្រឹតភាពរបស់កម្ពុជា ហើយចាប់ពីនេះដែលពេលវេលាសម្រាប់សម្តេចព្រះនរោត្តម សីហនុ និងប្រជាជនខ្មែរទាំងអស់កាន់តែមានតិចតួច ។ ស្របពេលនោះ វាពិតជាលំបាកសម្រាប់សម្តេចព្រះនរោត្តម សីហនុ ក្នុងការជ្រើសរើសជម្រើសអ្វីផ្សេងក្រៅពីនេះ ។ ការបងសម្ព័ន្ធមិត្តជាមួយនឹងសហរដ្ឋអាមេរិក និងការបន្តវិវាទពីសំណាក់ប្រទេសជិតខាងគឺវៀតណាមខាងត្បូង និងប្រទេសថៃកាន់តែជំរុញឲ្យកម្ពុជាពាក់ព័ន្ធនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីពីរនេះ ។

ម៉្យាងវិញទៀតបើទោះបីជាសម្តេចព្រះនរោត្តម សីហនុ បានខិតខំអស់ពីសមត្ថភាពដើម្បីដកខ្លួនចេញពីសង្គ្រាមត្រជាក់ក៏ដោយ ក៏សង្គ្រាមត្រជាក់នេះបានទន្ទ្រានប្រទេសកម្ពុជាដដែល ។ ហើយខ្ញុំអាចអះអាងថាប្រសិនបើគ្មានសង្គ្រាមឥណ្ឌូចិនលើកទីពីរនេះទេ ខ្មែរក្រហមក៏មិនអាចឡើងក្តោបក្តាប់អំណាចនៅកម្ពុជាបានដែរ ។ ហើយវាក៏មិនអាចទៅរួចដែលថា សម្តេចព្រះនរោត្តម សីហនុ អាចនឹងត្រូវបានទម្លាក់ពីតំណែងនោះ ។

ដើម្បីផ្តល់ឲ្យអ្នកនូវហេតុការណ៍ស្តីពីកត្តាខាងក្រៅដែលជាប់ពាក់ព័ន្ធជាមួយប្រទេសកម្ពុជា នៅដើមទសវត្សរ៍៦០ ជាពេលដែលព្រះរាជាណាចក្រកម្ពុជាគឺជា «ដែនកោះសន្តិភាព» ហើយជាពេលដែលសម្តេចព្រះនរោត្តម សីហនុ កំពុងតែមានប្រជាប្រិយភាពនោះ ខ្ញុំនឹងលើកឡើងពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ខ្ញុំនៅត្រង់ចំណុចនេះ ។

ដំបូងខ្ញុំបានចាប់អារម្មណ៍ប្រទេសកម្ពុជាតាំងពីហាសិបពីរឆ្នាំមុនគឺនៅឆ្នាំ១៩៥៩ នៅពេលដែលខ្ញុំបានស្ម័គ្រចិត្តបម្រើការងារនៅក្នុងវគ្គបណ្តុះបណ្តាលភាសាខ្មែរនៅរដ្ឋវ៉ាស៊ីនតោនឌីស៊ី ។ នៅអំឡុងពេលនោះ ខ្ញុំគ្រាន់តែជាសមាជិកតូចតាចម្នាក់នៃកិច្ចការការទូតរបស់សហរដ្ឋអាមេរិកតែប៉ុណ្ណោះ ។ ខ្ញុំយល់ថា ប្រទេសកម្ពុជាអាចជាកន្លែងដ៏គួរឲ្យចង់ធ្វើការ ហើយវាច្បាស់ណាស់ថាប្រទេសកម្ពុជាគឺជាទីកន្លែងមួយដ៏ល្អ ។

នៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៦២ ពេលដែលខ្ញុំបានបម្រើការងារនៅស្ថានទូតអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ នយោបាយរបស់សហរដ្ឋអាមេរិកចំពោះកម្ពុជាគឺពឹងផ្អែកទៅលើសង្គ្រាមត្រជាក់ ។ នយោបាយនេះមានបំណងបញ្ចប់ដំណើរការវិវឌ្ឍរបស់របបកុម្មុយនីស្តនៅជុំវិញពិភពលោក ជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ ។ ប្រជាជនអាមេរិកបានអះអាងថា ប្រទេសមួយនេះមិនមែនជាប្រទេសគាំទ្រ ឬប្រឆាំងនឹងសហរដ្ឋអាមេរិករបស់យើងទេ ។ ប្រទេសកម្ពុជាគឺកំពុងតែវង្វេង ពីព្រោះប្រទេសកម្ពុជាមិនគាំទ្រ ហើយក៏មិនប្រឆាំងនឹងប្រទេសណាមួយ ។

នៅអំឡុងពេលនោះសង្គ្រាមឥណ្ឌូចិនលើកទីពីរមិនទាន់កើតមាននៅឡើយ ប៉ុន្តែសហរដ្ឋអាមេរិកបានគិតថាខ្លួនត្រូវតែប្រឆាំងនឹងរបបកុម្មុយនីស្តនៅប្រទេសវៀតណាមខាងត្បូង ហើយដើម្បីធ្វើដូច្នោះបាន សហរដ្ឋអាមេរិកត្រូវតែជំរុញឲ្យមានការគាំទ្រសង្គ្រាមត្រជាក់ខ្លួននៅទីក្រុងសៃហ្គន និងទីក្រុងឯករាជ្យបាងកកនិងនៅទីក្រុងភ្នំពេញ ដែលមានសម្តេចព្រះនរោត្តម សីហនុ ដែលជាមនុស្សមិនគួរឲ្យជឿជាក់គ្រប់គ្រង ។ សម្តេចព្រះនរោត្តម សីហនុ មិនចូលចិត្តសហរដ្ឋអាមេរិកទេ ដោយសារតែរបបដែលធ្វើការគាំទ្រសហរដ្ឋអាមេរិកនៅទីក្រុងសៃហ្គន និងទីក្រុងបាងកកមានបំណងចង់ទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីអំណាច និងដោយសារតែប្រទេសរបស់លោកខាងលិចដែលព្រះអង្គសព្វព្រះហឫទ័យ និងឈ្វេងយល់ច្បាស់គឺប្រទេសបារាំង មិនមែនសហរដ្ឋអាមេរិកទេ ។

ក្រោយពីរចនាសម្ព័ន្ធសង្គ្រាមត្រជាក់នេះរយៈពេលប៉ុន្មានឆ្នាំដែលខ្ញុំបានបម្រើការងារនៅទីក្រុងភ្នំពេញ គឺជាពេលវេលាមួយដ៏ល្អសម្រាប់ប្រទេសកម្ពុជា បើទោះបីជាខ្ញុំគ្មានឥទ្ធិពលអ្វីចំពោះហេតុការណ៍ដែលបានកំពុងតែកើតឡើងនៅក្នុងអំឡុងពេលនោះ ។ នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំនោះ សម្តេចព្រះនរោត្តម សីហនុ ពិតជាមានប្រជាប្រិយភាពណាស់ ។ នៅពេលនោះ សម្រាប់មនុស្សជាច្រើនរួមទាំងខ្លួនខ្ញុំបានគិតថាប្រទេសកម្ពុជាគឺជា «ដែនដីសន្តិភាព» ដ៏ពិសិដ្ឋមួយនៅក្នុងពិភពលោកដែលពោរពេញទៅដោយភាព

ច្របូកច្របល់ ហើយលទ្ធភាពដែលថា សម្តេចព្រះនរោត្តម សីហនុ អាចនឹងត្រូវបានទម្លាក់ពីអំណាចដោយក្រុមគាំទ្រសហរដ្ឋអាមេរិក ឬដោយបដិវត្តន៍កុម្មុយនីស្ត នោះគឺស្ទើរតែមិនអាចកើតឡើងទាល់តែសោះ ។

ប៉ុន្តែដោយសារតែមានការវាយប្រហារពីក្រុមគាំទ្រសហរដ្ឋអាមេរិក និងបដិវត្តន៍កុម្មុយនីស្តបានផ្ទុះឡើងនៅទសវត្សរ៍៧០ នោះយើងចាំបាច់ត្រូវតែបែរមកចាប់អារម្មណ៍មើលខ្មែរក្រហមវិញម្តង ដែលនៅអំឡុងពេលនោះខ្មែរក្រហមមិនត្រូវបានគេស្គាល់ទេ ស្របពេលដែលខ្ញុំបានកំពុងធ្វើការនៅទីក្រុង ភ្នំពេញ ។

ពេលដែលខ្ញុំបានជួប ប៉ុល ពត ជាលើកចុងក្រោយគឺនៅឆ្នាំ ១៩៥២ ជាពេលដែល ប៉ុល ពត បានចូលរួមនៅក្នុងបក្សកុម្មុយនីស្តនៅទីក្រុងប៉ារីស ។ ប៉ុល ពត បានត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥៣ ក្រោយពេលដែល ប៉ុល ពត បានប្រឡងធ្លាក់ ហើយបានចំណាយពេលមួយរយៈខ្លីរស់នៅក្នុងតំបន់ដែលសម្បូរទៅដោយជនជាតិវៀតណាម (តំបន់នៅទីក្រុងប៉ារីស) ។ នៅទីនោះ ប៉ុល ពត ត្រូវបានទទួលស្គាល់ថាជាសមាជិកម្នាក់របស់បក្សកុម្មុយនីស្តឥណ្ឌូចិន ហើយបានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងកម្មាភិបាលម្នាក់របស់បក្សប្រជាជនបដិវត្តន៍ខ្មែរគឺ ទូ សាមុត ។ ដោយសារតែ ប៉ុល ពត បានវិលត្រឡប់មកប្រទេសកម្ពុជាមុនដៃគូរបស់ខ្លួនដែលនៅប្រទេសបារាំង ប៉ុល ពត ទទួលបានមុខតំណែងសំខាន់នៅក្នុងចលនាក្រុមកុម្មុយនីស្តកម្ពុជា ជាពិសេសគឺដោយសារតែទំនាក់ទំនងជិតស្និទ្ធរបស់ ប៉ុល ពត ជាមួយនឹង ទូ សាមុត ។

នៅចុងទសវត្សរ៍៥០ ប៉ុល ពត បានរៀបការជាមួយនឹងនារីស្នេហាជាតិដ៏ស្មោះស្ម័គ្រម្នាក់ឈ្មោះគឺ ខៀវ ប៉ុណ្ណារី ហើយបានចាប់ផ្តើមចូលបង្រៀននៅសាលារៀនឯកជនមួយ ស្របពេលដែល ប៉ុល ពត កំពុងតែបន្តអនុវត្តចលនាបក្សកុម្មុយនីស្តរបស់ខ្លួន ។ នៅក្នុងអំឡុងពេលនោះ បក្សកុម្មុយនីស្តនេះមានទ្រង់ទ្រាយតូច មិនមានរចនាសម្ព័ន្ធរៀបរយល្អ ខ្វះខាតថវិកា និងទទួលរងការវាយប្រហារ ពីកងកម្លាំងប៉ូលិសរបស់សម្តេចព្រះនរោត្តម សីហនុ ។

បុរស និងស្ត្រីដែលបានតស៊ូប្រឆាំងនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយជាមួយនឹងប្រជាជនវៀតណាមបានចាប់ផ្តើមជីវភាពរស់នៅរបស់ខ្លួនសារជាថ្មីម្តងទៀត ក្រោយពេលដែលប្រទេសកម្ពុជាទទួលបានឯករាជ្យភាព ។ ដំបូងឡើយ ចលនាកុម្មុយនីស្តកម្ពុជាគឺជាបាតុភូតរបស់ប្រជាជនរស់នៅទីក្រុងដែលធ្វើការកាត់ផ្តាច់ពីទីជនបទ និងពីចលនារបស់ក្រុមអ្នកគាំទ្ររបបកុម្មុយនីស្តនៅជនបទ ។ ប្រទេសវៀតណាមខាងជើងមិនទាន់មានឆន្ទៈនឹងផ្តល់ជំនួយដល់ការតស៊ូរវាងកម្លាំងយោធានៅប្រទេសវៀតណាមខាងជើងនៅឡើយទេ ហើយក៏មិនទាន់បានអនុវត្តសកម្មភាពជាមួយនឹងខ្សែបណ្តាញរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាសាជាថ្មីដែរ ។ អំឡុងពេលទសវត្សរ៍៥០ និង៦០ គឺជាពេលវេលាមួយដ៏មានគ្រោះថ្នាក់បំផុតសម្រាប់ក្រុមកុម្មុយនីស្តរបស់ប្រទេសវៀតណាមខាងត្បូង និងប្រទេសកម្ពុជា បើទោះបីជាអំឡុងពេលនោះត្រូវបានយល់ខុសថា ជាពេលវេលាល្អសម្រាប់ប្រទេសកម្ពុជាដូចដែលយើងបានឃើញមានការកើនឡើងនូវប្រជាប្រិយភាពរបស់សម្តេចព្រះនរោត្តម សីហនុ ដែលជាប្រធានប្រមុខរដ្ឋដ៏មានជំនាញ និងជំនឿទុកចិត្តលើខ្លួនឯងក៏ដោយ ។ ដោយធ្វើការគាបសង្កត់លើក្រុមកុម្មុយនីស្តនៅកម្ពុជា និងចងសម្ព័ន្ធមិត្តជាមួយនឹងប្រទេសចិន សម្តេចព្រះនរោត្តម សីហនុ ប្រាកដក្នុងព្រះរាជហឫទ័យថា ព្រះអង្គអាចទប់ស្កាត់ប្រទេសកម្ពុជាកុំឲ្យធ្លាក់ក្នុងរបបកុម្មុយនីស្ត និងសង្គ្រាមនៅប្រទេសវៀតណាម ។

យ៉ាងណាមិញ សម្តេចព្រះនរោត្តម សីហនុ មិនបានស្រមើស្រមៃជាមុនពីភាពសាហាវនៃសង្គ្រាមឥណ្ឌូចិនលើកទីពីរនេះទេ ដែលជាលទ្ធផលបានបញ្ចប់អំណាចរបស់ព្រះអង្គ ហើយនាំមកនូវជ័យជម្នះរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។

បើទោះបីជា ប៉ុល ពត និងគូកនរបស់ខ្លួននៅក្នុងក្រុមអ្នកដឹកនាំចលនាកុម្មុយនីស្តសម្ងាត់នេះអាចគេចផុតពីកងកម្លាំងប៉ូលិសរបស់សម្តេច សីហនុ ក៏ដោយ ក៏ក្រុមអ្នកកុម្មុយនីស្តទាំងអស់នេះមានភាពច្របូកច្របល់នៅពេលដែលប្រធានបក្សរបស់ខ្លួនគឺ ទូ សាមុត បានបាត់ខ្លួននៅឆ្នាំ១៩៦២ ដែល ទូ សាមុត ត្រូវបានគេសន្មតថាត្រូវបានសម្លាប់ ។ ប៉ុល ពត បានឡើងកាន់តំណែងជំនួស ទូ សាមុត ហើយអស់រយៈពេលប៉ុន្មានឆ្នាំមកទៀតដោយសារតែភ័យខ្លាចនឹងការចាប់ខ្លួន ប៉ុល ពត បានរត់ទៅជ្រកកោនជាមួយ

នឹងសមាជិកផ្សេងៗទៀតនៅមូលដ្ឋានយោធារបស់ពួកកុម្មុយនីស្ត វៀតណាមនៅជិតស្រុកមេមត់ជាប់ព្រំដែនប្រទេសវៀតណាម ។ ប៉ុល ពត បានរស់នៅទីនោះអស់រយៈពេលពីរឆ្នាំ ។ វាជារឿងគួរឲ្យភ្ញាក់ផ្អើល ប៉ុល ពត មិនដែលបោះបង់ចោលនៃក្តីសង្ឃឹមទេ ។ នៅឆ្នាំ១៩៦៥ ប៉ុល ពត ត្រូវបានកោះហៅឲ្យទៅចូលរួមពិភាក្សានៅទីក្រុងហាណូយ ។ នេះប្រហែលបញ្ជាក់ឲ្យឃើញ ប៉ុល ពត មានជាប់ពាក់ព័ន្ធជាមួយនឹងជម្លោះដ៏តានតឹងនៅក្នុងប្រទេសវៀតណាមខាងត្បូង ។ ប៉ុល ពត បានធ្វើដំណើរដោយថ្មើរជើងទៅកាន់ភាគខាងជើងអស់រយៈពេលជាច្រើនខែដោយសេចក្តីរីករាយ ដោយជឿថាវៀតណាមខាងជើងបានទទួលស្គាល់ ប៉ុល ពត ជាប្រធានបក្សកុម្មុយនីស្តកម្ពុជា ។ ប៉ុល ពត រំពឹងថានឹងបានចែករំលែកផែនការបដិវត្តន៍របស់ខ្លួនជាមួយនឹងសមាជិកបក្សកុម្មុយនីស្តវៀតណាមនៅទីក្រុងហាណូយ ។

ជាក់ស្តែង អាជ្ញាធរវៀតណាមខាងជើងមិនសូវចាប់អារម្មណ៍នឹងផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ។ ផ្ទុយទៅវិញ វៀតណាមខាងជើងមានបំណងចង់ចាប់ផ្តើមការសហការសាជាថ្មីម្តងទៀតជាមួយនឹងកម្ពុជាដើម្បីពង្រឹងកម្លាំងយោធារបស់ខ្លួន និងដើម្បីការពារផ្លូវសម្រាប់ផ្តល់ជំនួយដល់ការធ្វើសង្គ្រាមរបស់ប្រទេសវៀតណាមខាងត្បូងដែលកាត់ប្រទេស «មិនចូលបក្សសម្ព័ន្ធ» ឡាវនិងកម្ពុជាទៅវិញទេ ។ បើនិយាយម្យ៉ាងវិញទៀត វៀតណាមខាងជើងមានបំណងចង់ចងសម្ព័ន្ធភាពសាជាថ្មីជាមួយនឹងប្រជាជនកម្ពុជាដែលរស់នៅតាមជនបទដែលបានតស៊ូនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ ។

នាអំឡុងពេលនោះ សម្តេចព្រះនរោត្តម សីហនុ បានកាត់ផ្តាច់ចំណងមិត្តភាពជាមួយនឹងសហរដ្ឋអាមេរិក ហើយងាកមករាប់អានក្រុមកុម្មុយនីស្តវៀតណាមដែលព្រះអង្គជឿថានឹងទទួលជោគជ័យលើវៀតណាមខាងត្បូង ។ ដូចគ្នានឹង ប៉ុល ពត សម្តេចព្រះនរោត្តម សីហនុ ត្រូវបានធ្លាក់ខ្លួនចូលទៅក្នុងសង្គ្រាមត្រជាក់ដោយមិនដឹងខ្លួន ។

អស់រយៈពេលជាច្រើនឆ្នាំក្រោយមក ដោយរួមគ្នាជាមួយនឹងដៃគូកុម្មុយនីស្តរបស់ខ្លួន ប៉ុល ពត បានរៀបចំគម្រោងបដិវត្តន៍ថ្មីមួយសម្រាប់បក្សកុម្មុយនីស្តរបស់ខ្លួន ។ គម្រោងនោះគឺផ្តោតទៅលើការតស៊ូប្រដាប់អាវុធជាមួយនឹងកងកម្លាំងរបស់សម្តេចព្រះនរោត្តម សីហនុ និងបំផ្លាញរាល់អ្វីដែលក្រុមកុម្មុយនីស្តនេះចាត់ទុកថាជារបប «សក្តិភូមិ» និងបុគ្គលដែលសង្កត់សង្កិនអ្នកដទៃនៅក្នុងសង្គមខ្មែរ ។

នៅពេលដែល ប៉ុល ពត បានមកដល់ទីក្រុងហាណូយ ប៉ុល ពត បានធ្វើបទបង្ហាញពីគម្រោងរបស់បក្សកុម្មុយនីស្តកម្ពុជាជូនដល់ប្រធានបក្សពលកររបស់វៀតណាមគឺលោក លី ឌួន ។ លោក លី ឌួន បានប្រាប់ ប៉ុល ពត ទាំងគំរោះគំរើយថា គម្រោងរបស់បក្សកុម្មុយនីស្តកម្ពុជាមិនហុចជាប្រយោជន៍ទេ ពីព្រោះគម្រោងនេះមិនបានពិចារណាទៅលើទស្សនៈអន្តរជាតិ កាតព្វកិច្ចជាទូទៅរបស់របបកុម្មុយនីស្តកម្ពុជា និងជាពិសេសគឺបដិវត្តន៍កម្ពុជាតែម្តង ។ គម្រោងនេះក៏មិនអើពើចំពោះការចងសម្ព័ន្ធភាពជាមួយនឹងវៀតណាមខាងជើងដែរ ។ លោក លី ឌួន បានប្រាប់ ប៉ុល ពត ឲ្យនៅក្រោមបង្គាប់របស់បក្សកុម្មុយនីស្តវៀតណាមខាងជើង យកគម្រោងរបស់បក្សកុម្មុយនីស្តវៀតណាមធ្វើជាអាទិភាព ហើយពន្យារពេលការតស៊ូប្រដាប់អាវុធរហូតដល់វៀតណាមខាងជើងយកជ័យជម្នះពីវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិកសិន ។ បើទោះបីជាលោក លី ឌួន មិនបានលើកឡើងពីបញ្ហារបស់វៀតណាមខាងជើងជាមួយនឹងសម្តេចព្រះនរោត្តម សីហនុ ទៅកាន់ ប៉ុល ពត ក៏ដោយ ក៏លោក លី ឌួន ចង់រក្សាកិច្ចព្រមព្រៀងសម្ងាត់ដែលបក្សកុម្មុយនីស្តវៀតណាមដែលបានធ្វើជាមួយនឹងសម្តេចព្រះនរោត្តម សីហនុ ដែរ ។ នៅក្នុងកិច្ចព្រមព្រៀងនោះ សម្តេចព្រះនរោត្តម សីហនុ បានអនុញ្ញាតឲ្យបក្សកុម្មុយនីស្តវៀតណាមដាក់កម្លាំងទ័ពនៅក្នុងប្រទេសកម្ពុជា ហើយនាំយកជំនួយយោធាកាត់តាមប្រទេសកម្ពុជាដោយសន្យាថាមិនបង្កគ្រោះថ្នាក់ដល់ប្រជាជនកម្ពុជា ហើយត្រូវគោរពតាមបូរណភាពដែនដីរបស់កម្ពុជា ។ ប្រតិកម្មរបស់ ប៉ុល ពត ចំពោះមតិរិះគន់របស់ លី ឌួន មិនត្រូវបានកត់ត្រាទុកទេ ប៉ុន្តែការប្រមាថមើលងាយ និងការអន់ចិត្តច្បាស់ជាកើតមានជាមិនខាន ចំពោះ ប៉ុល ពត ។

បើនិយាយពីបញ្ហារបស់សម្តេចព្រះនរោត្តម សីហនុ វិញ គ្មានមធ្យោបាយណាផ្សេងដែលព្រះអង្គអាចបដិសេធការទាមទាររបស់វៀតណាមបានទេ ហើយព្រះអង្គជឿថា តាមរយៈការរៀបចំ

គម្រោងសម្ងាត់ជាមួយវៀតណាមមុនពេលអំណាចរបស់សហរដ្ឋអាមេរិករីកសាយភាយនោះ ព្រះអង្គអាចនឹងការពារប្រទេសកម្ពុជាកុំឲ្យធ្លាក់ចូលក្នុងសង្គ្រាម និងទទួលបានប្រយោជន៍ពីចំណងមិត្តភាពជាមួយវៀតណាមក្រោយពេលដែលក្រុមកុម្មុយនីស្តវៀតណាមនេះឈ្នះសង្គ្រាម ។

នៅដើមឆ្នាំ១៩៦៦ ប៉ុល ពត បានធ្វើដំណើរពីហាណូយទៅប្រទេសចិនមួយថ្ងៃមុនពេលមានបដិវត្តន៍វប្បធម៌ ។ មន្ត្រីប្រទេសចិនបានប្រាប់ ប៉ុល ពត ថាប្រទេសចិនបានគាំទ្រការធ្វើបដិវត្តន៍នៅជុំវិញពិភពលោកដែលមិនផ្តោតលើទិដ្ឋភាពនិងកាតព្វកិច្ចរបស់សង្គមនិយមអន្តរជាតិ ។ តាមពិតប្រទេស ចិនគាំទ្របដិវត្តន៍ដែលបានឆ្លើយតបនឹងស្ថានភាពក្នុងស្រុករបស់ប្រទេសដែលធ្វើបដិវត្តន៍នោះច្រើនជាង ។ នេះមានន័យថាប្រទេសចិនទំនងជាគាំទ្របដិវត្តន៍របស់ ប៉ុល ពត ។ ដោយសារតែប្រទេសចិននៅតែគាំទ្រសម្តេចព្រះនរោត្តម សីហនុ នោះការធ្វើទស្សនកិច្ចរបស់ ប៉ុល ពត ត្រូវបានរក្សាជាការសម្ងាត់ ហើយមន្ត្រីដែលបានចូលជួបជាមួយនឹង ប៉ុល ពត ត្រូវតែលាក់ការសម្ងាត់ ។

យ៉ាងណាមិញ ប៉ុល ពត បានយល់ឃើញថាខ្លួនអាចនឹងទទួលបានផលប្រយោជន៍ច្រើនសម្រាប់បដិវត្តន៍នេះ ប្រសិនបើ ប៉ុល ពត ទទួលការឧបត្ថម្ភគាំទ្រពីប្រទេសចិន ប្រសើរជាងស្ថិតនៅក្រោមបង្គាប់របស់វៀតណាម ។ នៅពេលដែល ប៉ុល ពត ត្រឡប់ចូលប្រទេសវិញ ប៉ុល ពត បានបង្កើតទីបញ្ជាការនៅភូមិភាគឦសាននៃប្រទេសដែលនៅទីនោះ ប៉ុល ពត បានទទួលការការពារដែលពីកងយោធាកុម្មុយនីស្តវៀតណាម ប៉ុន្តែមិននៅក្រោមបញ្ជាគ្រប់គ្រងពីវៀតណាមពីមួយថ្ងៃទៅមួយថ្ងៃដូចមុននោះទេ ។ ក្នុងរយៈពេលពីរឆ្នាំ ប៉ុល ពត បានប្រមូលជំនួយឧបត្ថម្ភនិងធ្វើកំណែទម្រង់លើគម្រោងរបស់ខ្លួនឡើងវិញ ។ ស្របពេលជាមួយគ្នានោះ ប៉ុល ពត រួមជាមួយនឹងគូកនរបស់ខ្លួននៅមិនទាន់ជឿជាក់គ្រប់គ្រាន់ក្នុងការធ្វើការតស៊ូប្រយុទ្ធផ្នែកយោធាដោយគ្មានការអនុញ្ញាត និងជំនួយឧបត្ថម្ភពីប្រទេសវៀតណាមបានទេ ។ នេះក៏ទំនងជាបញ្ជាក់ឲ្យឃើញថាខ្មែរក្រហមនៅតែគោរពឱនលំទោនចំពោះវៀតណាមដដែល ។

នៅក្នុងអំឡុងពេលដូចគ្នានោះ ទិដ្ឋភាពផ្នែកនយោបាយនៅក្នុងប្រទេសកម្ពុជាកំពុងតែមានការផ្លាស់ប្តូរដែលប៉ះពាល់ដល់អត្ថប្រយោជន៍របស់សម្តេចព្រះនរោត្តម សីហនុ ។ មានហេតុផលជាច្រើនបានបញ្ជាក់ឲ្យឃើញថា ការគ្រប់គ្រងប្រទេសកម្ពុជាដោយគ្មានសម្ព័ន្ធភាពពីប្រទេសដទៃទៀតកាន់តែមានការពិបាកសម្រាប់សម្តេចព្រះនរោត្តម សីហនុ ។ សេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមធ្លាក់ចុះ ។ ប្រទេសកម្ពុជាកាន់តែឃ្លាតឆ្ងាយពីប្រទេសដទៃ ហើយក្រុមអ្នកស្នេហាជាតិរបស់កម្ពុជាកាន់តែខ្វះការអត់ធ្មត់ចំពោះអំណាចដឹកនាំប្រទេសរបស់សម្តេចព្រះនរោត្តម សីហនុ ។ នៅជិតខាងប្រទេសវិញ ការវាយប្រហារបានគំរាមកំហែងនិងប៉ះពាល់ដល់ប្រទេសកម្ពុជា ហើយក្រុមអ្នកស្នេហាជាតិ និងមន្ត្រីយោធាខ្លះរួមទាំងមេបញ្ជាការ លន់ នល់ មិនពេញចិត្តជាមួយសម្តេចព្រះនរោត្តម សីហនុ ដែលធ្វើការគាំទ្រប្រទេសកុម្មុយនីស្តមួយចំនួនជាងសហរដ្ឋអាមេរិកឡើយ ។

នៅក្នុងការបោះឆ្នោតរដ្ឋសភាជាតិឆ្នាំ១៩៦៦ បេក្ខជនទាំងអស់គឺសុទ្ធតែជាសមាជិករបស់របបសង្គមរាស្ត្រនិយម ។ យ៉ាងណាមិញ ការបោះឆ្នោតនេះគឺជាការបោះឆ្នោតលើកដំបូងបង្អស់ដែលសម្តេចព្រះនរោត្តម សីហនុ មិនបានធ្វើការជ្រើសតាំងដោយផ្ទាល់យ៉ាងហ្មត់ចត់នោះទេចាប់តាំងពីប្រទេសកម្ពុជាទទួលបានឯករាជ្យភាពមក ។ ជាលទ្ធផល បេក្ខជនដែលបានជ្រើសរើសចូលមកកាន់តំណែងទាំងអស់នោះគ្មានជំពាក់គុណអ្វីជាមួយសម្តេចព្រះនរោត្តម សីហនុ ឡើយ ហើយអ្នកខ្លះបានបន្តកាន់តំណែងដោយគ្មានការគាំទ្រពីសម្តេចព្រះនរោត្តម សីហនុ ។ ភ័ស្តុតាងនៃការធ្លាក់ចុះនូវប្រជាប្រិយភាពរបស់សម្តេចព្រះនរោត្តម សីហនុ ក្នុងចំណោមអ្នកស្នេហាជាតិមានទិដ្ឋភាពដូចឧទាហរណ៍នេះ ។ សមាជិករដ្ឋសភាខ្លះដែលស្អប់សម្តេចព្រះនរោត្តម សីហនុ ដែលក្នុងនោះរួមមានជនកុម្មុយនីស្ត ខៀវ សំផន, ហ៊ូ នឹម និងអតីតអ្នកកាន់លទ្ធិប្រជាធិបតេយ្យរបស់ប្រទេសលោកខាងលិច ឌូក រ៉ៃយ បានទទួលកៅអីកាន់តំណែងនៅរដ្ឋសភាមកវិញដោយមានសំឡេងឆ្នោតគាំទ្រកាន់តែកើនឡើង ។ ដោយពូកែវិភាគលើកិច្ចការរបស់ខ្លួន ប៉ុន្តែអសមត្ថភាពក្នុងការចាកចេញពីឆាកនយោបាយនេះ សម្តេចព្រះនរោត្តម សីហនុ បានចាប់ផ្តើមបាត់បង់ភាពជឿជាក់ក្នុងការដឹកនាំប្រទេសនៅឆ្នាំ១៩៦៧ ហើយផាកមក

ចំណាយពេលផលិតខ្សែភាពយន្តវិញ ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៧ ខណៈពេលដែលកងយោធាវៀតណាមនាំគ្នាចាកចេញពីប្រទេសកម្ពុជាដើម្បីចូលរួមក្នុងយុទ្ធនាការយោធាសង្គ្រាមវៀតណាមនៅប្រទេសវៀតណាមខាងត្បូង ខ្មែរក្រហមបានចាប់ផ្តើមវាយប្រហារប្រដាប់អាវុធដោយវាយយកបានប៉ុស្តិ៍ប៉ូលិស និងប្រមូលបានអាវុធមួយចំនួននៅតាមតំបន់ដាច់ស្រយាលនៃខេត្តបាត់ដំបង ។ មួយឆ្នាំក្រោយមក ការប៉ះទង្គិចគ្នាតូចៗរវាងទាហានឈ្លបខ្មែរក្រហម និងកងទ័ពកម្ពុជាបានចាប់ផ្តើមកើតមានឡើងនៅតាមទីជនបទនៃប្រទេសកម្ពុជា ។ ការវិវឌ្ឍនៃស្ថានភាពបែបនេះបានផ្តល់សញ្ញាណមួយដល់សម្តេចព្រះនរោត្តម សីហនុ ថាព្រះអង្គបានបាត់បង់ការជឿទុកចិត្តពីអ្នកស្នេហាជាតិក្នុងក្រុងហើយ ។ សម្តេចព្រះនរោត្តម សីហនុ តែងតែសន្មតថា «ខ្មែរក្រហម» គឺនៅក្រោមការបង្គាប់បញ្ជារបស់ប្រទេសវៀតណាម ប៉ុន្តែពេលនេះវៀតណាមបានកំពុងតែបោកប្រាសសម្ព័ន្ធមិត្តសម្ងាត់របស់ខ្លួនជាមួយនឹងសម្តេចព្រះនរោត្តម សីហនុ ដោយផ្តល់អំណាចដល់ «អាយ៉ង» របស់ខ្លួនទៅវិញ ។

ដោយងាកចេញពីគោលនយោបាយពីមុនរបស់ខ្លួន សម្តេចព្រះនរោត្តម សីហនុ បានចាប់ផ្តើមផ្សាភ្ជាប់សម្ព័ន្ធមិត្តភាពការទូតជាមួយនឹងសហរដ្ឋអាមេរិកវិញ ដោយអនុញ្ញាតឲ្យអាមេរិកទម្លាក់គ្រាប់បែកលើផ្លូវលំ ហូ ជីមិញ ហើយបានតែងតាំងអ្នកប្រឆាំងនឹងលទ្ធិកុម្មុយនីស្ត លន់ នល់ ជានាយករដ្ឋមន្ត្រីថ្មី ។ នៅឆ្នាំ១៩៦៩ ក្នុងកិច្ចខំប្រឹងប្រែងរក្សាតុល្យភាពនៅក្នុងសង្គ្រាមត្រជាក់របស់ខ្លួន សម្តេចព្រះនរោត្តម សីហនុ គឺជាប្រមុខរដ្ឋម្នាក់គត់ដែលបានចូលរួមពិធីបុណ្យសពរបស់ ហូ ជីមិញ នៅទីក្រុងហាណូយ ។

ការផ្លាស់ប្តូររបស់ សម្តេច សីហនុ ទាំងអស់នេះបានចាប់ផ្តើមឡើងយឺតពេលទៅហើយក្នុងការបញ្ចៀសគ្រោះមហន្តរាយ ហើយវាក៏មិនអាចទៅរួចដែរក្នុងការគិតលើទិដ្ឋភាពដែលថាប្រទេសកម្ពុជាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សម្តេចព្រះនរោត្តម សីហនុ អាចនឹងមិនពាក់ព័ន្ធជាមួយនឹងសង្គ្រាមឥណ្ឌូចិនលើកទីពីរនេះ ឬសង្គ្រាមត្រជាក់ដែលប្រទេសកម្ពុជាគ្មានការចាប់អារម្មណ៍ ។ ជាក់ស្តែង ប្រជាជនកម្ពុជាមិនចង់ក្លាយជាសមាជិករបស់ប្រទេសសេរី ឬប្រទេសកុម្មុយនីស្តឡើយ ។ ប្រជាជនកម្ពុជាគ្រាន់តែចង់បានជីវិតរស់នៅដែលសមរម្យមួយតាមផ្លូវរបស់ខ្លួនតែប៉ុណ្ណោះ ។

ផ្ទុយទៅវិញ យើងអាចនិយាយបានថា ប្រទេសកម្ពុជាត្រូវបានរងគ្រោះដោយសារកងកម្លាំងយោធារបស់សង្គ្រាមត្រជាក់ ដូច្នេះប្រទេសកម្ពុជាក៏បានចាប់ផ្តើមមានសកម្មភាពឡើងវិញដោយសារតែការងើបឡើងវិញទាំងផ្នែកស្មារតី និងកម្លាំងកាយរបស់ប្រជាជនកម្ពុជា និងដោយសារតែសង្គ្រាមត្រជាក់បានបញ្ចប់ជាស្ថាពរហើយ ។

ស្របពេលជាមួយគ្នានោះ នៅសហរដ្ឋអាមេរិក រីឆាត និកសុន បុគ្គលដែលមានសមត្ថភាពដោះស្រាយបញ្ហាសង្គ្រាមត្រជាក់បានចូលកាន់តំណែងជាប្រធានាធិបតី ។ លោកបានសន្យាថានឹងបញ្ចប់សង្គ្រាមនៅឥណ្ឌូចិនលើកទីពីរនេះដែលលោកគិតថាវាគឺជាកិច្ចការដ៏មានកិត្តិយស ។ ខណៈពេលដែលប្រធានាធិបតីនិកសុន បន្តកិច្ចចរចាជាមួយនឹងវៀតណាមខាងជើងដែលកិច្ចចរចានេះត្រូវបានបើកធ្វើឡើង ដោយលោកអតីតប្រធានាធិបតី លីនដុន ចនសាន់ នោះ លោក រីឆាត ក៏ជឿជាក់ថាប្រទេសកម្ពុជាគឺជាកូនសោ«គន្លឹះ»មួយសម្រាប់យុត្តិសាស្ត្រនាពេលអនាគតរបស់អាមេរិកនៅក្នុងតំបន់ឥណ្ឌូចិន បើទោះបីជាហេតុផលខ្លះនៃការជឿជាក់បែបនេះនៅតែមិនមានលក្ខណៈស្រពេចស្រពិលសម្រាប់សហរដ្ឋអាមេរិកក៏ដោយ ។ ជាលទ្ធផល ការយល់ខុសនេះបានបង្កឲ្យប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់កម្ពុជាក្នុងអំឡុងពេលយូរអង្វែង ។

នៅខែមីនា ឆ្នាំ១៩៧០ ខណៈពេលដែលសម្តេចព្រះនរោត្តម សីហនុ បានកំពុងតែធ្វើដំណើរទស្សនកិច្ចនៅប្រទេសអឺរ៉ុប ទ្រង់ត្រូវបានបោះឆ្នោតទម្លាក់ពីតំណែងប្រមុខរដ្ឋដោយរដ្ឋសភាជាតិ ។ រដ្ឋប្រហារនេះ គឺជាបញ្ហាស្មុគស្មាញបំផុតនៃប្រវត្តិសាស្ត្រទាក់ទងនឹងការមិនពេញចិត្តរបស់អ្នកស្នេហាជាតិក្នុងក្រុងចំពោះសម្តេចព្រះនរោត្តម សីហនុ ។ រដ្ឋប្រហារនេះបានទទួលការអនុញ្ញាតពីសហរដ្ឋមេរិកដែលក្នុងដំណាក់កាលនោះ សហរដ្ឋអាមេរិកកំពុងតែស្រេកឃ្លានចង់បានការគាំទ្រនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីពីរនេះ ។ តាមទស្សនៈរបស់ខ្ញុំ ខ្ញុំមិនគិតថាមនុស្សគ្រប់គ្នានៅសហរដ្ឋអាមេរិកយល់ថា សម្ព័ន្ធភាពរវាងកម្ពុជា និងសហរដ្ឋអាមេរិកអាចនឹងបង្កនូវគ្រោះមហន្តរាយដល់ប្រទេសកម្ពុជា

ទេ ពីព្រោះប្រទេសកម្ពុជាគឺជាកូនអុកមិនមែនជាអ្នកលេងអុក នៅក្នុងសង្គ្រាមត្រជាក់នេះទេ ដូច្នេះសហរដ្ឋអាមេរិកអាចដើរចេញពីល្បែងអុកនេះបានយ៉ាងងាយ ប្រសិនបើអាមេរិកចាញ់ល្បែងនេះ ។

ជាលទ្ធផល ការធ្វើរដ្ឋប្រហារនេះបានក្លាយជាដីកាកាត់ទោសប្រទេសកម្ពុជាដែលតែងតែចាត់ទុកខ្លួនឯងជា "ដែនដីសន្តិភាព" ទៅវិញទេ ហើយសំណើរបស់នាយករដ្ឋមន្ត្រី លន់ នល់ ដែលសុំឲ្យកងទ័ពវៀតណាមទាំងអស់ចាកចេញពីប្រទេសកម្ពុជាភ្លាមៗនោះ គឺជាសេចក្តីសម្រេចចិត្តដែលខ្វះការពិចារណាមួយ ។ ជាក់ស្តែង កងទ័ពវៀតណាមនៅតែមាននៅក្នុងទឹកដីកម្ពុជាដដែល តាំងពីឆ្នាំ១៩៦៤មក ដើម្បីបន្ត "រំដោះ" ប្រទេសវៀតណាមខាងត្បូង ។ កងទ័ពវៀតណាមមិនបានគិតពីប្រយោជន៍អ្វីរបស់ប្រទេសកម្ពុជាឡើយ ។

កំហុសសម្រាប់អ្វីៗដែលបានកើតឡើងចាប់តាំងពីពេលនោះមក (បើយើងគិតពីប្រយោជន៍របស់ប្រជាជនកម្ពុជា) អាចធ្លាក់ទៅលើវៀតណាមខាងជើង សហរដ្ឋអាមេរិក របបសាធារណរដ្ឋខ្មែរ និងខ្មែរក្រហម ។ ប៉ុន្តែសង្គ្រាមដែលបង្កដោយរដ្ឋប្រហាររបស់ លន់ នល់ ក៏បណ្តាលមកពីឥទ្ធិពលនៃសេចក្តីសម្រេចចិត្តរបស់សម្តេចព្រះនរោត្តម សីហនុ ដែលបានធ្វើឡើងក្រោយពេលព្រឹត្តិការណ៍រដ្ឋប្រហារនេះនៅទីក្រុងម៉ូស្គូ ដែលខណៈពេលនោះទ្រង់បានកំពុងស្វែងរកកន្លែងជ្រកកោននៅទីក្រុងប៉េកាំង ហើយក៏បានសម្រេចចិត្តប្រកាសសង្គ្រាមជាមួយនឹងរបបថ្មីនៅទីក្រុងភ្នំពេញ ។

ភ្លាមៗក្រោយពេលដែលសម្តេចព្រះនរោត្តម សីហនុ បានចុះពីយន្តហោះ មិត្តសំឡាញ់ចាស់របស់ព្រះអង្គគឺលោកប្រធានាធិបតីចិន ជូ អេនឡាយ បានសន្យាថា នឹងធ្វើឲ្យសម្តេចព្រះនរោត្តម សីហនុ ឡើងកាន់អំណាចវិញ ។ ចំណែកឯប្រធានាធិបតីវៀតណាមខាងជើងលោក ផាម វ៉ាន់ឌុង ក៏បានសន្យាដូចគ្នាដែរ ខណៈពេលដែលលោកបានធ្វើដំណើរទស្សនៈកិច្ចទៅទីក្រុងប៉េកាំង ។ ការទទួលបានការគាំទ្រផ្នែកនយោបាយពីប្រទេសចិន និងជំនួយផ្នែកយោធាពីប្រទេសវៀតណាមខាងជើងបានធ្វើឲ្យសម្តេចព្រះនរោត្តម សីហនុ សព្វព្រះហឫទ័យយ៉ាងខ្លាំង ។ សម្ព័ន្ធភាពថ្មីនេះក៏ធ្វើឲ្យខ្មែរក្រហមត្រូវបានទទួលស្គាល់ដែរ ហើយខ្មែរក្រហមក៏ទទួលបានការឧបត្ថម្ភជាសព្វាវុធពីវៀតណាម និងវគ្គបណ្តុះបណ្តាលផ្នែកយុទ្ធសាស្ត្រយោធា ។ ជាមួយគ្នានេះ ខ្មែរក្រហមក៏ទទួលបានផលប្រយោជន៍ពីការឃោសនាពី "អំពើក្បត់" របស់រដ្ឋប្រហារ (លន់ នល់) ដោយអះអាងថាខ្មែរក្រហមគឺជាអ្នកស្មោះស្ម័គ្រនឹងសម្តេចព្រះនរោត្តម សីហនុ ហើយមានបំណងចង់ទាមទារអំណាចឲ្យព្រះអង្គមកធ្វើជាប្រមុខរដ្ឋវិញ ។ យុទ្ធនាការនេះបានធ្វើឲ្យខ្មែរក្រហមទទួលបានអ្នកស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍របស់ខ្លួនរាប់ពាន់នាក់ និងការគាំទ្រពីសហគមន៍អន្តរជាតិដែលប្រឆាំងនឹងសហរដ្ឋអាមេរិក ។

រយៈពេលប្រាំឆ្នាំក្រោយមក ប្រទេសកម្ពុជាបានធ្លាក់នៅក្នុងសមរភូមិនៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទីពីរ ។ នេះគឺជាវាសនាដែលសម្តេចព្រះនរោត្តម សីហនុ បានខិតខំព្យាយាមគេចចេញពីសង្គ្រាមនេះក្នុងអំឡុងពេលកាន់អំណាចរបស់ទ្រង់ បើទោះបីជាព្រះអង្គបានដឹងយ៉ាងច្បាស់ពីភាពទន់ខ្សោយផ្នែកយោធារបស់កម្ពុជាក៏ដោយ ។ នៅអំឡុងឆ្នាំ១៩៧០-១៩៧២ កងកម្លាំងខ្មែរក្រហមបានទទួលជំនួយសព្វាវុធយ៉ាងច្រើនពីប្រទេសវៀតណាម រួមទាំងវគ្គបណ្តុះបណ្តាលផ្នែកយោធាទៀតផង ។ ស្របពេលនោះ កងកម្លាំងវៀតណាមខាងជើងក៏បានធ្វើការវាយប្រហារលើកងទ័ពយោធាទន់ខ្សោយរបស់ លន់ នល់ ។

តើនឹងមានរឿងអ្វីកើតឡើងប្រសិនបើសម្តេច សីហនុ មិនបានចងសម្ព័ន្ធភាពដោយស្មោះត្រង់មួយនេះជាមួយនឹងខ្មែរក្រហម? សង្គ្រាមរវាងរបប លន់ នល់ និងកងទ័ពវៀតណាមខាងជើងអាចនឹងអូសបន្លាយកាន់តែយូរ ហើយស្ថានភាពនេះកាន់តែយ៉ាប់យ៉ឺនទៀត ហើយការទាមទារឲ្យមានការចូលរួមពាក់ព័ន្ធពីសហរដ្ឋអាមេរិកក៏មិនអាចគេចផុតបានដែរ ។ បើនិយាយឲ្យត្រង់ទៅ នៅពេលដែលយុទ្ធនាការសង្គ្រាមត្រូវបានបញ្ចេះហើយនោះ អ្វីៗដែលសម្តេចព្រះនរោត្តម សីហនុ បានព្យាយាមទប់ស្កាត់មិនអាចផ្លាស់ប្តូរស្ថានភាពអ្វីបានឡើយនៅអំឡុងពេលនោះ ។ ជាក់ស្តែង ប្រទេសកម្ពុជាបានរបូតចេញពីដៃរបស់ព្រះអង្គ ហើយខណៈពេលដែលទ្រង់បានដាក់ប្រទេសកម្ពុជាទៅក្នុងដៃរបស់អ្នកដទៃ ប្រទេសកម្ពុជាក៏ធ្លាក់ចូលនៅក្រោមសង្គ្រាមត្រជាក់នេះតែម្តង ។

នៅពេលឡើងកាន់អំណាច ខ្មែរក្រហមមានបំណងចង់

បង្ហាញថាខ្លួនគឺជាអ្នកបដិវត្តន៍កម្ពុជាស្អាតស្អំ ដែលគ្មានជំពាក់អ្វីបុទ្ទូលបានការជ្រោមជ្រែងលើកទឹកចិត្តពីពួកបរទេសទេ ។ ដើម្បីធ្វើដូច្នេះបាន មេដឹកនាំខ្មែរក្រហមបានបដិសេធចោលការសហការជាមួយនឹងប្រទេសវៀតណាម និងពង្រឹងចំណងសម្ព័ន្ធមិត្តរបស់ខ្លួនជាមួយប្រទេសចិន ។ ខ្មែរក្រហមបានដាក់ខ្លួនឯងចូលទៅក្នុងបរិបទពិភពលោក ហើយរយៈពេលបីឆ្នាំក្រោយមក វាកាន់តែឃើញច្បាស់ថាប្រទេសចិនបានចាត់ទុកខ្មែរក្រហមជាកម្លាំងប្រឆាំងនឹងរបបដែលគាំទ្រសហភាពសូវៀត (វៀតណាមខាងជើង) ដែលបានឡើងកាន់អំណាចនៅប្រទេសវៀតណាមកាលពីឆ្នាំ១៩៧៥ ។ បើទោះបីជាមិនចង់ធ្វើបែបនេះក៏ដោយ ក៏ប្រទេសកម្ពុជានៅតែក្លាយជាឈើយសឹករបស់ល្បែងអុកនៃសង្គ្រាមត្រជាក់នេះដែរ ។

ប្រទេសចិនបានជំរុញឲ្យខ្មែរក្រហមវាយប្រហារលើប្រទេសវៀតណាម ប៉ុន្តែចិនមិនដែលផ្តល់ជំនួយផ្នែកកងទ័ព ឬជំនួយកងទ័ពផ្នែកអាកាសអ្វីទាល់តែសោះដល់ខ្មែរក្រហមនៅពេលដែលសង្គ្រាមរវាងកម្ពុជា និងវៀតណាមបានផ្ទុះឡើង ។

ក្រោយឆ្នាំ១៩៧៩ ប្រទេសចិន និងសហរដ្ឋអាមេរិក ដែលមានសម្ព័ន្ធមិត្តនឹងគ្នាធ្វើការប្រឆាំងនឹងសហភាពសូវៀត បានបន្តគាំទ្រការចូលធ្វើជាសមាជិកនៅក្នុងអង្គការសហប្រជាជាតិរបស់ខ្មែរក្រហមដែលជារដ្ឋាភិបាលតែមួយគត់ដែលមានកិត្តិយសនៅក្នុងអង្គការសហប្រជាជាតិ បើទោះបីជាឋិតនៅក្នុងសមាសភាពជាអ្នកនិរទេសក៏ដោយ ។ ស្របពេលជាមួយគ្នានោះ របបវៀតណាមថ្មីនៅទីក្រុងភ្នំពេញ (របបសាធារណរដ្ឋប្រជាមានិតកម្ពុជា) ទទួលបានជំនួយតិចតួចណាស់ពីសហគមន៍អន្តរជាតិ ហើយជាលទ្ធផលបានព្យាយាមស្តាបនាប្រទេសដោយសន្សឹមៗក្រោយពីរងការបំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិលនិងជំងឺតានតឹងផ្លូវចិត្តដែលបណ្តាលមកពីការប្រព្រឹត្តរបស់ខ្មែរក្រហម ។

ប្រទេសកម្ពុជាមិនអាចងើបចេញពីសង្គ្រាមត្រជាក់បានទេ រហូតដល់សង្គ្រាមត្រជាក់នេះបានបញ្ចប់ទៅរយៈពេលម្ភៃឆ្នាំក្រោយមកនៅចន្លោះឆ្នាំ១៩៨៩-១៩៩០ ។ សម្តេចព្រះនរោត្តម សីហនុ បានព្យាយាមអស់ពីសមត្ថភាពដើម្បីទាញប្រទេសកម្ពុជាចេញពីសង្គ្រាមត្រជាក់នេះ ។ ដំបូងប្រទេសវៀតណាមខាងជើង ហើយបន្ទាប់មកសហរដ្ឋអាមេរិកបានរារាំងមិនឲ្យប្រទេសកម្ពុជាធ្លាក់ក្នុងសង្គ្រាមត្រជាក់នេះទេ ។ ប៉ុន្តែ ក្រោយមក លន់ នល់ និង ប៉ុល ពត ដែលជាអ្នកចូលរួមនៅក្នុងសង្គ្រាមត្រជាក់នេះបានគិតថា សម្ព័ន្ធមិត្តរបស់ខ្លួនជាមួយនឹងសហរដ្ឋអាមេរិក និងប្រទេសចិនអាចនឹងធ្វើឲ្យខ្លួនមានអំណាចគ្រប់គ្រាន់ដើម្បីទទួលជ័យជម្នះ ។ ប៉ុន្តែសម្ព័ន្ធមិត្តនេះគឺជាភាពល្ងង់ខ្លៅទៅវិញទេ ហើយជាលទ្ធផលរបបគ្រប់គ្រងអំណាចរបស់អ្នកទាំងពីរនេះត្រូវបានកម្ចាត់ចោល ។ បើវិភាគតាមទស្សនៈនៃសង្គ្រាមត្រជាក់នេះ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានចាត់ទុកជាអ្នកនៅក្រោមបង្គាប់របស់សហភាពសូវៀតមិនមែនជារបបមួយដែលត្រូវការជំនួយពីសហគមន៍អន្តរជាតិ និងផលប្រយោជន៍ពីការធ្វើជាសមាជិករបស់អង្គការសហប្រជាជាតិនោះទេ ។

បើនិយាយពីឆ្នាំ២០១១នេះវិញ ខ្ញុំគ្មានសង្ឃឹមថាប្រទេសកម្ពុជាអាចដកខ្លួនចេញពីសង្គ្រាមត្រជាក់បានឡើយដែលសង្គ្រាមត្រជាក់នេះបានបណ្តាលឲ្យមានផលប៉ះពាល់ខ្លាំងដល់អាយុជីវិតប្រជាជន ការចំណាយទាំងថវិកា និងកម្លាំង និងការខូចខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធទៀតផង ។ បើប្រៀបធៀបលំដាប់ថ្នាក់ពិភពលោកវិញ វាពិតជាពិបាកសម្រាប់ប្រទេសកម្ពុជាក្នុងការចាប់ផ្តើមស្តាបនាស្ថានភាពក្រោយការបំផ្លិចបំផ្លាញធ្ងន់ធ្ងរទាំងអស់នេះ ។ មេរៀនដែលប្រទេសកម្ពុជាអាចរៀនសូត្រពីសង្គ្រាមត្រជាក់នេះបានគឺថា ប្រទេសកម្ពុជាមិនត្រូវចងសម្ព័ន្ធមិត្តជាមួយប្រទេសណាៗទាំងអស់ ពីព្រោះថាប្រទេសកម្ពុជាអាចធ្លាក់ខ្លួនចូលជាអ្នកបម្រើឲ្យប្រយោជន៍ប្រទេសនោះជាជាងបម្រើឲ្យប្រយោជន៍ប្រជាជនខ្លួនឯង ។ បើនិយាយពីការបំផ្លិចបំផ្លាញ និងស្ថានភាពស្មុគស្មាញផ្សេងៗរបស់ប្រទេសកម្ពុជាដែលបណ្តាលមកពីសង្គ្រាមត្រជាក់នេះវិញ គ្មានការប្រព្រឹត្តឡើងវិញតាមប្រវត្តិសាស្ត្រកម្ពុជាមុនទសវត្សរ៍៩០ឡើយ ។ ទោះបីជាយ៉ាងនេះក្តី វាក៏មានសារសំខាន់ដូចគ្នាដែលថាអ្នកទាំងអស់គ្នាមិនត្រូវបំភ្លេចនូវប្រវត្តិសាស្ត្រនេះចោលឡើយ ហើយជាពិសេសយើងមិនត្រូវបំភ្លេចចោលនូវប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមដែលនឹងត្រូវយកមករៀបរាប់នៅក្នុងជំពូកក្រោយដែលយើងនឹងធ្វើការពិភាក្សា និងសិក្សានៅក្នុងរយៈពេលប៉ុន្មានថ្ងៃនិងសប្តាហ៍ខាងមុខនេះ ។

**ដេវីដ ឆេនដល័រ**

# បញ្ហាសុខភាពអាចជាឧបសគ្គដល់ដំណើរការស្វែងរកការពិត

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វិស័យសុខាភិបាលត្រូវបានអង្គការលើកសរសើរយ៉ាងខ្លាំងបន្ទាប់ពីវិស័យយោធា ។ ខ្មែរក្រហមបានធ្វើការជ្រើសរើសនារីៗដែលមានអាយុក្មេងៗឲ្យចូលបម្រើវិស័យសុខាភិបាលនេះ ដែលភាគច្រើនគឺជាអ្នកដែលទទួលការអប់រំនយោបាយ និងមានវណ្ណៈស្អាតស្អំ ប៉ុន្តែមិនចេះអក្សរនិងមិនបានរៀនវគ្គបណ្តុះបណ្តាលទាក់ទងនឹងវិស័យពេទ្យនោះទេ ។ ហេតុដូច្នេះហើយ យើងឃើញថា នៅពេលដែលអ្នកជំងឺត្រូវបានបញ្ជូនមកព្យាបាលនៅមន្ទីរពេទ្យ ភាគច្រើនគឺបានស្លាប់ដោយសារតែមិនមានថ្នាំព្យាបាល ការមើលថែទាំមិនបានដិតដល់ពីសំណាក់គ្រូពេទ្យ ប្រើប្រាស់ថ្នាំដែលផ្សំពីឫសឈើ (ថ្នាំអាចម៍ទន្សាយ) ដែលពុំមានប្រសិទ្ធភាពដូចថ្នាំបរទេស ។ លើសពីនេះទៅទៀត អ្នកជំងឺមួយចំនួនទៀតក៏បានស្លាប់ដោយសារតែការចោទប្រកាន់របស់អង្គការថាធ្វើពុត ឬគ្មានសតិអារម្មណ៍ ដូចពាក្យស្លោកថា "គ្មានទន្សាយ ឬគ្មានញាក់ គ្មានញ័រ គ្មានគ្រាក់ទ័រគ្មានឡាន" ហើយមិនត្រូវអនុញ្ញាតឲ្យឈប់សម្រាកទេ ។

យ៉ាងណាមិញ ទាក់ទងនឹងសវនាការថ្ងៃទី២៩ ខែសីហានេះ យើងឃើញថា មេដឹកនាំខ្មែរក្រហម នួន ជា និង អៀង ធីរិទ្ធ បានធ្វើការស្នើសុំទៅអង្គសវនាការដើម្បីឲ្យមានអ្នកជំនាញធ្វើការវាយតម្លៃទៅលើសម្បទារបស់ខ្លួន ។ ស្ថានភាពរបស់មេដឹកនាំទាំងពីរនេះហាក់បីដូចជាស្ថិតក្នុងសភាពទ្រុឌទ្រោមដោយសារវ័យចាស់ជរា ជាពិសេស អៀង ធីរិទ្ធ ដែលមានអាយុតិចជាងគេក្នុងចំណោមមេដឹកនាំធំៗទាំងបួនរូប ។ នៅក្នុងដំណើរការសវនាការដំបូងនេះ គឺមានវត្តមានរបស់លោកសាស្ត្រាចារ្យ ចន ខាំប៉ែល អាយុ៦៥ឆ្នាំ ជនជាតិញូវហ្សេឡង់ ដែលមានជំនាញខាងថែទាំមនុស្សចាស់ដើម្បីធ្វើការបកស្រាយពីរបាយការណ៍ដែលគាត់បានរកឃើញទាក់ទងនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ ។

យើងឃើញថា ការស្នើសុំឲ្យមានការវិភាគទៅលើបញ្ហាសុខភាពនេះពិតជាមានសារសំខាន់ណាស់ព្រោះថាវាអាចបង្កជាឧបសគ្គមួយដល់ដំណើរស្វែងរកការពិត និងធ្វើឲ្យមានការពន្យារពេលដល់ដំណើរការរបស់តុលាការ ប្រសិនបើរកឃើញថាគាត់មានជំងឺ ។ តាមរយៈរបាយការណ៍របស់អ្នកជំនាញ ចន ខាំប៉ែល បានបង្ហាញថា ចំពោះករណី អៀង ធីរិទ្ធ គឺវាមិនខុសគ្នានឹងលទ្ធផលដែលវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យកាល់ម៉ែត្រដែលបានធ្វើការពិនិត្យកាលពីឆ្នាំ២០០៧ នោះទេគឺគាត់មានបញ្ហាខាងផ្នែកស្មារតីពិតមែន ។ ចំណែកឯ នួន ជា គឺមានកាយសម្បទាគ្រប់គ្រាន់អាចចូលរួមក្នុងដំណើរការសវនាការ ។ ប៉ុន្តែផ្ទុយទៅវិញ ក្នុងបន្ទប់សវនាការនៅថ្ងៃនេះ គាត់បានថ្លែងថា គាត់ពិតជាចង់ចូលរួមនៅក្នុងដំណើរការសវនាការណាស់ ប៉ុន្តែដោយសារតែគាត់មានបញ្ហាសុខភាពគឺបញ្ហាផ្លូវអារម្មណ៍ដូចជាស្តាប់និងអានបានរយៈពេលប្រហែលមួយម៉ោងប៉ុណ្ណោះ ក្រោយពីនោះភ្នែកគាត់នឹងស្រវាំងនាំឲ្យប៉ះពាល់ដល់ខួរក្បាល បេះដូងញ័រ សម្ពាធឈាមឡើង ហើយឈឺចង្កេះមិនអាចអង្គុយបាន ។ ជាងនេះទៅទៀតគាត់បាននិយាយថា លោក ខាំប៉ែល មិនបានពិនិត្យទៅលើបញ្ហានេះទេ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏លោក ខាំប៉ែល បានថ្លែងថា បញ្ហាផ្លូវអារម្មណ៍មិនមានបញ្ហាអីទេចំពោះ នួន ជា ពីព្រោះពេលពិនិត្យសុខភាព គាត់អាចសួរឆ្លើយបានត្រឹមត្រូវ ហើយបញ្ហានេះអាស្រ័យទៅលើ នួន ជា ដែលមិនបានផ្លូវអារម្មណ៍ ។ ចំពោះការចងចាំវិញគឺគាត់មានការចងចាំបានល្អផងដែរ ។

ដោយសារតែមានមានភាពមិនស៊ីសង្វាក់គ្នារវាងការបកស្រាយរបស់អ្នកជំនាញ និងការលើកឡើងរបស់ជនជាប់ចោទបានធ្វើឲ្យអ្នកចូលរួមមួយចំនួនមានការយល់ឃើញខុសគ្នាៗហើយធ្វើការប្រៀបធៀបការស្នើសុំរបស់គាត់ទៅនឹងរយៈពេលដែលគ្រប់គ្រងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលពេលនោះវិស័យពេទ្យ ឬសុខាភិបាលគឺមិនមានពេទ្យព្យាបាលអ្នកជំងឺឲ្យ

បានត្រឹមត្រូវនោះទេ ហើយក៏គ្មានថ្នាំគ្រប់គ្រាន់ដើម្បីព្យាបាលដែរ ។ ឥឡូវនេះ ជនជាប់ចោទយកជំងឺនេះដើម្បីធ្វើការស្នើសុំ ហើយធ្វើការពន្យារពេលដល់ការស្វែងរកការពិត និងការកាត់ក្តីរបស់ខ្លួនទៅវិញ ។

យក់ ណឹល អាយុ៦៣ឆ្នាំ រស់នៅស្រុកកោះអណ្តែត ខេត្តតាកែវ បានរៀបរាប់ទាំងទឹកមុខមាំដោយអារម្មណ៍ខឹងនឹងមេដឹកនាំខ្មែរក្រហមយ៉ាងខ្លាំងថា «ទោះបីជាមេដឹកនាំទាំងនេះស្លាប់បាត់បង់ជីវិតហើយក៏ដោយ ក៏ខ្ញុំចង់ឲ្យតុលាការយកឈ្មោះរបស់មេដឹកនាំខ្មែរក្រហមមកកាត់ទោសដែរ ដើម្បីឲ្យប្រជាជនបានអស់ចិត្ត» ។ ណឹល យល់ឃើញថា ចំពោះករណីមេដឹកនាំ នួន ជា និង អៀង ធីរិទ្ធ កំពុងតែធ្វើការស្នើសុំទៅតុលាការដើម្បីឲ្យមានអ្នកជំនាញវាយតម្លៃទៅលើសម្បទា និងស្មារតីរបស់ជនជាប់ចោទ គាត់មិនមានការអាក់អន់ចិត្តទេ ព្រោះនេះជារឿងធម្មតាទេដែលមនុស្សវ័យចំណាស់មានជំងឺបែបនេះ ។ ប៉ុន្តែប្រសិនបើគិតពីពេលដែលមេដឹកនាំទាំងនេះគ្រប់គ្រងវិញ នៅពេលនោះ ហេតុអ្វីបានជាប្រជាពលរដ្ឋមិនទទួលបាននូវការព្យាបាលឲ្យបានត្រឹមត្រូវបែបនេះដែរ ។

ណឹល មានបងប្រុសម្នាក់ឈ្មោះ យក់ អ៊ាវ ស្លាប់ដោយសារជំងឺ ដោយសារតែពេទ្យមិនបានព្យាបាលឲ្យគាត់ជិតដល់ ។ ណឹល បានបន្តថា នៅពេលដែលបងប្រុសរបស់គាត់មានជំងឺ គាត់ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យឃុំ មួយសប្តាហ៍ក្រោយមកគាត់ក៏បានស្លាប់នៅទីនោះ ។ ចំណែកខ្លួនរបស់គាត់វិញ នៅពេលដែលគាត់ត្រូវបានបញ្ជូនឲ្យព្យាបាលនៅមន្ទីរពេទ្យតំបន់ ដែលជាពេទ្យសម្រាប់ព្យាបាលកងចល័ត គាត់សង្កេតឃើញថា ថ្នាំពេទ្យមានតែថ្នាំអាចម៍ទន្សាយ និងប្រើប្រាស់ទឹកដូងប៉ុណ្ណោះ ដើម្បីព្យាបាល ។ លើសពីនេះទៅទៀត បុគ្គលិកដែលធ្វើការនៅទីនោះភាគច្រើនគ្មានជំនាញអ្វីទេ ។ ហេតុដូច្នេះហើយ គាត់បានឃើញមនុស្សស្លាប់ស្ទើរជារៀងរាល់ថ្ងៃ ហើយយកទៅកប់នៅទីធ្លាខាងលិចមន្ទីរពេទ្យ ។ ណឹល បន្តថា «ដោយសារតែខ្ញុំមានសំណាង ទើបខ្ញុំអាចរស់បាន» ។ ចុងក្រោយ ណឹល គ្មានអ្វីក្រៅពីទទូចសុំឲ្យតុលាការកាត់ទោសឲ្យបានឆាប់ កុំឲ្យអ្នកទាំងនេះស្លាប់មុនពេលជំនុំជម្រះក្តីប៉ុណ្ណោះ» ។

សុខ យ៉ាន អាយុ៦០ឆ្នាំ រស់នៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងបានរៀបរាប់ឲ្យដឹងថា នៅក្នុងរបបខ្មែរក្រហម ឪពុករបស់គាត់ត្រូវបានបង្ខំឲ្យធ្វើការហួសពីកម្លាំង ក្រោយមកក៏មានជំងឺហើម ។ ពេលដែលគាត់ទទួលដំណឹងថា ឪពុកឈឺ អង្គការបានអនុញ្ញាតឲ្យគាត់មកសួរសុខទុក្ខគាត់បានរយៈពេលពីរថ្ងៃប៉ុណ្ណោះ ។ ស្ថានភាពរបស់គាត់មានជំងឺហើមយ៉ាងខ្លាំង ប៉ុន្តែឪពុករបស់គាត់មិនបានទទួលការព្យាបាលពីពេទ្យខ្មែរក្រហមទេ ដោយគ្រាន់តែផ្តល់ថ្នាំអាចម៍ទន្សាយឲ្យគាត់ប៉ុណ្ណោះ ។ ពេលដែលគាត់ត្រឡប់ទៅកងវិញ គាត់បានទទួលដំណឹងថា ឪពុករបស់គាត់ស្លាប់ហើយ ។ ពេលនោះ អង្គការមិនអនុញ្ញាតឲ្យគាត់មកជួបឪពុករបស់គាត់ជាលើកចុងក្រោយទេ ។ ចំណែក យ៉ាន វិញ ពេលដែលគាត់មានជំងឺគ្រុនចាញ់ ខ្មែរក្រហមបានអនុញ្ញាតឲ្យគាត់ឈប់សម្រាករយៈពេលពីរថ្ងៃដែរ ប៉ុន្តែត្រូវជួយធ្វើកិច្ចការខ្ចះៗនៅសហករណ៍ដែរ ។ គាត់បន្តថា ខ្មែរក្រហមបានចោទគាត់ថា ខ្ជិល និងឈឺពុត (មានជំងឺសតិអារម្មណ៍) ។ ឥឡូវនេះ យ៉ាន យល់ថា ពេលដែលមេដឹកនាំទាំងនេះបានធ្វើការស្នើសុំទៅអង្គសវនាការដើម្បីឲ្យមានអ្នកជំនាញវាយតម្លៃទៅលើសម្បទារបស់គាត់ គាត់មានការអាក់អន់ចិត្តបន្តិច ព្រោះវាធ្វើឲ្យមានការពន្យារពេលទៅដល់ដំណើរការរបស់តុលាការ ។ តែទោះជាយ៉ាងណាក៏ដោយ គាត់យល់ថាវាអាស្រ័យទៅលើច្បាប់ទៅចុះ ។

ម៉ាន សូត្រ ដែលរស់នៅស្រុកបារាយ ខេត្តកំពង់ធំ ក៏បានរៀបរាប់ថា គាត់មានក្មួយប្រុសម្នាក់ឈ្មោះ ភូ អាយុប្រហែល ២០ឆ្នាំ បានស្លាប់នៅក្នុងរបបខ្មែរក្រហមដោយសារជំងឺ ។ នៅពេលនោះ ក្មួយរបស់គាត់ត្រូវបានគេសែងទៅពេទ្យសហករណ៍នៅសិរីសាមគ្គី ប៉ុន្តែនៅទីនោះមិនមានថ្នាំព្យាបាលឲ្យបានត្រឹមត្រូវទេ គឺមានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះ ។ ដោយសារតែការព្យាបាលគ្មានប្រសិទ្ធភាព បានប្រហែលពីរបីថ្ងៃក្រោយមកក៏បញ្ជូនគាត់ទៅពេទ្យមួយទៀត ហើយគាត់នៅតែស្លាប់ដដែល ។

រាល់ថ្ងៃនេះ សូត្រ មានអាយុ៧៨ឆ្នាំហើយ ។ ប្រសិនបើប្រៀបធៀបទៅនឹងអាយុរបស់ជនជាប់ចោទវិញ សូត្រ យល់ឃើញថា ប្រសិនបើពេទ្យវាយតម្លៃថា សុខភាពរបស់គាត់ពិតជាមិនល្អមែន ហើយត្រូវយកទៅព្យាបាលនៅមន្ទីរពេទ្យ ឬបើ

មិនដាយកទៅប្រទេសក្រៅដែលធ្វើឲ្យតុលាការពន្យារពេល ដោយសារបញ្ហាជំងឺនេះ គាត់ក៏អស់ចិត្តដែរ ។

លោកតា ជឹង ផាន អាយុ៩៩ឆ្នាំ រស់នៅខេត្តតាកែវ បានរៀបរាប់ថា «បើទោះបីជាខ្ញុំមិនមានបងប្អូនស្លាប់នៅក្នុងរបបខ្មែរក្រហមដោយសារជំងឺក៏ដោយ ប៉ុន្តែកាលជំនាន់ខ្មែរក្រហមនោះពិតជាលំបាកណាស់ ព្រោះខ្ញុំបានឃើញអ្នកជំងឺជាច្រើនស្លាប់ដោយសារតែមិនមានថ្នាំព្យាបាល ។ ចំណែកថ្នាំខ្មែរក្រហមប្រើជាទូទៅគឺមានតែថ្នាំខ្មៅៗដែលយើងហៅថាថ្នាំអាចម៍ទន្សាយគ្មានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺទូទៅបានឡើយ» ។

ទាក់ទងនឹងសវនាការនាពេលព្រឹកនេះវិញ ដែលបានលើកមកពិភាក្សាអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ មានសាស្ត្រាចារ្យមកពីបរទេសដែលនិយាយពីសុខភាពថា មានសតិមិនល្អដែលអាចអាចពន្យារពេលនៅក្រោយទៀត គាត់រៀបរាប់ឲ្យដឹងថា «ខ្ញុំមិនអាចសន្និដ្ឋានថាគាត់ឈឺពិតមែន ឬក៏អត់នោះទេ ។ ប៉ុន្តែនៅពេលដែលមានអ្នកជំនាញវិភាគអំពីសម្បារបស់មេដឹកនាំទាំងនេះ ខ្ញុំជឿថាអ្នកជំនាញនឹងរកឃើញថាការពិតនឹងទៅជាយ៉ាងណា» ។ ផាន យល់ឃើញ «តុលាការគួរតែយកជនជាប់ចោទនេះមកកាត់ទោសមិនចាំបាច់គិតពីការឈឺ ឬមិនឈឺនោះទេ ពីព្រោះកាលពីជំនាន់ខ្មែរក្រហមមេដឹកនាំទាំងនេះមិនដែលគិតថាយើងឈឺឬមិនឈឺនោះទេ ។ លើសពីនេះ កាលនោះយើងឈឺតិចតួច គេថាយើងមាយាដល់ពេលគេឈឺវិញ សុទ្ធតែមានពេទ្យអន្តរជាតិមកពិនិត្យ ។

ចំណែក ង៉ែត សន អាយុ៥៩ រស់នៅភូមិស្រុកកោះអណ្ដែត ខេត្តតាកែវ ក៏មានយោបល់មិនខុសពីអ្នកភូមិខាងលើដែរ ។ សន បានរៀបរាប់ទាំងទឹកមុខស្រងូតស្រងាត់ថា «កាលពីសម័យខ្មែរក្រហមខ្ញុំមានជំងឺរាគជាខ្លាំងដោយសារតែបរិភោគគ្មានអនាម័យ ។ ពេលខ្ញុំទៅសុំថ្នាំពេទ្យ ពេទ្យនៅទីនោះមិនចង់ទាំងមើលមុខខ្ញុំផង ហើយគេឲ្យថ្នាំខ្មៅៗដូចអាចម៍ទន្សាយមកឲ្យខ្ញុំលេប ប៉ុន្តែគ្មានប្រសិទ្ធភាពទេ ។ ដូច្នេះខ្ញុំបានទៅបេះស្លឹកត្របែកយកមកបុកហូបក្នុងរយៈពេលបីថ្ងៃទើបជាសះស្បើយ ។ ខ្មែរក្រហមអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកតែមួយថ្ងៃប៉ុណ្ណោះ» ។

សន បានបន្ថែមថា មេដឹកនាំខ្មែរក្រហមនិយាយថាគាត់ចាស់មានជំងឺ តែកាលសម័យនោះមិនថាចាស់ឬក្មេងនោះទេ ក៏ត្រូវតែទៅធ្វើការដែរ ។ សន បន្តថា «ការព្យាបាលនេះអាចពន្យារពេលដល់ដំណើរការរបស់តុលាការ ។ ខ្ញុំអារម្មណ៍អន់ចិត្ត និងមិនសប្បាយចិត្តបន្តិចដែរ ព្រោះកាលនោះគេ (ខ្មែរក្រហម) ធ្វើបាបប្រជាជនយើងមិនគិតចាស់ក្មេងឈឺជានោះទេ ។ ដល់ពេលនេះតុលាការយកគាត់មកកាត់ទោស គាត់បែរជាយកលេសថាឈឺនេះឈឺនោះ» ។

នៅក្នុងដំណើរការសវនាការពេញមួយថ្ងៃនេះ នៅតែមិនទាន់ដឹងពីការពិតថា បញ្ហាសុខភាពរបស់ជនជាប់ចោទនេះនឹងត្រូវបានសម្រេចយ៉ាងណានោះទេ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏បញ្ហាសុខភាពនេះពិតជាមានសារសំខាន់ណាស់ ហើយទាមទារឲ្យមានការស្វែងរកការពិតឲ្យបានត្រឹមត្រូវព្រោះថាប្រសិនជនជាប់ចោទ នួន ជា ត្រូវបានរកឃើញថាមានបញ្ហាខាងស្មារតីពិតមែនដូចករណី អៀង ធីរិទ្ធ នោះដំណើរការស្វែងរកការពិតនៅប្រទេសកម្ពុជានឹងត្រូវបានពន្យារពេល ហើយកំហឹងរបស់ប្រជាជននឹងនៅតែកើតមាន ។

**គាត លក្ខិណា និង ឆាយ ឈុនលី**

# ដំណឹងស្វែងរកសាច់ញាតិ

នាងខ្ញុំឈ្មោះ កង ឃិន អាយុ ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិអន្លង់ជ្រៃ ឃុំអំពើង ស្រុកបន្ទាយមាស ខេត្តកំពត ។ សូមប្រកាសស្វែងរកកូននិងប្ដីដែលបាត់ខ្លួនកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ។ កូនរបស់ខ្ញុំឈ្មោះ ហួម ហើយប្ដីឈ្មោះ ពីន ។ អ្នកទាំងពីរត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើស្រែអំបិលនៅកែប ហើយមិនឃើញត្រឡប់មកវិញរហូតដល់សព្វថ្ងៃ ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះ ឬឮដំណឹងនេះ សូមមេត្តាទាក់ទងមកអាសយដ្ឋានរបស់នាងខ្ញុំដូចបានរៀបរាប់ខាងលើឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ***

# រឿងរ៉ាវពិតរបស់ខ្ញុំ

**(តពីលេខមុន)**

## អាយុមិនអស់មិនស្លាប់

នារដូវប្រាំងមួយប្រហែលជាក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ ពេលខ្ញុំត្រឡប់មកពីអន្តភាពធ្វើបន្ទីរបស់ឪពុកខ្ញុំ ខ្ញុំក៏ឃើញម្តាយខ្ញុំត្រូវអ្នកមូលដ្ឋានប្រើឲ្យទៅរកស្វាយ ។ ដោយសារតែគាត់មិនហ៊ានប្រកែកនឹងការចាត់តាំងនេះ គាត់បានឲ្យខ្ញុំនាំគាត់ទៅរកបេះស្វាយស្រគាលឲ្យគាត់ ។ ព្រឹកនោះ ខ្ញុំបាននាំគាត់ដើរចម្ងាយប្រហែលប្រាំពីរគីឡូម៉ែត្រពីភូមិលាជឆ្លងស្ទឹងកំពង់លួងឆ្ពោះទៅកាន់តំបន់ដំណាក់ឈើក្រំដែលជាតំបន់ព្រៃស័ក្តិសិទ្ធសម្បូរផ្លែឈើគ្រប់ប្រភេទ ។

ពេលទៅដល់ទីនោះ យើងឃើញមានដើមស្វាយទំហំប៉ុនកង់រទេះ និងកម្ពស់ជាងដប់ម៉ែត្រជាច្រើនដើម ។ ប៉ុន្តែក្នុងចំណោមនោះមានតែដើមស្វាយមួយដើមគត់មានផ្លែពេញដើម ផ្លែខ្លះចាស់ខ្លះស្រគាល និងខ្លះទៀតត្រូវបានសត្វស៊ី ។ ពេលដែលក្រឡេកមើលទៅគល់ស្វាយមានស្នាមឆូតដោយកាំបិតជាសញ្ញាខ្វែងជើងក្អែក និងក្បាលខ្មោច ហើយចារថា ៈ ប្រសិនបើឡើងនឹងស្លាប់ជាមិនខាន ។ ឃើញដូច្នេះ ខ្ញុំបានប្រាប់ម្តាយខ្ញុំថា ដើមនេះឡើងមិនបានទេ បើហ៊ានឡើងច្បាស់ជាធ្លាក់ស្លាប់មិនខាន រួចក៏បបួលគាត់ទៅរកកន្លែងផ្សេងទៀត ។ ដោយសារតែដើររពីរកន្លែង ហើយនៅតែរកមិនឃើញដើមស្វាយដែលមានផ្លែស្វាយបែបនេះបាន ម្តាយខ្ញុំបានហៅខ្ញុំឲ្យត្រឡប់មករកកន្លែងដដែលវិញ ។ ពេលទៅដល់ដើមស្វាយនោះ គាត់ក៏បានអង្គុយលុតជង្គង់លើកដៃសំពះមេឃសំពះដី និងសំពះដើមស្វាយដោយនិយាយខបកិច្ចទៅអ្នកតាអារក្សដែលរក្សាដើមស្វាយសូមបេះឲ្យគេបានមួយហូបគ្រប់គ្រាន់ ។ ក្រោយពីបន់ស្រន់រួច គាត់ក៏តឿនខ្ញុំឲ្យឡើងបេះ ។ ប៉ុន្តែខ្ញុំនៅតែមិនព្រមឡើងដើមស្វាយនេះទេ ដោយប្រាប់គាត់ថា បើខ្ញុំហ៊ានឡើងច្បាស់ជាត្រូវស្លាប់ជាមិនខាន ។ ដោយសារតែគាត់បារម្ភខ្លាចអង្គការដាក់ពិន័យគាត់និងប្តូរការងារទៅកន្លែងផ្សេងវិញដែលធ្វើកូនតូចៗត្រូវដាច់ពោះស្លាប់ គាត់ក៏អង្វរខ្ញុំ ហើយអង្វរទៀត ។ ខ្ញុំមិនអាចប្រកែកបានក៏សម្រេចចិត្តថាត្រូវតែឡើងបេះស្វាយនេះជូនគាត់ទាំងអារម្មណ៍ភ័យរន្ធត់ និងព្រឺសម្បុរគីង្គក់ ។ ឡើងទៅដល់ចុងមែកខ្ពស់ ខ្ញុំក៏មិនហ៊ានងាកមើលខាងក្រោមដែរ គិតតែមើលទៅលើ និងសម្លឹងរកមើលផ្លែស្វាយ ។ ខ្ញុំឃើញផ្លែស្វាយខ្ចីចាស់ និង ស្រគាលជិតទុំ និងខ្លះត្រូវសត្វស៊ីអស់មួយចំហៀងៗក៏មាន រួចខ្ញុំក៏បេះទម្លាក់មកដី ។ ខណៈពេលនោះ មេឃដែលស្រឡះមានពន្លឺថ្ងៃស្រាប់តែប្រែទៅជាខ្មៅមានភ្លៀង ហើយធ្លាក់ហ្វូងស្រមោចក្រហមមកខាំខ្ញុំច្រើនណាស់ ធ្វើឲ្យខ្ញុំទ្រាំមិនបាន ហើយក៏អង្គុយប្រុងសម្រូតខ្លួនចុះក្រោមវិញ ។ ប៉ុន្តែខ្ញុំស្រាប់តែឃើញស្រមោលមនុស្សខ្មៅធំមួយចេញមកទាញជើងនិងដៃខ្ញុំទាំងពីរដែលខំប្រឹងឱបមែកស្វាយ ហើយឮសម្រែកម្តាយខ្ញុំស្រែកល្មើយៗថា កូនតោងឲ្យជាប់ ។ ខ្ញុំទ្រាំលែងបានទៀតហើយ ព្រោះជើងទាំងពីរត្រូវបានស្រមោលខ្មៅតោងជាប់ និងមានហ្វូងស្រមោចខាំខ្ញុំផងធ្វើឲ្យខ្ញុំធ្លាក់ពីមែកស្វាយខ្ពស់បំផុតមកទើលើមែកស្វាយខាងក្រោមរួចធ្លាក់បន្តមកដី ។ ពេលធ្លាក់មកដល់ដី ខ្ញុំនៅតែមានស្មារតីនឹងនររួចប្រវេប្រវាស្ទុះក្រោកឈរ ។ ប៉ុន្តែគ្រាន់តែបោះជើងស្តាំឈានទៅមុខ ខ្ញុំក៏ដួលទៅវិញ ក្រឡេកមើលទៅជើងខាងស្តាំមានឈាមហូរជោគប្រឡាក់ខោជើងវែងដល់ចុងជើង ទើបខ្ញុំបានដឹងថាត្រូវបាក់ជើង ។

មេឃដែលងងឹតមានភ្លៀងធ្លាក់បានប្រែទៅជាស្រឡះធម្មតាវិញ បន្ទាប់មកម្តាយខ្ញុំបានស្ទុះមកឱបខ្ញុំ យំផងស្រែកផងសម្លឹងមើលជើងខ្ញុំដែលចេញឈាម ។ ខ្ញុំបានប្រាប់ម្តាយខ្ញុំឲ្យប្រមូលស្វាយយកទៅផ្ទះ រួចមើលប្អូនៗរបស់ខ្ញុំវិញ ។ ប៉ុន្តែគាត់មិនព្រមទៅទេ ដោយគាត់ស្រែកហៅគេមកជួយ ។ មួយសន្ទុះក្រោយមកខ្ញុំឃើញយោធាស្លៀកសម្លៀកបំពាក់ខ្មៅមួយក្រុមមានគ្នា៤-៥នាក់មករោមមើលខ្ញុំ ។ ឃើញដូច្នេះ ម្តាយខ្ញុំបានហុចសំបុត្រខ្ទេសនាមដែលប្រធានភូមិចាត់តាំងឲ្យគាត់ធ្វើជាអ្នករកបន្លែផ្គត់ផ្គង់ការដ្ឋានភូមិដើម្បីបង្ហាញ ។ ខ្ញុំឃើញយោធាម្នាក់មកទាញជើងខ្ញុំឲ្យត្រង់ រួចយកក្រមារបស់គាត់ចងពីលើស្នាមបាក់ ហើយសូត្រជុំមន្តអាគមន៍ដាក់លើជើងរបស់ខ្ញុំ និងយោធាម្នាក់ទៀតមកយកអង្រឹងក្រាលលើដី ហើយពីរនាក់លើកខ្ញុំដាក់លើអង្រឹង មានយោធា

ម្នាក់ទៀតចាប់កាប់ឫស្សីយកមកធ្វើស្នែង ហើយសែងខ្ញុំចេញភ្លាម ។ ពេលសែងទៅរកមន្ទីរពេទ្យ ខ្ញុំសន្លប់ដឹងខ្លួនផង ។ ពេលនោះ ខ្ញុំឃើញស្រមោលខ្មៅដែលបានប្រានខ្ញុំទម្លាក់ពីលើដើមស្វាយបានហោះតាមអង្រឹងជាប់ ។

យោធាពីរនាក់បានសែងខ្ញុំឆ្លងស្ទឹងយ៉ាងលំបាក ហើយប្រាប់ខ្ញុំថាកុំដេកៗ ត្រូវតែទ្រាំជិតដល់ពេទ្យហើយ ។ ពេលដែលខ្ញុំដឹងខ្លួនមកវិញ ខ្ញុំក៏ឮសំឡេងម៉ែរបស់ខ្ញុំស្រែកទ្រហោយំ ។ រសៀលបន្តិច យោធាទាំងពីរនាក់បានយកលិខិតខ្ទេសនាមរបស់ម៉ែខ្ញុំឲ្យទៅពេទ្យមើល ។ ម្ដាយខ្ញុំនាំមើលខ្ញុំបានមួយភ្លែត ពេទ្យខ្មែរក្រហមបាននិយាយប្រាប់ម្ដាយខ្ញុំថា មិនមែនជាភារកិច្ចរបស់សមមិត្តទេ ទៅវិញចុះទុកនាទីឲ្យពេទ្យជាអ្នកមើល ។ បន្ទាប់មក ពេទ្យខ្មែរក្រហមបានលើកខ្ញុំដាក់លើគ្រែអ្នកជំងឺគ្រុនចាញ់ដែលកំពុងដេកសន្លប់ ហើយនិយាយថា ដេកលើគ្រែនេះសិនចុះរង់ចាំសមត្ថកិច្ចបងមកពិនិត្យមើល ។ ល្ងាចនោះ ខ្ញុំឃ្លានបាយផងស្រែកទឹកផង ឈាមក៏នៅតែហូរតិចៗចេញពីជើងដែលបាក់ ។ ដោយសារអស់កម្លាំងហេវហត់ និងឈឺចាប់ត្រង់មុខរបួសផង ខ្ញុំក៏សន្លប់បាត់ស្មារតី ។

លុះដល់ពេលដឹងខ្លួន ខ្ញុំស្ថិតនៅលើដីក្នុងបន្ទប់មួយងងឹតសូន្យមើលមិនឃើញអ្វីទាំងអស់ ។ ខ្ញុំយកដៃរាវចុះរាវឡើង និងរំកិលខ្លួនទៅមុខស្រាប់តែប៉ះលើមនុស្សនៅជុំវិញដេកមិនកម្រើកទេ ចំណែកសាច់អ្នកទាំងនោះត្រជាក់ដូចទឹកកកក ទើបខ្ញុំដឹងថាជាសាកសព ។ បន្ទប់ដែលដាក់សាកសពនោះជាបន្ទប់ងងឹតឈឹងលុះព្រលឹមស្រាងៗមានពន្លឺចាំងចូលតាមប្រឡោះក្ដារជញ្ជាំង ទើបខ្ញុំដឹងថាភ្លឺហើយ រួចក៏យកដៃស្ទាំស្ទាបកន្លែងរបួសបាក់ជើង ។

## ខ្ញុំត្រូវបានប្រធានពេទ្យបដិវត្តន៍ខ្មែរក្រហមមកសង្គ្រោះ

ខណៈពេលដែលពេទ្យខ្មែរក្រហមបើកទ្វារបន្ទប់ដើម្បីលើកខ្មោចយកទៅកប់ចោល ខ្ញុំស្រែកថាជួយផងៗ ។ ពេលនោះ ពេទ្យក្មេងៗពីរនាក់បានទម្លាក់ខ្មោចចោល រួចស្ទុះរត់ចេញក្រៅស្រែកថាខ្មោចលងៗ ។ ប៉ុន្តែ ក្រោយមកខ្ញុំឃើញអ្នកទាំងពីរត្រឡប់មកវិញមានទាំងបុរសម្នាក់ទៀតអាយុសាមសិបប្លាយមានរាងខ្ពស់ស្រឡះសម្បុរជ្រះ ទឹកមុខសុភាព និងស្លៀកពាក់ខោអាវខ្មៅថ្មីបង់កក្រមាក្រហមបានដើរចូលមក ។ ខ្ញុំបាននិយាយខ្សាវៗទៅកាន់គាត់ថា សមមិត្តបងអ្នកមានបុណ្យជួយខ្ញុំផង ។ ខ្ញុំមើលទៅរូបរាងគាត់ទំនងជាប្រធានធំនិងប្រហែលជាអ្នកទទួលខុសត្រូវនៅមន្ទីរពេទ្យនេះ រួចនិយាយថា "អ្នកជំងឺនៅរស់សោះ យកមកបោះចោលក្នុងបន្ទប់សាកសព តើសមមិត្តណាជាអ្នកទទួលខុសត្រូវកាលពីម្សិលមិញ? សែងអ្នករបួសនោះយកទៅបន្ទប់សង្គ្រោះវិញ" ។ បន្ទាប់មក ពេទ្យទាំងនោះក៏យកខ្ញុំទៅដាក់បន្ទប់ឈើមួយ ហើយគាត់ក៏បញ្ជាឲ្យពេទ្យយកសេរ៉ូមមកព្យួរឲ្យខ្ញុំ និងចាប់ផ្ដើមចាប់ទាញតម្រង់ជើងខ្ញុំដើម្បីឲ្យឆ្អឹងជាប់គ្នាវិញ ។ ដោយសារតែខ្ញុំឈឺខ្លាំងពេក និងទ្រាំមិនបាន ខ្ញុំក៏សន្លប់បាត់ស្មារតី ។

ពេលខ្ញុំដឹងខ្លួនមកវិញ ពេទ្យយកឫស្សីមកផ្គុបជើងរបស់ខ្ញុំ និងរុំក្រណាត់ស្បៃយ៉ាងណែនធ្វើឲ្យខ្ញុំមានអាការៈធូរស្រាលបន្តិច ។ បន្តិចក្រោយមក ពេទ្យនារីបានលើកបាយថ្ងៃត្រង់ឲ្យខ្ញុំហូប និងឲ្យថ្នាំលេប ។ ក្រោយពីខ្ញុំមានកម្លាំងខ្លះ ខ្ញុំគិតថាខ្ញុំរស់ឡើងវិញហើយ ។ ចំណែកប្រធានពេទ្យដែលបញ្ជាឲ្យគេយកខ្ញុំមកព្យាបាលគាត់ខស្សរាហ៍មកមើលខ្ញុំណាស់ហាក់បីដូចជាយកចិត្តទុកដាក់ចំពោះខ្ញុំខ្លាំងណាស់ ដែលនេះប្រហែលជាបុណ្យកុសលរបស់ខ្ញុំ ។ ថ្ងៃបន្ទាប់ៗ ពេទ្យនារីលើកបាយឲ្យខ្ញុំហូប និងឲ្យថ្នាំខ្ញុំលេបជាប្រចាំដែលប្រៀបបីដូចជាបងស្រីជួយប្អូនប្រុសបង្កើតដែលដើរមិនរួច ។ ពេលម្ដាយខ្ញុំមកមើលខ្ញុំ ពេទ្យនារីៗនិងប្រធានពេទ្យមិនបានស្ដីបន្ទោសឲ្យគាត់ទេ ។ ខ្ញុំបាននិយាយប្រាប់ម្ដាយខ្ញុំសព្វបែបយ៉ាងពីអំពើល្អរបស់ប្រធានពេទ្យ តែខ្ញុំមិនដឹងថាគាត់ឈ្មោះអ្វីទេ ។

ប្រហែលមួយខែក្រោយមក ខ្ញុំលែងបានជួបក្រុមពេទ្យចិត្តល្អនេះទៀតហើយ ព្រោះមានក្រុមពេទ្យនារីផ្សេងទៀតមកធ្វើការជំនួស ដែលក្រុមពេទ្យមកក្រោយនេះគឺជាមនុស្សកាចៗ និងមានវិន័យតឹងតែងណាស់ បើដឹងថាមានសាច់ញាតិណាម្នាក់មកសួរសុខទុក្ខអ្នកជំងឺ នោះនឹងត្រូវគេដេញទាំងអ្នកសួរសុខទុក្ខ និងអ្នកជំងឺចេញពីមន្ទីរពេទ្យភ្លាម ។

ខ្ញុំត្រូវបានពេទ្យប្ដូរមកសម្រាកនៅគ្រែខាងក្រៅជាមួយអ្នកជំងឺវិញ ដែលភាគច្រើនជាមនុស្សចាស់ៗមានជំងឺគ្រុនចាញ់ និងក្មេងៗមានជំងឺហើមដោយសារខ្វះជីវជាតិ ។ មួយរយៈក្រោយមក ស្នាមរបួសដែលត្រូវឆ្អឹងបាក់បានក្លាយទៅជាដំបៅរលួយមានខ្ទុះ និងមានឈាមហូរចេញធ្វើឲ្យសើមក្រណាត់ស្បៃ ។ ពេលនោះ ខ្ញុំគិតថា ខ្ញុំប្រហែលជាមិនអាចគេចផុតពីសេចក្ដីស្លាប់បានឡើយ

ព្រោះពេទ្យមិនបានមកប្តូរក្រណាត់ស្បៃឲ្យខ្ញុំទេ ។ តែជាសំណាងល្អ ដល់ពេលថ្ងៃ ក្រុមពេទ្យវេនទីពីរ និងក្រុមទីបីក៏មកជំនួស ហើយក្រុមទាំងពីរនេះយកចិត្តទុកដាក់ចំពោះជំងឺរបស់ខ្ញុំណាស់ ដោយក្រុមវេនទីបីបានលាងដំបៅឲ្យខ្ញុំ ប្តូរស្បៃមុងថ្មី ថែមទាំងឲ្យហូបបបរគោក និងថ្នាំទៀងទាត់ទៀតផង ។ ខណៈពេលនោះ មន្ទីរពេទ្យនេះបានផ្លាស់ទីតាំងថ្មីនៅមន្ទីរពេទ្យភូមិលាជ រួចក៏សែងខ្ញុំទៅព្យាបាលនៅទីនោះដែរ ។ ខ្ញុំសម្រាកព្យាបាលអស់រយៈពេលប្រាំមួយខែ ដំបៅសាច់ភ្លៅរបស់ខ្ញុំនៅតែមិនជាសះស្បើយឡើយ ។ បន្ទាប់មក ខ្ញុំបានប្រាប់ក្រុមគ្រូពេទ្យដែលជាវេនប្រធានពេទ្យចិត្តល្អដើម្បីពិនិត្យឲ្យខ្ញុំបន្ថែមទៀត ។ គាត់មកពិភាក្សាជាមួយខ្ញុំដោយនិយាយប្រាប់ថា ជើងនេះត្រូវកាត់ត្រឹមកកន្លែងបាក់ចេញទើបអាចជា ។ ប៉ុន្តែ ខ្ញុំបានបដិសេធមិនព្រមឲ្យពេទ្យកាត់ជើងទេ ដោយប្រាប់វិញថា ត្រូវតែវះកាត់ជើងហ្នឹងមើលទើបអាចដឹង ប្រហែលជាឆ្អឹងដុះមុតសាច់ហើយទើបមិនជាបែបនេះ ។

មួយថ្ងៃក្រោយមក ខ្ញុំត្រូវបញ្ជូនទៅកន្លែងវះកាត់ ។ ពេលនោះ ខ្ញុំស្មានថាជើងខ្ញុំត្រូវកាត់បាត់ហើយ ប៉ុន្តែក្រោយមក បុគ្គលិកវះកាត់នោះបានយកអំបោះលីឡុងដេរជប់ប្រាំថ្នេរ រួចរុំក្រណាត់ស្បៃនិងសែងខ្ញុំត្រឡប់មកគ្រែដេកវិញ ។ ខ្ញុំត្រេកអរណាស់ ព្រោះនេះជាវេនរបស់ក្រុមពេទ្យចិត្តល្អ ។ មិនបានមួយម៉ោង អស់ឥទ្ធិពលថ្នាំស្ពឹក ជើងក៏ចាប់ផ្តើមឈឺដូចកាលធ្លាក់ពីដើមស្វាយ ។ ពេលយប់ឈានមកដល់ នៅពេលដែលបុគ្គលិកពេទ្យទៅផ្ទះអស់ ស្រមោលខ្មៅដែលជាខ្មោចដើមស្វាយបានមកជិះលើពោះខ្ញុំ និងដៃទាំងពីរត្របាច់កខ្ញុំ ។ ខ្ញុំគិតថា មិនអាចរស់បានទេ ព្រោះព្រលឹងខ្ញុំស្រែកហៅឪពុកម្តាយខ្ញុំ និងទេវតា អ្នកតា អ្នកសច្ចាំងឲ្យជួយខ្ញុំ តែមិនដឹងនរណាម្នាក់មកជួយទេ មួយសន្ទុះធំខ្ញុំឮសូរសំឡេងមាន់រងាវ ខ្មោចស្រមោលខ្មៅក៏លែងខ្ញុំ ហើយរលាយរូបបាត់ ។

ស្នាមវះជើងប្រហែលមួយចង្អាមដៃធំណាស់ និងជ្រៅទៀតផង រហូតធ្វើឲ្យឈាមបានជ្រាបដោតពេញស្បៃរុំ ។ ខ្ញុំឈឺផ្សាខ្លាំងណាស់ គួបផ្សំនិងពេទ្យមិនឲ្យហូបទៀត ខ្ញុំក៏អស់កម្លាំងពីក្នុងខ្លួន ហើយសន្លប់បាត់ស្មារតីទៀត ។ នៅពេលដឹងខ្លួនមកវិញ ថ្ងៃរះខ្ពស់បន្តិចហើយ ពេទ្យបានឈរពោមមើលខ្ញុំជិត ដោយស្មានថារូបខ្ញុំស្លាប់ដោយសារការឈឺចាប់និងអស់ឈាម ។

ពេលថ្ងៃត្រង់ ពេទ្យយកបាយចំហុយនិងសាច់គោចៀនមកឲ្យខ្ញុំហូប ។ នេះជាលើកទីមួយហើយដែលខ្ញុំបានបាយចំហុយ ចំណែកអ្នកជំងឺផ្សេងៗដែលដើរមិនរួចមិនបានរបបបាយចំហុយដូចរូបខ្ញុំទេ ព្រោះពេទ្យចែកបបរខាប់ឲ្យលើកលែងតែខ្ញុំម្នាក់ ។ បានរយៈពេលកន្លះខែ ខ្ញុំឡើងសាច់ ធាត់ហើយស្នាមវះក៏ចាប់ផ្តើមផ្សះ ។ នៅពេលក្រុមពេទ្យកាចមកដល់ ក្រុមនេះស្រាប់តែចាប់ផ្តើមដេញអ្នកជំងឺឲ្យទៅហូបបាយនៅរោងបាយពេទ្យ ហើយប្តូរពីបាយចំហុយទៅជាបបររាវវិញ ឯថ្នាំលេបក៏ត្រូវពេទ្យប្តូរឲ្យលេបថ្នាំសន្តមកិច្ច (ថ្នាំអាចម៍ទន្សាយ) ព្រមទាំងមិនលាងរបួសឲ្យខ្ញុំទេ ។ ដូច្នេះហើយ ស្នាមវះដែលផ្សះមុខខាងក្រៅបានក្លាយទៅជាដំបៅខាងក្នុង ហើយស្អុយរលួយម្តងទៀត ។ ខ្ញុំមិនបានរុំស្បៃមុងដូចសព្វដងទេ គឺទុកដំបៅធ្លាយចេញ និងរង់ចាំពេទ្យបបរឲ្យហូបប៉ុណ្ណោះ ។ ខ្ញុំតែងតែគិតថាមិនដឹងត្រូវស្លាប់ដោយដំបៅនេះ ឬយ៉ាងណាទេ ។

ប្រហែលដប់ថ្ងៃក្រោយមក កន្លែងដំបៅក៏ខុះឈឺ និងរមាស់ជាខ្លាំង ។ ខ្ញុំសម្លឹងមើលស្បែកសាច់ភ្លៅ គឺស្តើងស្ទើរធ្លាយ ។ ថ្ងៃមួយ ខ្ញុំរំកិលវិតទៅគែមគ្រែ ដំបៅស្រាប់តែធ្លាយចេញមកសុទ្ធតែខ្ទុះនិងដង្កូវ ។ ខ្ញុំបណ្តោយឲ្យខ្ទុះធ្លាយចេញ រហូតដល់អ្នកជំងឺនោះនៅក្បែរនោះនាំគ្នាក្រោកចេញអស់ ព្រោះធុំក្លិនខ្ទុះអណ្តែង និងដង្កូវដែលវារចេញមកនេះ ។ ខណៈពេលនោះចំម៉ោងបាយថ្ងៃត្រង់ ពេទ្យនារីដែលយកបបរមកចែកដល់គ្រែខ្ញុំក៏មានការភ្ញាក់ផ្អើល និងស្រឡាំងកាំង ។ ដៃខ្ញុំទាំងពីរកំពុងយកស្បៃមុងជូតដំបៅ និងរឹតវាកុំឲ្យដង្កូវនិងខ្ទុះចេញមក ស្រាប់តែពេទ្យនារីជួសបបរក្តៅៗ២កំពប់ចំកន្លែងដំបៅនេះ ។ ខ្ញុំឈឺជាខ្លាំង ប៉ុន្តែខ្ញុំមិនហ៊ានស្រែកថ្ងូរឈឺចាប់ទេ ព្រោះខ្លាចពេទ្យស្តីឲ្យ ។ ក្រោយមក ខ្ញុំបែរទៅជាអន់ឈឺចាប់មួយរំពេច ព្រោះធូរស្រាលដូចធ្លាយបូសដូច្នោះដែរ ។ ខ្ញុំមិនដឹងថាតើគាត់មានចេតនាចាក់ទឹកបបរលើជើងរបស់ខ្ញុំ ឬមួយជាវិធីសម្រាប់ព្យាបាលសាច់ស្អុយរលួយបែបនេះនោះទេ ខ្ញុំគ្រាន់តែដឹងថា ពីមួយថ្ងៃទៅមួយថ្ងៃដំបៅនោះបានធូរស្រាល លែងឈឺចាប់ដូចមុន ហើយក៏មិនបានទទួលការមើលថែទាំពីពេទ្យដែរ ព្រោះជាវេនរបស់ក្រុមពេទ្យកាច ។ តែទោះបីជាយ៉ាងណា ក៏ខ្ញុំនឹកគុណគាត់ក្នុងចិត្តដែរ កុំអីប្រហែលជាដំបៅរបស់ខ្ញុំត្រូវដង្កូវចោះរហូតស្លាប់ជាមិនខាន ។ **(នៅមានត)** **ឡៃ ហួត**


អ៊ិត សារ៉េត ក្នុងឆ្នាំ១៩៦៣នៅបែលហ្សិក

# អ៊ិត សារ៉េត សម្លាញ់ខ្ញុំ

ខ្ញុំបានឈ្មោះ ជេមស៍ ប្លេក (James Black) សព្វថ្ងៃរស់នៅរដ្ឋចរចៀ សហរដ្ឋអាមេរិក ។ ខ្ញុំបាទសូមប្រកាសស្វែងរកមិត្តជិតស្និទ្ធម្នាក់ឈ្មោះ អ៊ិត សារ៉េត ដែលបានមកសិក្សានៅសាកលវិទ្យាល័យចរចៀ សហរដ្ឋអាមេរិកកាលពីឆ្នាំ១៩៦២ ឬសាច់ញាតិរបស់ សារ៉េត ដែលអាចរស់រានជីវិតពីជំនាន់ខ្មែរក្រហម ។ ក្រោយពីបញ្ចប់ការសិក្សា សារ៉េត បានវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ ហើយក្រោយមកពីឆ្នាំ១៩៧២ ដល់១៩៧៥ សារ៉េត បានកាន់មុខតំណែងជាប្រធានទីភ្នាក់ងារសារព័ត៌មានខ្មែរ (Agence Khmer de Presse) និងជាសាស្ត្រាចារ្យច្បាប់នៅទីក្រុងភ្នំពេញ ។ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៣ សារ៉េត បានសរសេរលិខិតតូចមួយផ្ញើមកខ្ញុំដោយប្រាប់ថា គាត់ធ្វើការនៅក្រសួងព័ត៌មាន ហើយលែងធ្វើជាចាងហ្វាងការផ្សាយសារព័ត៌មានភ្នំពេញថែមទៀតហើយ ។ គាត់មានខ្សែបង្កេះមួយដែលម្តាយរបស់គាត់ឲ្យគាត់ពាក់ ហើយគាត់បានពាក់ខ្សែបង្កេះនោះមកកាន់សហរដ្ឋអាមេរិកនៅឆ្នាំ១៩៦២ ។ បងប្អូនស្រីរបស់គាត់បានធ្វើស្នុកមួយ ហើយគាត់បានយកស្នុកនោះដើម្បីទុកស្រោមជើងរបស់គាត់ ។ នៅក្នុងឆ្នាំ១៩៧៤ ពេលដែល សារ៉េត មកប្រជុំនៅការិយាល័យអង្គការសហប្រជាជាតិក្នុងបុរីញូវយ៉ក គាត់បានឲ្យខ្ញុករូបហនុមានមួយមកខ្ញុំ ។ ក្រៅពីខ្ញុកនេះ សារ៉េត បានផ្ញើវត្ថុអនុស្សាវរីយ៍មកខ្ញុំជាច្រើន ហើយសព្វថ្ងៃនេះខ្ញុំនៅតែរក្សាទុករបស់ទាំងនេះបានល្អដដែល ។ ប៉ុន្តែចាប់តាំងពីខ្មែរក្រហមចូលកាន់កាប់ប្រទេសកម្ពុជាមក សារ៉េត បានបាត់ខ្លួនរហូត និងមិនដឹងជារស់នៅទីណា ឬស្លាប់នៅទីណាឡើយ ។ ប្រសិនបើនរណាស្គាល់ ឬដឹងព័ត៌មានអំពី អ៊ិត សារ៉េត សូមទាក់ទងមករូបខ្ញុំផ្ទាល់តាមរយៈសារអេឡិចត្រូនិច jlblack.jim@gmail.com ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**


អ៊ិត សារ៉េត ក្នុងឆ្នាំ១៩៦៣


នៅសហរដ្ឋអាមេរិកក្នុងឆ្នាំ១៩៦៤


ខ្សែបង្កេះ និងស្នុកដែល សារ៉េត ប្រគល់ជូន ជេមស៍ ប្លេក


ខ្ញុក

# ស្វែងរកឪពុកម្តាយនិងបងប្អូន

នាងខ្ញុំឈ្មោះ អានី ធូ ឆាយ សព្វថ្ងៃរស់នៅរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ។ នាងខ្ញុំសូមប្រកាសសួររកសាច់ញាតិដែលបានបាត់ខ្លួនកាលពីរបបខ្មែរក្រហមចំនួនប្រាំបួននាក់ ។ កាលពីជំនាន់ខ្មែរក្រហម យើងត្រូវបានបំបែកមិនឲ្យរស់នៅជាមួយគ្នាទេ ហើយយើងក៏មិនបានដឹងដំណឹងអ្វីពីគ្នាទៅវិញទៅមកដែរ ។ ឪពុករបស់ខ្ញុំគឺជាអ្នកលក់ស្ករត្នោត ហើយម្តាយរបស់ខ្ញុំរកស៊ីលក់ទឹកកកឈូស ។ ខ្ញុំមានបងប្រុសម្នាក់ បងស្រីម្នាក់ ប្អូនប្រុសពីរនាក់ និងប្អូនស្រីបីនាក់ ។ គ្រួសាររបស់យើងគឺជាខ្មែរចិនទៀជីវដែលមានត្រកូលឈ្មោះ ធូ ។ ខ្ញុំសូមប្រកាសរកសាច់ញាតិចំនួនប្រាំបួនរូបដូចជា ◆ ឪពុកឈ្មោះ ធូ ធានជីវ ◆ ម្តាយឈ្មោះ ធូ ចាងអ៊ីង ◆ បងប្រុសឈ្មោះ ធូ ចិនវ៉ួយ ◆ បងស្រីឈ្មោះ ធូ អាយអឹ ◆ ប្អូនប្រុសពីរនាក់ទៀតឈ្មោះ ធូ ចិនស៊ីង និង ធូ ចិនចុង ◆ ប្អូនស្រីបីនាក់ទៀត ធូ ឈីងអឺ, ធូ ស៊ីអឺ និង ធូ អ៊ូអឺ ។

ខ្ញុំមានរូបថតបីសន្លឹក ។ រូបទីមួយនិងទីពីរ គឺជារូបថតប្អូនប្រុសបង្អស់របស់ខ្ញុំនិងភរិយារបស់គាត់នៅថ្ងៃរៀបការ ។ រូបទីបីគឺ ជារូបអាពាហ៍ពិពាហ៍របស់ខ្ញុំជិតកាលពីជាងសែសិបឆ្នាំមុន ។ បងស្រីបង្អស់របស់ខ្ញុំនិងប្អូនប្រុស-ស្រីរបស់ខ្ញុំក៏នៅក្នុងរូបថតទីបីនេះដែរ ។



បងប្រុស ធូ ចិនវ៉ួយ នៅថ្ងៃរៀបការ



បងប្រុស ធូ ចិនវ៉ួយ នៅថ្ងៃរៀបការ



រូបនៅថ្ងៃរៀបការរបស់ អានី ធូ ឆាយ

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

edIm,Iyut iFm nigkarcgcaM

EdlCamUld and sMxan;kæægkarpSHpSaCati

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 142, October 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.